អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Jul-2013, 11:48
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី១៩៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

កញ្ញា មីរាម ម៉ាហ្វេសាន់ទិ
*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក ច័ន្ទ តារាស្មី

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSÉ)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធារី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ហើយលោក ដាវ អានសាន ឡើងរាយការណ៍អំពីស្ថានភាពវត្តមានភាគី ដែលអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពជម្រាបលោកប្រធាន! នៅក្នុងសវនាការនាថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីមានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមានពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងដោយសារមូលហេតុសុខភាព។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក អានសាន។

បាទជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ និងសាធារណជន។ ខ្ញុំសូមបន្តការបង្ហាញឯកសារពាក់ព័ន្ធទៅនឹងគោលនយោបាយស្តីពីសហករណ៍ និងជំរំធ្វើការ។ ឯកសារដែលខ្ញុំនឹងបង្ហាញនោះគឺ ឯកសារលេខ E3/5 គឺជាទស្សនាវដ្តីទង់បដិវត្ត ចុះខែសីហា ឆ្នាំ១៩៧៥។

[០៩:០៤:៣៣]

ទស្សនាវដ្តីនេះមានអត្ថបទជាច្រើន ក៏ប៉ុន្តែអត្ថបទទី៤នោះគឺមានចំណងជើងថា “ជ័យជម្នះមួយជំហានសំខាន់ទៀតរបស់សហករណ៍ និងរបស់ចលនាបដិវត្តន៍យើង”។ នៅទំព័រជាភាសាខ្មែរ 00063

347 រហូតទៅដល់ 48, ជាភាសាបារាំងគឺ 00538981, ជាភាសាអង់គ្លេស 00401507។ អត្ថបទនេះមានសរសេរដូចតទៅ៖

"ក្រោយពីប្រទេសជាតិ និងប្រជាជនបានរំដោះទាំងស្រុងមក ហើយដើម្បីអនុវត្តភារកិច្ចថ្មីឱ្យបានជ័យជម្នះលោតផ្លោះ បក្សបានសម្រេចពង្រីកសហករណ៍ឱ្យមានទំហំធំទូលាយជាងមុន។ កាលមុនរំដោះ យើងចាត់តាំងសហករណ៍ជាក្រុមៗ។ មួយក្រុមមាន១៥, ២០, ៣០គ្រួសារតាមសភាពការណ៍ជាក់ស្តែងដើម្បីស្រួលក្នុងការដឹកនាំ។ តែឥឡូវនេះ ដើម្បីជំរុញចលនាផលិតកម្មឱ្យខ្លាំងថែមទៀត បក្សបានសម្រេចចាត់តាំងសហករណ៍ជាសហករណ៍ភូមិ"។

[០៩:០៦:៥៦]

ខ្ញុំសូមរំលងឃ្លាមួយចំនួន ហើយខ្ញុំចូលទៅឃ្លាមួយផ្សេងទៀត "កាលសហករណ៍នៅចាត់តាំងជាក្រុម២០ៗ -- ១០, ២០, ៣០គ្រួសារនៅឡើយ តួនាទីរបស់សហករណ៍ក្នុងការជួយពង្រឹងរដ្ឋអំណាចបដិវត្តន៍នៅតាមភូមិមានក្របខ័ណ្ឌចង្អៀត។ ការតស៊ូវណ្ណៈក៏មាននៅក្នុងក្របខ័ណ្ឌជាក្រុមតូចៗ ការតស៊ូកម្ចាត់ពួកសន្តិសម្ព័ន្ធចារកម្មក៏មិនបានធំទូលាយ។ ក្រោយពីបានចាត់តាំងសហករណ៍តាមភូមិវិញ សហ-ករណ៍ដើរតួនាទីសំខាន់ក្នុងការរួមកម្លាំងពង្រឹងរដ្ឋអំណាចភូមិលើគ្រប់ផ្នែក។ សមូហជនក្នុងសហករណ៍ពិសេសកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោមដែលជាសមាជិកសហករណ៍ បានពង្រឹងឋានៈខ្លួនជាម្ចាស់ភូមិ ម្ចាស់ឃុំ ពិតប្រាកដ"។ សូមបញ្ចប់ការដកស្រង់។

ឯកសារបន្ទាប់ទៅទៀត គឺឯកសារ E3/729 ដែលជាទស្សនាវដ្តីយុវជន យុវនារីបដិវត្តន៍ចុះខែតុលា ឆ្នាំ១៩៧៥។ ការបកប្រែជាភាសាបារាំងនោះមិនល្អទេ។ ដូច្នេះ ខ្ញុំសូមអានជាភាសាអង់គ្លេសវិញ។ សម្រង់នេះនៅទំព័រជាភាសាខ្មែរគឺ 00063400 ទៅដល់ 01, ជាភាសាអង់គ្លេស 00357903, ជាភាសាបារាំង 00364224។ ចំណងជើងជាភាសាអង់គ្លេសគឺថា៖ វិធីសាស្ត្រសម្រាប់យុវជនកម្ពុជា និងរបៀបធ្វើការរបស់ពួកគេ ដើម្បីពង្រឹង និងពង្រីកផលិតផលនៅក្នុងនៅតាមសហករណ៍។

[០៩:០៨:១៩]

ខ្ញុំសូមដកស្រង់៖ "ក្រោយរំដោះទូទាំងប្រទេស ប្រជាជនកម្ពុជា៩៩,៩ភាគរយ ត្រូវទៅរស់នៅជនបទទាំងអស់ ដើម្បីចូលរួមចលនាបង្កបង្កើនផល ឧបត្ថម្ភខ្លួន និងរួមចំណែកការពារ និងកសាងប្រទេស។ ក្នុងរយៈពេលដំបូងនេះសហករណ៍ផលិតកម្មដែលមាននៅទូទាំងប្រទេស ដែលមិនបាច់ធានាដល់ការខ្វះខាតសព្វបែបយ៉ាងជាបណ្តោះអាសន្ន។ សហករណ៍ផលិតកម្មយើងទទួលរ៉ាប់រងទុក្ខទាំងនេះ

ហើយ ហើយមានលទ្ធភាពនិងសមត្ថភាពដោះស្រាយបញ្ហាទាំងអស់ឲ្យបានជោគជ័យ ដើម្បីដោះស្រាយបញ្ហាប្រជាជនជាង២លាននាក់ឲ្យបានសុខដុម និងរៀបរយទៀតផង។ ក្នុងសភាពការណ៍ស្មុគស្មាញដែលប្រជាជនថ្មីជាង២លាននាក់ទើបចុះទៅរស់នៅក្នុងជនបទ ភ្នាក់ងារខ្មាំងនិងសមត្ថភាពមិនល្អផ្សេងទៀតនៅលាយឡំច្របូកច្របល់នៅក្នុងជួរប្រជាជនថ្មីនេះដែរ។ សហករណ៍ផលិតកម្មយើងមានតួនាទីពង្រឹងរដ្ឋអំណាចតាមភូមិ ឃុំផង ជួយរក្សាការពារសន្តិសុខដល់ប្រជាជនថ្មី ក៏ដូចជាការរក្សារបៀបរៀបរយនៅតាមមូលដ្ឋានភូមិឃុំផងដែរ"។ បញ្ចប់ការដកស្រង់។

ហើយនៅទំព័របន្ទាប់ គឺសូមដកស្រង់ដូចតទៅ៖ "នៅក្នុងសហករណ៍មានការប្រយុទ្ធវណ្ណៈ និងការដោះស្រាយទំនាស់វណ្ណៈជាប់ជានិច្ចដែរ។ ហេតុដូច្នេះនៅក្នុងសហករណ៍គ្មានបាតុភាព សន្តិភាពនិយម គ្មានបាតុភាពភ្លើតភ្លើន ហ៊ឺហា សម្បូរបែប គ្មានបាតុភាពខ្ជះខ្ជាយ គ្មានបាតុភាពសេរី ដោយសារមានការគ្រប់គ្រងការធ្វើដំណើរ ហើយយើងត្រូវប្រយុទ្ធជាប់ ត្រូវដោះស្រាយជាប់។ ក្រៅពីនេះនៅក្នុងសហករណ៍មានការចាត់តាំងត្រឹមត្រូវ និងច្បាស់លាស់ មានអង្គការវិន័យរឹងប៉ឹង និងហ្មត់ចត់មានការប្រជុំជីវភាព ធ្វើទិះតៀន ស្វ័យទិះតៀនទៀងទាត់ មានការប្រជុំរៀនសូត្រនយោបាយជាប្រចាំនិងវប្បធម៌ជាប់លាប់នៅគ្រប់ពេលវេលា។" បញ្ចប់ការដកស្រង់។

[០៩:១១:០២]

ឯកសារបន្តទៅទៀតនោះ គឺឯកសារ E3/11 ជាទស្សនាវដ្តីទង់បដិវត្តចុះខែកញ្ញា ឆ្នាំ១៩៧៧ គឺជាសុន្ទរកថារបស់ ប៉ុល ពត ក្នុងឱកាសខួបបក្សលើកទី១៧ គឺនៅក្នុងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៧។

ខ្ញុំសូមបញ្ជាក់ថាឯកសារនេះមានលេខកូដមួយទៀតដែលជាឯកសារដដែល ដែលមានសុន្ទរកថារបស់ប៉ុល ពត នេះគឺថា E3/144 ដែលឯកសារនេះត្រូវបានចុះផ្សាយនៅឆ្នាំ១៩៧៨ ដោយក្រសួងការបរទេស។ នៅក្នុងឯកសារនេះ ប៉ុល ពត បានធ្វើតារាងដ៏អស្ចារ្យនៃជោគជ័យ នៃគោលនយោបាយសមូហភាពភាវូបនីយកម្មនិងការងារនៅសហករណ៍។ ខ្ញុំសូមអានឯកសារជាភាសាខ្មែរគឺ00063174, ជាភាសាបារាំងគឺ 00492846, ជាភាសាអង់គ្លេសគឺ 00486256។ ខ្ញុំសូមដកស្រង់នូវសម្តីរបស់ប៉ុល ពត៖ "បច្ចុប្បន្ននេះសហករណ៍យើងប្រែក្លាយជនបទកម្ពុជាដ៏ក្រៀមក្រោះ អត្តខាត់ ពេលជំនាន់មុននេះមកជាជនបទកាន់តែមានសម្រស់ឡើង មានអាងទឹកធំតូច មានព្រែកជីក ប្រឡាយខ្វាត់ខ្វែង មានស្រែចម្ការខៀវស្រងាត់។ល។ ហើយសហករណ៍នេះទៅជាសហករណ៍សង្គមសមូហភាពតូចមួយ។ (បន្ទាប់មកទៀត) គឺសហករណ៍យើងក៏បានពង្រឹងខាងទំហំផងដែរ។ ហើយពង្រឹងពង្រីកសង្គមសមូហ

ភាពថ្មីស្អាតស្អំស្មើភាពសុខដុម និងមានជីវភាពរស់នៅគ្រប់គ្រាន់ទាំងស្បៀងអាហារ ទាំងសុខភាពអនាម័យ ទាំងវប្បធម៌សិក្សាអប់រំ។ មកដល់ថ្ងៃនេះអង្គភាពសហករណ៍យើងក៏បានពង្រីកខាងទំហំផងដែរ។ គិតជាមធ្យមនៅជនបទយើងទូទាំងប្រទេសមានសហករណ៍ចំនួន៥០% ដែលមានពី៧០០ ទៅ ១០០០គ្រួសារ។ មានសហករណ៍ចំនួន៣០% ពី៤០០ ទៅ៦០០គ្រួសារ។ មានសហករណ៍ចំនួន២០% ពី១០០ ទៅ៣០០គ្រួសារ។ គឺថាជាទូទៅសហករណ៍យើងជាសហករណ៍ឃុំហើយ នៅសល់មួយចំនួនតិចទេដែលមានសហករណ៍ឃុំនៅឡើយ"។ សូមបញ្ចប់ការដកស្រង់។

[០៩:១៣:៥៣]

ដូច្នេះយើងបាននិយាយអំពីសហករណ៍ក្រុម ទៅជាសហករណ៍ឃុំ ហើយឥឡូវយើងចេញមកដល់សហករណ៍ឃុំ។ នៅក្នុងអត្ថបទដដែលនេះ ប៉ុល ពត និយាយអំពីលទ្ធភាពដែលសហករណ៍ធ្វើការងារធំៗនិងធ្វើការដ្ឋាន។ ខ្ញុំសូមដកស្រង់ទំព័រជាភាសាខ្មែរគឺ 00063181, ជាភាសាបារាំង 00492851, ជាភាសាអង់គ្លេស 00486260 ទៅដល់ 61។

ប៉ុល ពត បាននិយាយថា៖ "ក្នុងជាងមួយរដូវប្រាំង ១៩៧៧ កន្លងទៅប្រជាជនសហករណ៍យើងបានកសាងអាងទឹកធុនធំនៅតាមភូមិនីមួយៗ អាងធំមធ្យមចំណុះពី៥០លាន ទៅ៦០លានម៉ែត្រគុណនីមួយៗ។ នៅតំបន់នីមួយៗ អាងធុនតូចមាននៅតាមស្រុកនីមួយៗ ព្រមទាំងជីក ព្រែកជីរាប់រយគីឡូម៉ែត្ររួចហើយ។ ប្រជាជនសហករណ៍យើងបានធ្វើទំនប់ស្ទឹងព្រែកត្នោតប្រាំកន្លែង ទំនប់ស្ទឹងជំនិតពីរកន្លែង ទំនប់ទឹកពោធិសាត់បីកន្លែង ទំនប់ស្ទឹងបាត់ដំបងមួយកន្លែង...។ល។ ដើម្បីធ្វើទាំងអស់នេះគឺប្រជាជនកម្មករ កសិករយើងធ្វើដោយខ្លួនទីពឹងខ្លួនទាំងស្រុង ដោយដៃនិងចបរបស់ខ្លួន"។ សូមបញ្ចប់ការដកស្រង់។

[០៩:១៥:៣៣]

ឯកសារសំខាន់មួយទៀតគឺឯកសារ E3/748 ជាទស្សនាវដ្តីទង់បដិវត្តន៍ខែតុលា វិច្ឆិកា ឆ្នាំ ១៩៧៥។ ឯកសារនេះពន្យល់អំពីភារកិច្ចរបស់សហករណ៍ ជាពិសេសពាក់ព័ន្ធទៅនឹងសន្តិសុខ និងការស្វែងរកខ្លាំង។ ឯកសារពាក់ព័ន្ធ -- អត្ថបទពាក់ព័ន្ធគឺអត្ថបទទី៥ ដែលមានចំណងជើងថា "ពង្រឹងនិងពង្រីកសហករណ៍ផលិតកម្មរបស់បក្សឲ្យកាន់តែខ្លាំងក្លាថែមទៀត ដើម្បីធ្វើជាកម្លាំងស្នូលសម្រេច៣តោនក្នុង១ហិកតាសម្រាប់ឆ្នាំ១៩៧៦"។ អត្ថបទសម្រង់នោះ គឺនៅទំព័រជាភាសាខ្មែរ 00063268 រហូតទៅដល់ 69, ជាភាសាបារាំងគឺ 00499710 ទៅដល់ 11, ជាភាសាអង់គ្លេសគឺ 00495826 ។

"១) ធាតុពិតនិងសំណូមពរបច្ចុប្បន្ននិងអនាគតនៃសហករណ៍ផលិតកម្ម។ សហករណ៍ជាអង្គការផលិតកម្មមានធាតុពិតវណ្ណៈ។ (ចុះមកក្រោមបន្តិច) ដូច្នេះសហករណ៍នេះវាធ្វើការតស៊ូប្រជាជាតិនិងតស៊ូវណ្ណៈជាបន្តបន្ទាប់។ យើងត្រូវពង្រឹងពង្រីកសហករណ៍ទៅតាមសំណូមពរនេះ ទៅតាមធាតុពិតនេះឲ្យជាប់"។

នៅទំព័រដដែលគឺលេខពីរធំ(II) ភារកិច្ចបដិវត្តន៍គ្រប់ផ្នែករបស់សហករណ៍ផលិតកម្មរបស់បក្ស។ យើងឃើញមានភារកិច្ចប្រាំមួយសំខាន់ យើងខ្ញុំសូមដកស្រង់តែបួនទេ។

ទី១៖ សហករណ៍ប្រមូលកម្លាំងប្រជាកសិករមូលដ្ឋានដើម្បីបង្កបង្កើនផលគ្រប់ផ្នែក។ (ខ្ញុំសូមរំលងពីរ, បី) ចូលទៅដល់ចំណុចទី៤៖ វាដោះស្រាយបញ្ហាពាណិជ្ជកម្មដោយដោះដូរផលិតផលសម្រាប់សហករណ៍។ ចំណុចទី៥៖ វាបំពេញភារកិច្ចខាងយោធារក្សាសន្តិសុខនិងការពារប្រទេស។ ចំណុចទី៦៖ វាគិតគូរបំពាក់បំប៉នខាងនយោបាយសតិអារម្មណ៍បដិវត្តន៍អនុវត្តមាគ៌ាចាត់តាំងរបស់បក្សក្នុងសហករណ៍ ។ល។" សូមបញ្ចប់ការដកស្រង់។

ឯកសារបន្ទាប់មកទៀតគឺឯកសារ E3/273--

**ប្រធានអង្គជំនុំ៖**

ឈប់សិនផ្អាកបន្តិចលោកតំណាងសហព្រះរាជអាជ្ញា។ សូមអញ្ជើញលោកស្រីមេធាវី។

[០៩:១៨:៥៨]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់។ ជម្រាបសួរអង្គជំនុំជម្រះ។ ខ្ញុំសូមអន្តរាគមន៍នៅក្នុងដំណាក់កាលនេះដោយយោងទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះកាលពីម្សិលមិញនេះ យើងគិតថាយើងមិនគួរណាលើកឡើងឯកសារពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយនោះទេ។ ដូច្នេះ ខ្ញុំស្ដាប់សហព្រះរាជអាជ្ញាតាំងពីព្រឹកមកហើយ ខ្ញុំស្ដាប់ទៅឃើញតែពីការនិយាយអំពីការអនុវត្តគោលនយោបាយពាក់ព័ន្ធទៅនឹងសហករណ៍។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅនឹងការបន្តបង្ហាញឯកសាររបៀបនេះ ដែលចំពោះខ្ញុំ ខ្ញុំគិតថាវាងាកចេញអំពីក្របខ័ណ្ឌនៃវិសាលភាពសំណុំរឿង ០០២/០១ហើយលោកប្រធាន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានខ្ញុំសូមឆ្លើយតប។

ឯកសារដែលខ្ញុំបង្ហាញនោះ គឺចេញមកពីមជ្ឈិមបក្ស។ ឯកសារទាំងអស់នេះបង្ហាញអំពីការអភិវឌ្ឍន៍នៃគោលនយោបាយពាក់ព័ន្ធនឹងសហករណ៍។ នេះមិនមែនជាគោលនយោបាយនៅឆ្នាំ១៩៧៣ គឺវាមានការវិវត្ត យើងឃើញថាវាមានការវិវត្តពីសហករណ៍ទំហំតូចមកដល់សហករណ៍ថ្នាក់ឃុំ។ ដូច្នេះ ឯកសារទាំងអស់នេះបង្ហាញអំពីនយោបាយរបស់មជ្ឈិមបក្ស និងមេដឹកនាំពាក់ព័ន្ធទៅនឹងសហករណ៍។ ដូច្នេះ ខ្ញុំមិនបាននិយាយពាក់ព័ន្ធនឹងការអនុវត្តនៅមូលដ្ឋាននោះទេ។ គឺនៅក្នុងទស្សនាវដ្ដីទង់បដិវត្តនោះ គឺមានបង្ហាញអំពីគោលជំហរផ្លូវការរបស់មជ្ឈិមបក្ស ពាក់ព័ន្ធទៅនឹងគោលនយោបាយស្ដីពីសហករណ៍ ជួនកាលវាអាចមានទិដ្ឋភាពអនុវត្ត ក៏ប៉ុន្តែវានៅតែជាសេចក្ដីណែនាំ និងគោលនយោបាយជាក់ស្ដែងរបស់មជ្ឈិមបក្ស។ សូមអរគុណលោកប្រធាន។

[០៩:២០:៥៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២២:១០]

**ប្រធានអង្គជំនុំ៖**

បាទ សូមប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបញ្ជាក់ទៅលើសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក ខៀវ សំផន ដែលជំទាស់ទៅនឹងការដាក់បង្ហាញនូវឯកសារគន្លឹះរបស់ភាគីសហព្រះរាជអាជ្ញា។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

អង្គជំនុំជម្រះយល់ឃើញថា ឯកសារដែលបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញានោះ គឺពាក់ព័ន្ធទៅនឹងសេចក្ដីណែនាំដែលត្រូវអនុវត្តនៅក្នុងក្របខ័ណ្ឌគោលនយោបាយសហករណ៍ ហើយសេចក្ដីណែនាំនោះត្រូវបានធ្វើឡើងដោយមជ្ឈិមបក្ស។ ដូច្នេះនេះមិនមែនជាការអនុវត្តនៅតាមមូលដ្ឋាននោះទេ។ ហើយការអនុវត្តនៅមូលដ្ឋាននោះ គឺវាមិនត្រូវស្ថិតនៅក្នុងឯកសារគន្លឹះនៃការបង្ហាញឯកសារនៅក្នុងសវនាការនេះទេ។ ដូច្នេះ ការជំទាស់របស់មេធាវីការពារក្ដីមិនមានប្រសិទ្ធភាពនោះទេ។

[០៩:២៣:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៣:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តទៀត!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។

ឥឡូវនេះ ខ្ញុំនិយាយអំពីឯកសារ E3/273 ឯកសារនេះជាអត្ថបទបោះពុម្ពផ្សាយរបស់ហ្វីប៊ីស ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦។ អត្ថបទដកស្រង់ដោយខ្ញុំនឹងអាននោះ គឺជារបាយការណ៍របស់ឧបនាយករដ្ឋមន្ត្រី គឺលោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មី។ របាយការណ៍នេះត្រូវបានបង្ហាញនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ ក្នុងឱកាសសមាជជាតិលោកទី៣ ដែលប្រព្រឹត្តឡើងនៅទីក្រុងភ្នំពេញ។ ខៀវ សំផន បាននិយាយអំពីគោលនយោបាយនៃសម្ហភាវូបនីយកម្ម នេះ គឺជាគោលនយោបាយ។ ជាភាសាខ្មែរគឺ ERN 00657443, ជាភាសាបារាំងគឺ 00725798, ជាភាសាអង់គ្លេស 00167813។ លោក ខៀវ សំផន ធ្វើបទអត្ថាធិប្បាយដូចតទៅ ខ្ញុំសូមដកស្រង់ "យោងតាមមាត្រា២នៃជំពូកពីរ រាល់មធ្យោបាយបង្កបង្កើនផលទាំងអស់ គឺជាទ្រព្យសម្ហភាព។ ទ្រព្យទាំងនេះត្រូវស្ថិតក្រោមការគ្រប់គ្រងនិងត្រួតត្រាដោយផ្ទាល់សមមិត្តកម្មករ កសិករ យើងដោយខ្លួនឯង។ កម្មសិទ្ធរួមគឺជាមូលដ្ឋាននៃសិទ្ធិ និងសេរីភាពរបស់ប្រជាជនយើង"។

[០៩:២៥:៣៦]

ចុះក្រោមមកបន្តិចមក "មានការដ្ឋានជាច្រើននៅគ្រប់ទីកន្លែង ដែលប្រជាជនយើងកំពុងខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីបង្កបង្កើនផល ស្ថាបនា និងធ្វើឲ្យរោងចក្រទាំងឡាយមានភាពប្រសើរឡើង កសាងឧស្សាហ៍កម្ម និងជំរុញការបង្កបង្កើនផលកសិកម្ម ព្រមទាំងប្រែក្លាយទស្សនវិស័យនៅតាមជនបទ"។ សូមបញ្ចប់ការដកស្រង់។

ឃ្លាមួយទៀតនេះគឺនៅទំព័រជាភាសាបារាំងគឺ 006570 -- សូមទោស! ខ្មែរគឺ 00657446 ទៅដល់ 48, ជាភាសាបារាំងគឺ 00725800 ទៅដល់ 01, ជាភាសាអង់គ្លេសគឺ 00167814 ទៅដល់ 15។ នេះជាសម្តីលោក ខៀវ សំផន នៅជំពូក១៩ មាត្រា១២។ ខៀវ សំផន និយាយថា "គ្រប់គ្នាធ្វើការនៅតាមស្រែចម្ការ ពីព្រោះកម្មករយើងអនុវត្តប្រព័ន្ធការងារសម្ហភាព និងដោយសារពួកគេជាម្ចាស់រោងចក្ររួម ម្ចាស់រថភ្លើងរួម និងម្ចាស់ការដ្ឋានបង្កបង្កើនផលទាំងអស់។ នេះគឺជាការពិតជាក់ស្តែងមួយទៀតដែលគេអាចមើលឃើញនៅប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ។ កសិករគ្រប់រូបគឺជាម្ចាស់ដីធ្លី ដែល

ខ្លួនភ្លួររាស់"។

ខ្ញុំសូមរំលងឃ្លាមួយចំនួនដើម្បីចូលទៅដល់មាត្រា១៣។ ខៀវ សំផន បាននិយាយថា៖ "មាត្រា ១៣ នៃជំពូកទី៩ សង្កត់ធ្ងន់ថា ត្រូវផ្តល់សមភាពពេញលេញឲ្យប្រជាជនកម្ពុជាទាំងអស់។ នេះឆ្លុះបញ្ចាំងពីការពិតជាក់ស្តែងមួយទៀតនៃសង្គមយើង។ បច្ចុប្បន្ននេះ យើងទាំងអស់គ្នាមានភាពស្មើគ្នា គ្មានវណ្ណៈអ្នកមាន គ្មានវណ្ណៈអ្នកក្រ គ្រប់គ្នាធ្វើការទាំងនៅតាមស្រែចម្ការ ឬក៏រោងចក្រ"។ សូមបញ្ចប់ការដកស្រង់។

[០៩:២៧:៣៥]

ឥឡូវនេះ ខ្ញុំចូលទៅដល់ឯកសារ E3/50 ដែលជាអត្ថបទរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមានចំណងជើងថា "រំឭកខួបឆ្នាំទី៣នៃការចាត់តាំងសហករណ៍ កសិករ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ ១៩៧៦"។ ឯកសារនេះបង្ហាញអំពីតួនាទីដ៏សំខាន់របស់សហករណ៍ក្នុងការតស៊ូប្រយុទ្ធប្រឆាំងនឹងខ្មាំងនៅក្នុងការត្រួតពិនិត្យរបស់របបទៅលើប្រជាជននៅក្នុងសហករណ៍។

សម្រង់ទី១ជាភាសាខ្មែរគឺ 00442214, ជាភាសាបារាំង 00623787, ជាភាសាអង់គ្លេស 00636014។ គឺនៅចំណងជើងលេខ៧ ខ្ញុំសូមដកស្រង់ "ដោយសារសហករណ៍ ខ្មាំងស្ថិតនៅជាសភាពចោរព្រៃ។ បក្សក្តាប់ប្រជាជនបាន កសាងកងទ័ពបាន កសាងសេដ្ឋកិច្ចបាន បម្រើសមរភូមិនបាន វាយខ្មាំងខ្លាំងក្លា។ មកពីកន្លែងណាក៏មានសហករណ៍ មានកម្លាំងសម្ព័ន្ធភាពកម្មករ កសិករក្រោមការដឹកនាំរបស់បក្ស"។ សូមបញ្ចប់ការដកស្រង់។

[០៩:២៨:២២]

បន្ទាប់ទៀតឯកសារនេះបង្ហាញអំពីទំនាក់ទំនងរវាងសហករណ៍ និងការជម្លៀសប្រជាជនចេញពីទីក្រុង និងពន្យល់អំពីសារៈសំខាន់នៃសហករណ៍ក្នុងការតស៊ូវណ្ណៈ ការតស៊ូប្រឆាំងនឹងខ្មាំង និងការតស៊ូប្រឆាំងនឹងកម្មសិទ្ធិឯកជន។

សម្រង់មួយទៀត គឺនៅទំព័រជាភាសាខ្មែរគឺ 00442217, ជាភាសាបារាំងគឺ 00623789, ជាភាសាអង់គ្លេស 00636015 ទៅដល់ 16។ ខ្ញុំសូមដកស្រង់ "ដល់ក្រោយរំដោះយើងជម្លៀសប្រជាជនចេញអស់ពីទីក្រុងភ្នំពេញ និងទីរួមខេត្តដែលទើបរំដោះថ្មីទាំងអស់ទៀត យើងវាយរំដោះផ្សារផ្សោ"។ ចុះមកក្រោមកបន្តិចមក "នេះគឺជាការបញ្ចប់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យទាំងស្រុង និងជាស្ពាពរផង ជាការបន្តបដិវត្តន៍សង្គមនិយមផង។ យើងធ្វើទាំងនេះបានមកពីយើងមានមូលដ្ឋានបដិវត្តន៍សង្គមនិយម

នៅតំបន់រំដោះ ពិសេសមានសហករណ៍ កសិករ។ គ្មានសហករណ៍នៅជនបទ យើងមិនអាចធ្វើយ៉ាងនេះបានជាដាច់ខាត”។ សូមបញ្ចប់ការដកស្រង់។

[០៩:៣០:៥៨]

អត្ថបទដកស្រង់មួយទៀតនោះ គឺនៅទំព័រជាភាសាខ្មែរ 00442220, ជាភាសាបារាំងគឺ 0062 3791 ទៅដល់ 91, ជាភាសាអង់គ្លេសគឺ 00636018 ទៅដល់ 19។ ខ្ញុំសូមដកស្រង់ “បក្សត្រូវក្តាប់និងដឹកនាំសហករណ៍គ្រប់មុខគ្រប់ផ្នែកទាំងអស់ តាមរយៈបក្ខជន និងសម្ព័ន្ធយុវកក ជនបង្គោលដែលមាននៅក្នុងសហករណ៍”។ សូមរំលងពីរបីបន្ទាត់មកក្រោមទៀត “បើមិនដូច្នោះទេមុខជាកសិករ និងកសិករលើ កសិករមាន និងវណ្ណៈដទៃទៀតដណ្តើមនាទីដឹកនាំក្នុងសហករណ៍បាន”។ សូមបញ្ចប់ការដកស្រង់។

ឯកសារបន្តទៅទៀតនេះ គឺឯកសារ E3/10 គឺជាទស្សនាវដ្តីទងបដិវត្ត ចុះខែកញ្ញា តុលា ឆ្នាំ ១៩៧៦។ អត្ថបទទី១ នោះមានចំណងជើងថា៖ “សេចក្តីដកស្រង់បទឧទ្ទេសនាមរបស់សមមិត្តតំណាងបក្ស ក្នុងឱកាសពិធីបុណ្យរំឭកខួបឆ្នាំទី១៦ ដ៏មហាជោគជ័យនៃកំណើតបក្សកុម្មុយនីស្តកម្ពុជា”។ យើងឃើញថាអត្ថបទនេះប្រហែលជាថ្លែងដោយ ប៉ុល ពត។

សម្រង់ទី១ នោះគឺនៅទំព័រជាភាសាខ្មែរ 00063069, ជាភាសាបារាំង 00491876, ជាភាសាអង់គ្លេស 00450509។ ខ្ញុំសូមដកស្រង់ “សង្គមកម្ពុជាបច្ចុប្បន្នមានវណ្ណៈតែពីរទេគឺ វណ្ណៈកម្មករ និងវណ្ណៈកសិករ។ សមមិត្តទាំងឡាយដែលមានធាតុដើមជាអនុធន បញ្ញាជន អ្នកបច្ចេកទេស បើរស់នៅក្នុងក្របខ័ណ្ឌណាត្រូវបញ្ចូលខ្លួនទៅក្នុងក្របខ័ណ្ឌនៃវណ្ណៈនោះ។ ឧទាហរណ៍ បើរស់នៅ ឬធ្វើការជាមួយកម្មករត្រូវចូលក្នុងជួរវណ្ណៈកម្មករ បើធ្វើការនៅជនបទក្នុងសហករណ៍ត្រូវចូលខ្លួនទៅជាកសិករ។ យើងមិនទុកឲ្យបញ្ញាជននៅជាស្រទាប់ដោយឡែកទេ”។ សូមបញ្ចប់ការដកស្រង់។

[០៩:៣៤:២២]

នៅក្នុងទស្សនាវដ្តីដដែលនេះមានអត្ថបទទី២មួយទៀត ដែលជាសុន្ទរកថារបស់ ប៉ុល ពត ផងដែរ។ អត្ថបទនេះមានចំណងជើងថា “សម្រួចសតិអារម្មណ៍នៃវណ្ណៈអធនឲ្យមុតស្រួច និងខ្លាំងក្លាបំផុត”។ នៅក្នុងអត្ថបទនេះគឺយើងនិយាយអំពីអង្គការវិន័យ និងចង្វាក់ការងារនៅក្នុងសហករណ៍ និងរោងចក្រ។ ឯកសារនេះមានភាពពាក់ព័ន្ធដោយសារថា បក្សមិនដែលភ្ជាប់ភាពខុសគ្នានៃចង្វាក់ការងារទៅនឹងសមត្ថភាពតាមផ្លូវរាងកាយនោះទេ ក៏ប៉ុន្តែគឺថាភាពជាសមាជិកទៅនឹងបដិវត្តន៍សង្គមនិយម។ ជាភាសាខ្មែរគឺ 00063086, ជាភាសាបារាំង គឺ 00491889, ជាភាសាអង់គ្លេសគឺ 00450522។

ខ្ញុំសូមដកស្រង់៖ "ពីរឿងយឺតយ៉ាវខ្លាំងក្លា ឬមិនខ្លាំងក្លានៅក្នុងបក្ស នៅក្នុងមន្ទីរ នៅក្នុងរោងចក្រ នៅក្នុងសហករណ៍ អ្នកខ្លះក៏ស្មុះស្មាញខ្លាំង អ្នកខ្លះក៏ស្មុះស្មាញល្មម អ្នកខ្លះវាហី អ្នកខ្លះខ្ជិល"។ សូមរំលងបន្តិចមកក្រោមបន្តិច "ឯអ្នកវាហី គឺមកពីភ្លើងបដិវត្តន៍សង្គមនិយមវាមិនខ្លាំង"។ ចុះខាងក្រោមបន្តិចមកមានឧទាហរណ៍ "បើធ្វើស្រូវបានតែ១តោនកន្លះ មិនបាន៣តោនមួយហិកតា គឺប៉ះពាល់កិច្ចការពារប្រទេស និងកិច្ចកសាងប្រទេស"។ សូមបញ្ចប់ការដកស្រង់។

[០៩:៣៦:៣៦]

នៅក្នុងឯកសារដដែលនេះដែរ គឺថាមានទំនាក់ទំនងរវាងការបង្កើត និងដំណើរការសហករណ៍ និងការជម្លៀសប្រជាជនចេញពីទីក្រុង ក៏ដូចជាការតស៊ូវណ្ណៈ។ នៅទំព័រជាភាសាខ្មែរគឺ 00063095, ជាភាសាបារាំងគឺ 00491897, ជាភាសាអង់គ្លេស 00450531។ ខ្ញុំសូមដកស្រង់៖ "ឯងយើងវិញ យើងមានតស៊ូវណ្ណៈទេ? យើងតស៊ូវណ្ណៈ។ យើងជម្លៀសប្រជាជនចេញពីទីក្រុង គឺយើងតស៊ូវណ្ណៈ។ យើងពង្រឹងពង្រីកសហករណ៍ជាការតស៊ូវណ្ណៈ ដើម្បីវាយកម្ទាយនូវកម្លាំងរបស់នាយទុនសក្តិភូមិ"។ សូមបញ្ចប់ការដកស្រង់។

នៅក្នុងឯកសារដដែល គឺឯកសារ E3/10 នៅក្នុងអត្ថបទហ្នឹង គឺបក្សបានបញ្ជាក់ថា នៅក្នុងសហករណ៍មានឋានៈខុសគ្នារវាងសកិករ និងកម្មករ ហើយនិងរវាងពួកសក្តិភូមិ និងនាយទុន ហើយនិងមានការរឹតត្បិត ហើយនិងមានការតាមដាន។ គឺយើងអាចមើលឃើញនៅទំព័រជាភាសាខ្មែរគឺ 0006 3096, ជាភាសាបារាំងគឺ 00491898, ជាភាសាអង់គ្លេស 00450531។ ខ្ញុំសូមដកស្រង់៖ "ត្រូវឱ្យសេរីភាពទៅប្រជាជនកម្មករ កសិករ។ ចំពោះពួកសក្តិភូមិ នាយទុន ត្រូវមានក្របខ័ណ្ឌចង្អៀត។ សេរីភាពត្រូវឱ្យទៅអ្នកណា ហើយមិនឱ្យទៅអ្នកណា។ ត្រូវច្បាស់លាស់។ ប្រយ័ត្នកុំឱ្យពួកសក្តិភូមិម្ចាស់ដី វាដើរហើរវែងឆ្ងាយហូរហែ ដូចជាទៅរកអំបិល ទៅរកឫសឈើធ្វើថ្នាំ ទៅឃ្វាលគោ ពួកនេះបើវាដើរហូរហែ វាទាក់ទងគ្នា។ ត្រូវអប់រំសហករណ៍យើងឱ្យប្រុងប្រយ័ត្នចំពោះពួកនេះ"។ សូមបញ្ចប់ការដកស្រង់។

[០៩:៣៩:៤២]

ឃ្លាចុងក្រោយនៃឯកសារដដែលនេះ គឺឯកសារ E3/10 គឺនៅទំព័រជាភាសាខ្មែរគឺ 00063101, ជាភាសាបារាំងគឺ 00491902, ជាភាសាអង់គ្លេសគឺ 00450535។ សូមដកស្រង់ "បើអត់សហករណ៍ធាតុពិតបដិវត្តន៍ក៏អស់។ ធាតុពិតចក្រពត្តិវាមកវិញ សេរីវាមកវិញ។ មានផ្សារ មានទីក្រុង គឺច្របូក

ច្របល់ យើងនឹងក្លាយជាខ្ញុំគេ"។ សូមបញ្ចប់ការដកស្រង់។

ឯកសារបន្តទៅទៀត គឺឯកសារ E3/86 ឯកសារនេះគឺសរសេរដោយមជ្ឈមណ្ឌលស្រាវជ្រាវ ស្រាវជ្រាវ និងឯកសារនៃចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យដែលមានលោក អៀង សារី ជាប្រធាន មានចំណងជើងថា "ការពិតអំពីរបបផ្ដាច់ការរបស់ ប៉ុល ពត ឆ្នាំ១៩៧៥ ទៅដល់ ឆ្នាំ១៩៧៨"។ ឯកសារនេះចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៩៦។ ហើយ អៀង សារី គាត់និយាយអំពីបញ្ហានេះការបែងចែកប្រជាជននៅតាមជនបទ។ ជាភាសាខ្មែរគឺ 00224434, ជាភាសបារាំង 00614098 ជាភាសាអង់គ្លេសគឺ00081219។

[០៩:៤១:៥៧]

ខ្ញុំសូមដកស្រង់ "ប៉ុល ពត បានចែកប្រជាជនខ្មែរទាំងមូលជាពីរប្រភេទ។ ប្រជាជនមូលដ្ឋានគឺអ្នកដែលបានចូលរួមក្នុងការតស៊ូ ហើយដែលកំពុងរស់នៅជាសហករណ៍។ រីឯប្រជាជនថ្មី ឬប្រជាជន១៧មេសា គឺអ្នកដែលត្រូវបានជម្លៀសពីទីក្រុងនានានៃខេត្ត ជាពិសេសពីភ្នំពេញ។ ប្រជាជនថ្មីត្រូវបានបញ្ជូនទៅការដ្ឋានផ្សេងៗនៅតាមជនបទ ដូចជាស្រែចម្ការ ការដ្ឋានសាងសង់ទំនប់ ការដ្ឋានសាងសង់ផ្លូវរថភ្លើងដើម្បីហ្វឹកហាត់ឲ្យចេះអត់ធន់ និងការរងទុក្ខលំបាកទាំងផ្លូវកាយ និងផ្លូវចិត្ត"។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំមិននិយាយអំពីអ្វីដែលលោកអៀង សារី លើកឡើងអំពីលក្ខខណ្ឌធ្វើការរបស់អ្នកទាំងអស់នោះទេ។

គណអចិន្ត្រៃយ៍ខ្លួនឯងនោះ ក៏ចាប់អារម្មណ៍ទៅលើតួនាទីរបស់សហករណ៍ ជាពិសេសទំនាក់ទំនងជាមួយថ្មី និងការជម្លៀសប្រជាជនដំណាក់កាលទី២។ មានសម្រង់នៃឯកសារ E3/216 ដែលសហភាតារបស់ខ្ញុំបានអានរួចមកហើយ ប៉ុន្តែនៅក្នុងបរិបទផ្សេង។ នេះគឺជាកំណត់ហេតុអំពីទស្សនកិច្ចរបស់អចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យនៅថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៥។ ខ្ញុំសូមអានសម្រង់ពីរចេញពីឯកសារនេះ។

[០៩:៤៣:២៥]

គឺសម្រង់ទី១ គឺនៅទំព័រជាភាសាខ្មែរគឺ 00008488 ទៅដល់ 89, ជាភាសាបារាំងគឺ 0034 3376 រហូតទៅដល់ 77, ជាភាសាអង់គ្លេស 00850975 ទៅដល់ 76។ នៅត្រង់ផ្នែកមតិណែនាំរបស់អង្គការ។ ខ្ញុំសូមដកស្រង់ "ដាក់ស្ដែងគឺត្រូវពង្រឹងពង្រីកសហករណ៍ យកកម្លាំងសហករណ៍ធ្វើជាស្នូល ធ្វើឲ្យស្នូលនេះរឹងថែស សម្រាប់ស្រូបប្រជាជនថ្មី។ ប្រជាជនថ្មីត្រូវរណបសហករណ៍ទាំងនយោបាយ

ទាំងសេដ្ឋកិច្ច។ នេះជាទិសរបស់យើង។ ប្រជាជនរឹង លុះត្រាតែសហករណ៍រឹង"។ សូមបញ្ចប់ការដកស្រង់។

នៅទំព័របន្ទាប់មកទៀត គឺនៅត្រង់ចំណុចលេខ២ "តួនាទីក្រោយពេលរំដោះទាំងស្រុង។ សហ-ករណ៍ស្រូបប្រជាជនថ្មីចេញពីទីក្រុងទាំងអស់ ពិសេសក្រុងភ្នំពេញ ហើយនិងនៅពាយ័ព្យគឺបាត់ដំបង។ ប្រជាជនថ្មីរាប់សែននាក់នៅបាត់ដំបងមានសមាសភាពអាក្រក់គ្រប់យ៉ាង។ តែសហករណ៍ស្រូបយកអស់ ផ្គត់ផ្គង់ស្បៀង ព្រមទាំងចាត់ចែងកម្លាំងធ្វើការងារទៀត។ អានុភាពសហករណ៍ខ្លាំងក្លាណាស់។ ដូច្នេះបើសហករណ៍រឹងខ្លាំងចូលមិនចុះ វាដើរមិនបាន ធ្វើសកម្មភាពមិនបាន ចូលគេដឹង សុំបាយគេដឹង។ នៅភូមិភាគពាយ័ព្យជាបណ្ដោះអាសន្នយើងដោះស្រាយបាននៅខ្វះខាតខ្លះ ប្រជាជនចាស់មិនអីទេ។ តែប្រយ័ត្នសមាសភាពមិនល្អក្នុងប្រជាជនថ្មីវាឆ្លៀតឱកាស ព្រោះពួកអានេះបើទុកឲ្យ បើទុកជាឲ្យវាគ្រប់គ្រាន់ (ពីរកំប៉ុង) ក៏វាមិននៅដែរ"។ បាទពីរកំប៉ុងនេះ គឺមានន័យថាអង្ករពីរកំប៉ុងក្នុងមួយថ្ងៃ។

[០៩:៤៦:២៨]

មានកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ផ្សេងទៀតដែលពាក់ព័ន្ធ ដែលនិយាយអំពីបញ្ហាសហករណ៍ និងការដ្ឋាននោះ។ ឧទាហរណ៍គឺដូចជាឯកសារ E3/213 ដែលជាកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍អំពីគម្រោងផែនការ៤ឆ្នាំ កសាងសង្គមនិយម គ្រប់ផ្នែករបស់បក្ស គឺពីថ្ងៃទី២១ ខែកក្កដា ទៅដល់ថ្ងៃ០២ ខែសីហា ឆ្នាំ១៩៧៦។ ខ្ញុំសូមអានសម្រង់តែមួយទេដែលមាននៅក្នុងជាភាសាខ្មែរ គឺ 00075818 រហូតទៅដល់ 19, ជាភាសាបារាំង គឺ 00301196 ទៅដល់ 97, ជាភាសាអង់គ្លេសគឺ 00104020។ "ក) ការងាយស្រួល ទី១កត្តាសង្គម។ សង្គមយើងជាសង្គមសមូហភាពជាទូទៅ"។ រំលងបន្តិចមក "កម្លាំងផលិតកម្មទាំងអស់ក៏សមូហភាព យើងអាចចាត់ចែងកម្លាំងមនុស្សគោ ក្របីឧបករណ៍យ៉ាងម៉េចក៏បាន"។ ចុះក្រោមបន្តិចមក "ឯយើង យើងមានលក្ខណៈខុសគេ។ គឺមានន័យថាគេនិយាយអំពី ចិន កូរ៉េ និងវៀតណាម។ យើងលឿនជាងគេ បើពិនិត្យពីលក្ខណៈសមូហភាពពីរបបសង្គមនិយម យើងលឿនជាងគេ ៤ទៅ ១០ឆ្នាំ"។ សូមបញ្ចប់ការដកស្រង់។

[០៩:៤៨:២៤]

មានកំណត់ហេតុរបស់កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ផ្សេងទៀតដែលនិយាយអំពីការដ្ឋានឬជំរំការងារ តែខ្ញុំនឹងនិយាយអំពីនៅពេលក្រោយ។ ឯកសារបន្ទាប់ទៅនេះគឺឯកសារ E3/760 ឯកសារនេះក៏មានលេខ E3/761ផងដែរ។ នេះគឺទស្សនាវដ្ដីទង់បដិវត្តន៍ចុះខែមិថុនា ឆ្នាំ១៩៧៦ ដែលបានបោះពុម្ពផ្សាយ

សេចក្តីដកស្រង់ណែនាំ មតិណែនាំរបស់សមមិត្តតំណាងអង្គការបក្សក្នុងសន្និបាត ភូមិភាគមួយ គឺពីថ្ងៃទី០៣ ដល់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ១៩៧៦។

សម្រង់ទី១ គឺនៅទំព័រជាភាសាខ្មែរ គឺ 00062850 ទៅដល់ 51, ជាភាសាបារាំង គឺ 00487760 ទៅដល់ 61, ជាភាសាអង់គ្លេសគឺ 00509615 ទៅដល់ 16។ ចំណងជើងគឺ បញ្ហាសំខាន់ត្រូវក្តាប់មហាជនពិសេសត្រូវក្តាប់សហករណ៍។ ខ្ញុំសូមដកស្រង់ ចុះខាងក្រោមបន្តិចមក "បក្សត្រូវក្តាប់សហករណ៍។ តើក្តាប់សហករណ៍យ៉ងម៉េចក្នុងក្របខ័ណ្ឌទប់ទល់ខ្មាំង? គឺក្តាប់ខាងនយោបាយឲ្យណែនឲ្យគេយល់ពីមាគ៌ានយោបាយសំខាន់ៗរបស់បក្ស"។ រំលងបន្តិចមក "ភ្លឺ ប្រឡាយ បីតោន គឺកសាងប្រទេសនិងការពារប្រទេស ត្រូវពន្យល់គេឲ្យគេជ្រះស្រឡះ"។ រំលងពីរបីបន្ទាត់ចុះមកក្រោមទៀតមក "ម្យ៉ាងទៀតក្តាប់ខាងចាត់តាំង ក្តាប់សមាសភាព ក្តាប់ប្រវត្តិរូបជាបន្តបន្ទាប់ យកកម្លាំងមហាជននៅក្នុងសហករណ៍ដើម្បីទប់ទល់ខ្មាំង"។

[០៩:៥១:០៩]

នៅក្នុងឯកសារដដែលនេះ គឺឯកសារ E3/760 សហករណ៍ត្រូវបានគេដាក់ចេញនូវគោលដៅដ៏មានមហិច្ឆតាដោយអង្គការបក្ស។ នៅទំព័រជាភាសាខ្មែរគឺ 00062865, ជាភាសាបារាំង 00487774, ជាភាសាអង់គ្លេសគឺ 00509626។ ខ្ញុំសូមដកស្រង់៖ "ត្រង់នេះខ្ញុំចង់និយាយថា ក្នុងក្របខ័ណ្ឌភូមិភាគយើងចំពោះកន្លែងខ្លះតែបី ឬបួន ឬប្រាំឆ្នាំក៏យើងចូលទៅកសិកម្មសម័យហើយ ឯរយៈពេល១០ ឬ១៥ឆ្នាំទៀត គឺនិយាយទូទាំងប្រទេស"។ រំលងពីរបីបន្ទាប់មកក្រោមទៀតមក "បើយើងនេះដល់ឆ្នាំ១៩៨០ យើងយកបាន១០តោន ទៅ១១តោនយ៉ាងធូរ។ ដូច្នេះក្នុងរយៈពេលខ្លីយើងមានទុនសម្រាប់ទិញម៉ាស៊ីន ទិញប្រេង និងឧបករណ៍ផ្សេងៗ"។ សូមបញ្ចប់ការដកស្រង់។

[០៩:៥២:៣៥]

បាទ ឯកសារបន្តទៀត គឺឯកសារ E3/193 គឺជាទង់បដិវត្តខែសីហា ឆ្នាំ១៩៧៧ គឺជាសុន្ទរកថារបស់អ្នកតំណាងបក្សស្តីអំពីសេចក្តីណែនាំមួយចំនួននៅក្នុងការកសាងពង្រឹងពង្រីកបក្សដឹកនាំក្នុងឱកាសសន្និបាតកម្មាភិបាលភូមិភាគបស្ចិម ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧។ ឯកសារនេះសំខាន់ណាស់ ពីព្រោះថាវាមិនត្រឹមតែទាក់ទងទៅនឹងភូមិភាគបស្ចិមនោះទេ ក៏ប៉ុន្តែថែមទាំងមានគោលនយោបាយ ហើយនិងគោលជំហររបស់បក្សដែលត្រូវតែអនុវត្តនៅគ្រប់ភូមិភាគទាំងអស់នៅក្នុងប្រទេស។ ដូច្នេះឯកសារនេះ បញ្ចប់ដោយពាក្យពេចន៍ដូចតទៅនេះ, ជាភាសាខ្មែរ គឺទំព័រ00062979, ជាភាសា

បារាំង 00611852, ជាភាសាអង់គ្លេស គឺ 00399246។ សូមដកស្រង់ "ស្នើឲ្យបក្សដឹកនាំគ្រប់ថ្នាក់យកចិត្តទុកដាក់ពិនិត្យពិចារណាសិក្សារៀនសូត្របទឧទ្ទេសនាមនេះឲ្យបានហ្មត់ចត់ ដើម្បីយកទៅអនុវត្តនៅតាមភូមិភាគរបស់ខ្លួនឲ្យបានលទ្ធផលល្អ"។ បាទ សូមបញ្ចប់ការដកស្រង់។

[០៩:៥៤:១៧]

សុន្ទរកថានេះ និយាយអំពីការបោសសម្អាតនៅក្នុងភូមិភាគបស្ចិម ហើយនិងការតស៊ូវណ្ណៈនៅក្នុងសហករណ៍ ហើយនិងការចាំបាច់ក្នុងការក្តាប់សហករណ៍ទាំងអស់ ដែលសហករណ៍ទាំងអស់នោះត្រូវតែដឹកនាំដោយកសិករក្រ ហើយនិងកសិករក្រមធ្យមក្រោម គឺមិនមែនត្រូវដឹកនាំដោយសត្រូវ ឬខ្មាំងនោះទេ។ ជាភាសាខ្មែរ គឺឯកសារ 00629234 រហូតទៅដល់ 36 នៅលេខចុងក្រោយលេខ, ជាភាសាបារាំងគឺ 001839 *(ស៊ុក)* ទៅដល់ ទៅដល់ 40, ជាភាសាអង់គ្លេសគឺ 00399234 ទៅដល់ 36 -- អ៊ំ! 35 សូមទោស។ បាទ ខ្ញុំសូមដកស្រង់ "នៅក្នុងមួយចំនួនគួរសមដែរ មិនទាន់នៅក្នុងកណ្តាប់ដៃកម្មករនិងកសិកររបស់បក្សទេ។ វានៅក្នុងកណ្តាប់វណ្ណៈផ្សេងនៅឡើយ ហើយបើនៅក្នុងកណ្តាប់ដៃវណ្ណៈផ្សេងៗនោះ តើវណ្ណៈហ្នឹងនៅក្នុងបដិវត្តន៍ឬទេ? អត់ទេ។ ប្រឆាំងបដិវត្តន៍"។

បាទ ហើយនៅក្រោមបន្តិច "រៀបចំកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោម ទៅកាន់កាប់សហករណ៍ ទៅរើកម្ទេចរដ្ឋអំណាច វណ្ណៈផ្សេងដែលមកលួចកាន់កាប់សហករណ៍របស់យើង"។ បាទ ហើយនៅក្រោមហ្នឹងបន្តិចទៀត បញ្ជាក់លាក់នេះដដែលនោះ "មិនត្រឹមតែទាក់ទងទៅនឹងភូមិភាគបស្ចិមទេ ប៉ុន្តែគ្រប់ភូមិភាគទាំងអស់នៅប្រទេស"។

[០៩:៥៦:១៨]

បាទ សម្រង់ទី២នៃឯកសារដដែលនេះ នៅទំព័រជាភាសាខ្មែរគឺ 00062978, ជាភាសាបារាំងគឺ 00611851, ជាភាសាអង់គ្លេសគឺ 00399246។ "គឺជាសេចក្តីសន្និដ្ឋានរបស់អ្នកតំណាងបក្សនៃនៅក្នុងសមាជនៅភូមិភាគបស្ចិម។ ដូច្នេះធ្វើយ៉ាងម៉េចពីនេះទៅចុងឆ្នាំ១៩៧៧ ត្រូវរៀបចំកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោមទៅកាន់រដ្ឋអំណាចគ្រប់ផ្នែកនៅក្នុងសហករណ៍នីមួយៗឲ្យបានចំនួនលើសពី៥០ភាគរយនៃសហករណ៍ទូទាំងភូមិភាគ ហើយដល់ពាក់កណ្តាលឆ្នាំ៧៨យ៉ាងយូរឲ្យបាន១០០ភាគរយ"។

បាទ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយពីផ្នែកចុងក្រោយនៃការបង្ហាញឯកសាររបស់ខ្ញុំនេះ។ មានឯកសារជាក់លាក់មួយទាក់ទងទៅនឹងការដ្ឋានសំណង់ ហើយនិងការដ្ឋានការងារ។ យើងសង្កេតឃើញថាអ្នកដឹកនាំបក្សចាប់អារម្មណ៍ទៅដល់ការផលិតអំបិលនៅស្រែអំបិលនៅក្នុងតំបន់កំពត ហើយនិងការ

បង្កើនផលិតកម្មជាដាច់ខាត។

[០៩:៥៧:៥៩]

ឯកសារទី១ គឺជាឯកសារ E3/230 បាទគឺជាកំណត់ហេតុនៃការកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី២២ កុម្ភៈ ឆ្នាំ១៩៧៦ ដែលជនជាប់ចោទនៅទីនេះបានចូលរួម។ នៅទំព័រជាភាសាខ្មែរគឺ 00000711, ជាភាសាបារាំងគឺ 00301330, ជាភាសាអង់គ្លេសគឺ 00182546។ បាទសូមអានម្ដងទៀត គឺថា 00182546 ចំណងជើងគឺ "បញ្ហាផលិតស្រែអំបិលៈ ស្នើជំរុញថែមឲ្យបានពី៥០.០០០ ទៅ ៦០.០០០ តោន"។ បាទ សូមបញ្ចប់ការដកស្រង់។

បាទនៅឯកសារមួយទៀត ទាក់ទងទៅនឹងការផលិតអំបិលនេះដែរ គឺឯកសារ E3/733 គឺជាទស្សនាវដ្ដីទង់បដិវត្តចុះខែឧសភា ឆ្នាំ១៩៧៦។ ជាភាសាខ្មែរលេខ ERN គឺ 00064011, ជាភាសាបារាំងគឺ 00524482, ជាភាសាអង់គ្លេសគឺ 00357874។ បាទ សូមដកស្រង់ "ចំណែកយុវជន យុវនារីយើងខាងស្រែអំបិលត្រូវវាយសម្រុក ត្រៀមរៀបចំ ពង្រឹងពង្រីកស្រែអំបិលឲ្យបានកាន់តែធំ កាន់តែល្អមាំទាំសម្រាប់បង្កើនផលអំបិលនៅឆ្នាំ៧៦ នេះឲ្យបានច្រើនបំផុត"។ បាទ សូមបញ្ចប់ការដកស្រង់។

[១០:០០:៣៦]

នៅទីបញ្ចប់គឺជាសុន្ទរកថារបស់លោក ខៀវ សំផន នៅបុណ្យខួបទី៣នៃបក្សកុម្មុយនីស្តកម្ពុជា ដែលចុះឆ្នាំ៧៨។ លេខ E3/169, ជាភាសាខ្មែរគឺលេខ ERN S00704520, ជាភាសាបារាំង S00004805, ជាភាសាអង់គ្លេសគឺ 00280394។ បាទ សូមដកស្រង់ "ឆ្នាំមុនអង្គភាពស្រែអំបិលបានផលិតក្នុងទិន្នផលខ្ពស់លើសពីផែនការដែលបានកំណត់ទុក។ ឆ្នាំនេះ អង្គភាពនេះបានសម្រេចផែនការដែលគ្រោងប្រចាំឆ្នាំចាប់តាំងពីបំណាច់ខែមីនាមកម្ល៉េះ។ នៅក្នុងអំឡុងខែមេសាបន្តទៅទៀត ការផលិតអំបិលបានទិន្នផលខ្ពស់លើសពីផែនការដែលបានគ្រោងទុក។ អង្គភាពស្រែអំបិល គឺជាអង្គភាពឈានមុខដែលជាគំរូសម្រាប់ទូទាំងប្រទេស"។ បាទ សូមបញ្ចប់ការដកស្រង់។

បាទ ឥឡូវទាក់ទងទៅនឹងការដ្ឋានសំណង់ ការដ្ឋានសាងសង់ព្រលានយន្តហោះនៅកំពង់ឆ្នាំង។ មានកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ ដែលនិយាយអំពីសេចក្ដីសម្រេចសាងសង់ព្រលានយន្តហោះនេះ។

ឯកសារទី១ គឺឯកសារ E3/182, កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ តុលា ឆ្នាំ១៩៧៥។ ខ្ញុំសូមអានសម្រង់ខ្លីទេ ជាភាសាខ្មែរគឺ 00019126, ជាភាសាបារាំងគឺនៅទំព័រចុងក្រោយ គឺលេខ ERN 00292886 ហើយជាភាសាអង់គ្លេសគឺលេខ ERN 00183407។ "ឯព្រលានយន្តហោះខាងយោធា

យើងមានផែនការធ្វើនៅកន្លែងផ្សេងៗទៀត អាចពិនិត្យមើលនៅខាងកំពង់ឆ្នាំង ពង្រឹងនិងពង្រីកវា”។ បាទ សូមបញ្ចប់ការដកស្រង់។

[១០:០៣:៣៤]

កំណត់ហេតុប្រជុំមួយទៀត ដែលចុះថ្ងៃទី២២ កុម្ភៈ ឆ្នាំ១៩៧៦ ធ្វើនៅពេលយប់ កាលណោះ នួន ជា និង ខៀវ សំផន មានវត្តមានដែរ។ ហើយកិច្ចប្រជុំនេះនិយាយអំពីបញ្ហាការពារប្រទេស។ គឺឯកសារ E3/229, ជាភាសាខ្មែរគឺ 00000720, ជាភាសាបារាំងគឺ 00334960, ជាភាសាអង់គ្លេសគឺ 00182627។ បាទ សូមដកស្រង់ “លេខ២ គឺបញ្ហាជំនួយចិនទាក់ទងទៅនឹងខាងអាកាស។ ទាក់ទងនឹងព្រលានយន្តហោះ អ៊ីចឹងសូមឲ្យពិនិត្យមើលកន្លែងថ្មីទៀតឲ្យច្បាស់លាស់ជាងហ្នឹងដូចជានៅត្បាតពង ឬកំពង់ឆ្នាំង”។

ហើយនៅឯកសារបញ្ចប់ហ្នឹង គឺឯកសារ E3/235 គឺជាកំណត់ហេតុប្រជុំនៃគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី១៩ ទៅថ្ងៃទី២១ មេសា ឆ្នាំ១៩៧៦ គឺសេចក្តីសម្រេចដែលធ្វើឡើងក្រោយពីបានប្រជុំ៣ថ្ងៃ។ គឺសម្រេចកសាងព្រលានយន្តហោះយោធា។ ERN ជាភាសាខ្មែរគឺ 00019145, ជាភាសាបារាំងគឺ 00322970, ជាភាសាអង់គ្លេសគឺ 00183419។ សូមដកស្រង់ ចំណងជើងទី៣ ស្តីអំពីកិច្ចការពារប្រទេស, ផ្នែកទី២ ព្រលានយន្តហោះយោធា។ “យើងរៀបចំដំណើរការនៅកំពង់ឆ្នាំងចុះ យើងត្រូវការការពារប្រទេសឲ្យមានប្រសិទ្ធភាព”។ សូមបញ្ចប់ការដកស្រង់។

[១០:០៦:០០]

ទាក់ទងទៅនឹងឯកសារ ដែលទាក់ទងទៅនឹងកន្លែង ឬក៏ជំរំការងារ ឬក៏ការដ្ឋានដដែលនោះ ហើយមានទាក់ទងទៅនឹងទំនប់អាងទឹក១មករា និងអាងទឹកត្រពាំងថ្ម។ ខ្ញុំសូមជូនឯកសារ គឺឯកសារ E3/200 ឬក៏ឯកសារ E3/201 គឺជារបាយការណ៍របស់ ប៊ី.ប៊ី.ស៊ី ដែលលើកឡើងអំពីសុន្ទរកថារបស់លោក ខៀវ សំផន ដែលធ្វើឡើងនៅបុណ្យខួបជោគជ័យថ្ងៃ១៧ មេសា នៅក្នុងកិច្ចប្រជុំមួយ -- ប្រជុំមហាជនមួយនៅថ្ងៃទី១៥ មេសា ឆ្នាំ១៩៧៧ នៅទីក្រុងភ្នំពេញ។ លេខ ERN ជាភាសាខ្មែរគឺ 00292 806 ដល់07 ហើយជាភាសាអង់គ្លេស 00419513 ទៅដល់ 14, ERN ជាភាសាបារាំងគឺ 00612167 ទៅដល់68។ បាទ ខ្ញុំសូមដកស្រង់ “ដូច្នេះការសម្រុកការកសាងប្រទេសយើងនៅក្នុងឆ្នាំ៧៧ ខ្លាំងក្លាជាងឆ្នាំ៧៦ អង្គភាពផលិតកម្មរីកចម្រើនរបស់យើងមួយចំនួនបានបំពេញផែនការឆ្នាំ៧៧រួចទៅហើយ ដូចអង្គភាពផលិតអំបិល។ លើសពីនេះទៅទៀត គឺគ្រប់ការដ្ឋានសាងសងទាំងអស់ដែលកំពុងកសាង

ទំនប់ទឹក ជីកអាងស្តុកទឹក និងជីកប្រឡាយទឹក អង្គភាពជាច្រើនបានបញ្ចប់ផែនការនៅឆ្នាំ១៩៧៧របស់ខ្លួនរួចទៅហើយ។ អង្គភាពរីកចម្រើនទាំងនេះ អាចឃើញមាននៅក្នុងគ្រប់តំបន់ និងស្រុក កន្លងមករហូតដល់ពេលនេះ គឺកសាងការដ្ឋានសាងសងជាច្រើន បានបំពេញការងាររបស់ខ្លួនពី៦០ ទៅ៧០ភាគរយទៅហើយ។ នៅទូទាំងប្រទេសការកសាងការដ្ឋានទាំងអស់នេះ បានបំពេញផែនការនៅឆ្នាំ៧៧ នៅបំណាច់ខែឧសភា។ គម្រោងទាំងនេះ រួមមានទំនប់ស្រោចស្រពវាលស្រែពេញមួយឆ្នាំ ហើយនិងមានទំនប់ទឹកនៅព្រែកត្នោត នៅស្ទឹងជីនិត នៅស្ទឹងផ្សេងៗទៀត។ លើសពីនេះទៅទៀត យើងបានកសាង និងកំពុងកសាងអាងស្តុកទឹកធំៗ រាប់រយលានម៉ែត្រគូប ហើយការកសាងអាងស្តុកទឹកនេះ ប្រឡាយ ឬក៏ទំនប់ទឹកនីមួយៗ កម្មកររបស់យើងបានធ្វើការប្រហែលជាខ្ទង់១០.០០០ ទៅ៣០០.០០០នាក់ ហើយការងារទាំងអស់នេះ ធ្វើសុទ្ធតែនឹងដៃ និងកម្លាំងទាំងអស់ដោយខ្លួនឯង។ ដូច្នេះវាបញ្ជាំងអំពីវីរភាពរបស់ប្រជាជនយើង ហើយនិងកម្លាំងរបស់ប្រជាជនយើង។ ទោះបីជាដៃទទេ ក៏ពួកគេអាចធ្វើការងារបានដែរ”។

[១០:០៩:២៩]

បាទ ឯកសារមួយទៀត អ៊ំ! ផ្នែកមួយទៀតនៃឯកសារនេះ ជាភាសាខ្មែរគឺ 00292811, ជាភាសាអង់គ្លេស 00612170, ជាភាសាអង់គ្លេសគឺ 00419516។ បាទ សូមដកស្រង់ “ដូច្នេះគោលដៅយើងគឺត្រូវធ្វើការចម្រើនចលនាកសាងជាតិ រៀនជំនាញបច្ចេកទេសស្របពេលជាមួយគ្នា។ ទោះយើងចំណាយត្រឹមតែ ៥ ឬ១០ឆ្នាំក្នុងការកសាងទំនប់ និងអាងស្តុកទឹក ក៏គ្មានបញ្ហាអ្វីដែរ។ ក្នុងរយៈពេល ៥ ឬ១០ឆ្នាំខាងមុខ យើងនឹងអាចរីកចម្រើនជាងនេះ សំបូរជាងនេះ ហើយមានបទពិសោធន៍ជាងនេះ ហើយនិងអាចក្តាប់នូវ ក្តាប់បាននូវជំនាញបច្ចេកទេសបានច្រើនជាងនេះ”។ បាទសូមបញ្ចប់ការដកស្រង់។

[១០:១០:៣៤]

ឥឡូវឯកសារមួយទៀត ឯកសារ E3/1783 នេះគឺជារឿងរ៉ាវដែលទាក់ទងទៅនឹងទស្សនកិច្ចរបស់ ជិន យុងគ្វី ថ្ងៃទី២២ ធ្នូ ឆ្នាំ១៩៧៧ គឺជាឯកសាររបស់ អេហ្វប៊ីអេស។ ឯកសារទាំងអស់នេះស្ថិតនៅក្នុងចំណោមឯកសារពាក់ព័ន្ធផ្សេងទៀតជាច្រើន ពីព្រោះថាវាបង្ហាញពីផែនការគណៈកម្មការមជ្ឈិមក្នុងការសង់ទំនប់ទឹក ហើយនិងមោទនភាពរបស់ថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការសាងសង់សំណង់ទាំងអស់នេះ ហើយនិងក្នុងការបង្ហាញសំណង់ទាំងអស់នេះទៅកាន់ជនបរទេស។

ឧទាហរណ៍ដូចជា ប៉ុល ពត បាននាំគេទៅទស្សនកិច្ចនៅទំនប់ត្រពាំងថ្ម ដូចជាលោកឧបនាយករដ្ឋមន្ត្រី ចិន ជិន យុងគ្វី ជាដើម។

យើងឃើញមាននៅទំព័រ ERN គឺ00659260 ជាភាសាខ្មែរ, ហើយនិងជាភាសាបារាំងគឺ 00606766, ERN ជាភាសាអង់គ្លេស គឺ00498181។ បាទខ្ញុំសូមដកស្រង់ "សមមិត្ត រស់ ញឹម បានមានប្រសាសន៍ថាអាងស្តុកទឹកត្រពាំងថ្ម ត្រូវបានកសាងក្នុងរយៈពេលជាង១ឆ្នាំ ដោយប្រជាជនក្នុងតំបន់៥នៃភូមិភាគពាយ័ព្យ ដោយជាការឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់គណកម្មាធិការមជ្ឈិមដើម្បីកសាងអាងស្តុកទឹកដ៏ធំមួយនេះ"។

[១០:១២:៤៦]

ខ្ញុំសូមដកស្រង់ខិតមកក្រោមបន្តិច។ បន្ទាប់មកទៀតគាត់លើកឡើងថា៖ គ្រោះរាំងស្ងួតបានកើតឡើងនៅពេលដែលយើងចាប់ផ្តើមកសាងអាងស្តុកទឹកដោយមានប្រជាជនចំនួន... ដោយសារប្រជាជនពុំមានទឹកហូបគ្រប់គ្រាន់។ នរណាក៏កោតសរសើរអំពីគោលជំហរបដិវត្តន៍ដ៏ក្លៀវក្លារបស់ប្រជាជនក្នុងការកសាងប្រទេស ហើយនិងសមិទ្ធិផលដ៏អស្ចារ្យនេះដែរ។ ហើយបន្ទាប់មកទៀត ទាក់ទងទៅនឹងទំនប់ទឹក១មករា ដែលមានឧបនាយករដ្ឋមន្ត្រីចិនបានមកធ្វើទស្សនកិច្ចដែលនៅស្ទឹងជីនិត។ បាទ ខ្ញុំសូមបញ្ចប់ការដកស្រង់។

ទាក់ទងទៅនឹងគោលនយោបាយ ពាក់ព័ន្ធទៅនឹងសហករណ៍ ហើយនិងការដ្ឋានសំណង់ ការដ្ឋានមួយចំនួន។ លោកប្រធានខ្ញុំបញ្ចប់មុនម៉ោងកំណត់ ហើយសហភាតារបស់ខ្ញុំនឹងមកជំនួសខ្ញុំបន្តិចទៀតនេះ។ អ៊ីចឹងខ្ញុំសូមសួរលោកប្រធាន តើឥឡូវនេះយើងអាចសម្រាកក្នុងពេលឥឡូវនេះ ឬក៏ត្រូវធ្វើយ៉ាងម៉េចទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមស្របសម្រាកដែរហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពេលពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះម្ភៃប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៤០ នាទី)*

[១០:៤០:00]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណ។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីភាគីទាំងអស់។ នៅក្នុងថ្ងៃនេះខ្ញុំនឹងបង្ហាញឯកសារគន្លឹះពាក់ព័ន្ធទៅនឹងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាលើបញ្ហាខ្មាំង និងការកំណត់គោលដៅក្រុមជាក់លាក់។ ខ្ញុំនឹងចាប់ផ្តើមដោយលើកឡើងឯកសារពាក់ព័ន្ធទៅនឹងគោលនយោបាយបក្សទូទៅ និងសេចក្តីសម្រេចចូលរួមជាមួយនឹងសហគ្រាស និងការលុបបំបាត់អំពើហិង្សា ដែលជាពិសេសការលុបបំបាត់ខ្មាំងបក្សកុម្មុយនីស្តកម្ពុជា។ ឯកសារទាំងអស់នេះគឺបង្ហាញអំពីគោលនយោបាយទាំងអស់នោះថាតើគោលនយោបាយបង្កើតឡើងដោយរបៀបណាហើយមានការឯក-ភាពគ្នាយ៉ាងម៉េចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងចំណោមស្ថាប័នសំខាន់ៗ និងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យនាសម័យនោះ រួមទាំងគណៈកម្មាធិការមជ្ឈិម ក្រសួង ផ្នែកយោធា ភូមិភាគ និងតំបន់ស្វ័យត នៅទូទាំងប្រទេស។ ឯកសារទាំងអស់នេះនឹងបង្ហាញមាគ៌ាគន្លឹះរបស់បក្ស ពាក់ព័ន្ធទៅនឹងបញ្ហាខ្មាំង។ សេចក្តីសម្រេចក្នុងការប្រើប្រាស់អំពើហិង្សាបដិវត្តន៍ប្រឆាំងនឹងខ្មាំងបក្សកុម្មុយនីស្តកកម្ពុជា។

[១០:៤២:១៥]

ការកំណត់ខ្មាំងដែលបក្សជឿថា មានចរិតស្លាប់រស់ ទំនាស់គ្នាស្លាប់រស់នោះគឺក៏បានបង្ហាញនៅក្នុងនេះ ហើយមានការកោះអំពាវនាវអំពីការធ្វើបដិវត្តន៍រឹងប៉ឹងនឹងសេចក្តីណែនាំធ្វើការវាយសម្រុកកម្ទេចឬក៏លុបបំបាត់ខ្មាំងគ្រប់ប្រភេទឲ្យអស់។ ផ្នែកទី២ នៃបទបង្ហាញរបស់ខ្ញុំផ្តោតសំខាន់ទៅលើឯកសារដែលបង្ហាញអំពីផែនការគោលនយោបាយបក្សកំណត់គោលដៅទៅលើមន្ត្រីរដ្ឋការ និងទាហានលន់នល់ក្នុងសម័យសាធារណរដ្ឋខ្មែរ។ ដោយសារបញ្ហានេះគឺជាបញ្ហា សំខាន់នៅក្នុងសំណុំរឿងនេះខ្ញុំនឹងព្យាយាមលើកឡើងចំណុចទាំងអស់នេះឲ្យបានលម្អិត ហើយនិងបង្ហាញឯកសារនីមួយៗដាច់ដោយឡែកពីគ្នា។

ពាក់ព័ន្ធទៅនឹងការកំណត់គោលដៅទៅលើក្រុមផ្សេងទៀតដូចជា ចាម វៀតណាម និងក្រុមពុទ្ធសាសនា ខ្ញុំនឹងមិនធ្វើបទបង្ហាញដោយឡែកនោះទេ ក៏ប៉ុន្តែខ្ញុំនឹងបង្ហាញឯកសារគន្លឹះសំខាន់មួយចំនួន

ពាក់ព័ន្ធទៅនឹងការកំណត់គោលដៅទៅលើក្រុមនីមួយទាំងនោះ ដែលវាស្ថិតនៅក្នុងផ្នែកបទបង្ហាញរបស់ខ្ញុំដំបូងពាក់ព័ន្ធទៅនឹងគោលនយោបាយទូទៅ។

ខ្ញុំចាប់ផ្ដើមនៅក្នុងថ្ងៃនេះដោយបង្ហាញឯកសារមួយចំនួន។ បង្ហាញអំពីដើមកំណើតនៃគោល-នយោបាយបក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធទៅនឹងខ្មាំង ដែលមេដឹកនាំកម្ពុជាប្រជាធិបតេយ្យលើកឡើងគោលនយោបាយនេះពីណាមក។ ឯកសារ E3/9 គឺសៀវភៅរបស់លោក ហ្វីលីព ស្សូត សុបិនអាក្រក់នៃប្រវត្តិសាស្ត្ររបស់ ប៉ុល ពត។ ចាប់ផ្ដើមដោយអង់គ្លេស ERN 00396256, បារាំងមានលេខ 006 39526។ សៀវភៅនេះមិនទាន់បានបកប្រែចេញជាភាសាខ្មែរនៅឡើយនោះទេ។

[១០:៤៤:២៧]

លោក ហ្វីលីព ស្សូត បានរៀបរាប់អំពី ការរៀបរាប់អំពីកុម្មុយនីស្តដែលថ្លែងដោយ សាឡុត ស, អៀង សារី និងសមាជិកក្រុមរបស់ពួកគេ។ គាត់សរសេររៀបរាប់ដូចតទៅ សូមដកស្រង់ "គេបានជួបប្រជុំម្ដងក្នុងមួយសប្ដាហ៍ជាទូទៅប៉ុន្មានម៉ោងក្នុងពេលល្ងាចដើម្បីពិភាក្សាអំពីហេតុការណ៍ និងដើម្បីសិក្សាអំពីគោលការណ៍ម៉ាក្សនិយម។ ពួកគេក៏សិក្សាអំពីម៉ាក្ស-ឡេនីនផងដែរ ហើយដែលអនុវត្តតាម ម៉ៅ សេទុង ពាក់ព័ន្ធទៅនឹងការធ្វើប្រជាធិបតេយ្យនាសម័យថ្មី។ នៅពេលល្ងាចក៏មានវគ្គស្វ័យទិតៀន និងវគ្គទិតៀនផងដែរ ដែលនៅក្នុងនោះ គឺសមាជិកនីមួយៗ ទិតៀន អំពីចំណុចខ្វះខាត និងចំណុចដែលខ្លួនត្រូវកែលម្អ។

ឯកសារសន្លឹកបន្ទាប់ ទំព័របន្ទាប់លោក ហ្វីលីព ស្សូត បាន លើកឡើងអំពីលោក សាឡុត ស និងក្រុមនិស្សិតដែលលើកឡើងអំពីទស្សនៈរបស់លោក ស្តាលីន ទៅលើបញ្ហាបក្សកុម្មុយនីស្តនាពេលនោះ។ ខ្ញុំសូមអានចំណុចដកស្រង់មួយចេញពីប្រធានបទនេះ ERN ជាភាសាអង់គ្លេស គឺ 00396258 រហូតទៅដល់59, បារាំងមានលេខ 00639529 រហូតទៅដល់លេខ 31។ អត្ថបទត្រង់នេះលើកឡើងថាតើឯកសារសរសេរដោយ ស្តាលីន នោះស្តីអំពីប្រវត្តិសាស្ត្របក្សកុម្មុយនីស្តនៅសហភាពសូវៀត។ សៀវភៅនេះ បានរៀបរាប់អំពីឥទ្ធិពលដែលវាមានមកលើក្រុម ប៉ុល ពត និងក្រុមនាសម័យនោះ។

[១០:៤៦:៤០]

លោក ហ្វីលីព ស្សូត បានសរសេរដូចតទៅ៖ ស្នាដៃនិពន្ធសៀវភៅនេះធ្វើឡើងដោយ -- សរសេរដោយលោក ស្តាលីន នៅក្នុងឆ្នាំ១៩៣៨ ក្រោម -- នៅពេលដែលក្រោយមកមានអំពើហិង្សាមួយ ហើយដើម្បីឲ្យអ្នកជនកុម្មុយនីស្តនៅទូទាំងពិភពលោកបានជ្រួលជ្រាប។ ម៉ៅ បានបកប្រែទៅជា

ភាសាចិន។ ហូ ជីមិញ បានបកប្រែចេញជាភាសាវៀតណាម។

ដូច្នេះសៀវភៅនេះ គឺមិនអាចបន្ទោសអំពីការអនុវត្តកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជាដែលមានលក្ខណៈចរិតព្រៃផ្សៃនោះទេ ក៏ប៉ុន្តែយ៉ាងណាក៏ដោយសៀវភៅនោះ បានមានឥទ្ធិពលទៅលើក្រុមកម្ពុជា។ ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា គឺវាបានសិក្សាតាមរយៈបទពិសោធន៍នេះ ហើយអ្នកខ្លះចង់ដើរតាមលទ្ធិកាល់ម៉ាក្ស ហើយពេលខ្លះពួកគេទទួលបានជោគជ័យ។

[១០:៤៧:៤៩]

ចំពោះពលោក ស្តាលីន បានបង្ហាញអំពីការគិតគូរអំពីជនបដិវត្តន៍នៅក្នុងប្រទេសកម្ពុជា។ គាត់បានគូសបញ្ជាក់អំពីការដឹកនាំដ៏មហាអស្ចារ្យ ហើយដែលនៅពេលនោះ គឺនឹងមានការធ្វើស្វ័យទិតៀន និងធ្វើទិតៀន។ ដូច្នេះហើយគឺគិតថា ស្តាលីន និង ម៉ាក្សស៊ីហ្សឹម និងលទ្ធិម៉ាក្ស មិនមែនជាលទ្ធិមួយដែលមិនមានឥទ្ធិពលនោះទេ។ ស្តាលីន បានសរសេរថា "បក្សនឹងកាន់តែខ្លាំងឡើងៗតាមការក្តោបនូវតួនាទី និងសមាសធាតុរបស់ខ្លួន"។

ហើយបន្ទាប់មក គឺមានចំណុចដកស្រង់ចេញពីសៀវភៅរបស់លោក ស្តាលីន៖ ដោយមិនចាំបាច់ធ្វើការតស៊ូប្រយុទ្ធទៅលើពួកឆ្វៀតឱកាសនិយមនៅក្នុងជួរ បក្សមិនអាចអនុវត្តតួនាទីរបស់ខ្លួនបានទេ។ បក្សអាចមើលឃើញថា ខ្លួនបានចំណាយពេលច្រើនទៅលើការតស៊ូ ហើយដាក់លក្ខណៈសំខាន់ពេកទៅលើការតស៊ូរបស់ខ្លួន។ ចំណុចនេះគឺជាការយល់ខុស។ យើងមិនអាចអត់ទ្រាំចំពោះចំណុចនេះទេ។ គ្មានមធ្យោបាយណាមួយដែលយើងអនុញ្ញាតឲ្យពួកឆ្វៀតឱកាស អ្នកដែលប្រមើលមើល និងពួកក្បត់ស្ថិតនៅក្នុងជួរដឹកនាំរបស់វណ្ណៈកម្មកររបស់យើងនោះឡើយ។ បន្ទាយរបស់យើងអាចវាយចាប់យកដោយងាយ។ ដើម្បីទទួលជោគជ័យ យើងត្រូវតែព្យាយាម និងលើកទឹកចិត្តទៅដល់បក្ស កម្មករឲ្យមានការយកចិត្តទុកដាក់ ហើយធ្វើយ៉ាងណាលុបបំបាត់ពួកក្បត់ចោល។

[១០:៤៩:៥៤]

ស្បូត បានសរសេរតទៀតថា "ប្រវត្តិសាស្ត្រនេះបានផ្តល់ជាបទពិសោធន៍ផងដែរអំពីសារៈសំខាន់នៃបដិវត្តន៍ ដែលគេប្រើប្រាស់នូវការតស៊ូផ្លូវច្បាប់ និងខុសច្បាប់ដើម្បីឈ្នះអំណាច។ ហើយជាពិសេសត្រូវធ្វើយ៉ាងណាឲ្យបក្ខជនមានការយកចិត្តទុកដាក់ខ្ពស់។ ក៏ប៉ុន្តែទម្ងន់របស់ ស្តាលីន គឺកុម្មុយនីស្តត្រូវតែមានការរឹងប៉ឹងប្រឆាំងទៅនឹងបញ្ញានយោបាយ។ ប្រជាជនទាំងអស់នេះ គឺត្រូវចូលទៅដល់ទិសដៅមួយដែលត្រូវគោរពបក្ស ហើយប្រើប្រាស់សមាជិកដើម្បីធ្វើការបំផ្លិចបំផ្លាញ និងទទួលយកជ័យជម្នះ។

ដូច្នេះចំណុចនេះគឺជាការតស៊ូមួយសម្រាប់យើង"។

មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានទទួលឥទ្ធិពលពីសៀវភៅរបស់លោក ស្តាលីន ហើយលោក ហ្វីលីព ស្សូត បានសរសេរនាពេលក្រោយមកនៅក្នុងសៀវភៅនេះ។ អង់គ្លេស ERN គឺ 00396336, បារាំង 00639616។ ស្សូត បានសរសេរថា "មេដឹកនាំកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជាបានមិនទទួលយកគំនិតនេះនៅក្នុងឆ្នាំ១៩៥៦ គឺទស្សនៈរបស់លោក ដូក ឆូវ *(តាមសូរស័ព្ទ)* ដែលលទ្ធិនៃការដំណើរការពីកុម្មុយនីស្តកមកសង្គមនិយម"។ លោក ស្សូត បាននិយាយរៀបរាប់ដូចតទៅ "នៅក្នុងយុគសម័យសន្តិភាពរវាងប្លុកទាំងពីរ កុម្មុយនីស្ត បក្សកុម្មុយនីស្តបានឈ្នះអំណាចតាមរយៈការបោះឆ្នោត ជាជាងការតស៊ូវណ្ណៈ និងការធ្វើអំពើហិង្សាបដិវត្តន៍"។

[១០:៥២:១៤]

ឯកសារទី២ ដែលខ្ញុំសូមបង្ហាញគឺពាក់ព័ន្ធទៅនឹងប្រភពនៃគោលនយោបាយរបស់បក្សលើខ្មាំងគឺឯកសារ 157.2 ឯកសារ E152.2។ ឯកសារនេះគឺសៀវភៅរបស់លោក ថេត សម្បត្តិ "នៅពីក្រោយវាលពិឃាដ"។ ចំណុចដែលពាក់ព័ន្ធត្រង់ ERN ជាភាសាអង់គ្លេស 00757506, បារាំងមានលេខ 00849394 រហូតទៅដល់ 95, ខ្មែរ 00858278 រហូតដល់ 79។ នៅក្នុងសៀវភៅនេះមានផ្នែកមួយនិយាយអំពីឥទ្ធិពលរបស់ម៉ៅសេទុង លើ ប៉ុល ពត និង នួន ជា។ ជាពិសេសលើការបង្កើតនូវមាគ៌ាបក្ស។ ចំណុចដែលខ្ញុំដកស្រង់មានសរសេរដូចតទៅៈ

"អ្នកទាំងពីរ – សំដៅលើ ប៉ុល ពត និង នួន ជា – ស្វែងរកគោលការណ៍សម្រាប់ជាមូលដ្ឋាននៃបក្សកុម្មុយនីស្តកម្ពុជា។ ប៉ុល ពត ទទួលបន្ទុកការស្រាវជ្រាវបញ្ហាជាតិ ជាពិសេសមេដឹកនាំរដ្ឋាភិបាល និងស្ថានភាពនៅក្រុងភ្នំពេញ។ នួន ជា ទទួលបន្ទុកប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងស្ថានភាពនៅតាមទីជនបទ រួមទាំងសមាជិកបក្សនៅ -- ប៉ុល ពត បានទៅបណ្ណាល័យជាតិដើម្បីសិក្សាសៀវភៅបារាំង និងឯកសារបោះពុម្ពផ្សាយផ្សេងទៀត។ នួន ជា មិនដែលធ្លាប់ទៅបណ្ណាល័យជាតិនោះទេ ប៉ុន្តែគាត់ទិញសៀវភៅអំពីបញ្ហានយោបាយ និងគោលការណ៍នយោបាយ។ ជាពិសេសសៀវភៅស្តីអំពីវៀតណាម សហភាពសូវៀត ចិន និងសៀវភៅបោះពុម្ពផ្សាយអំពីប្រទេសកុម្មុយនីស្តផ្សេងទៀត។

[១០:៥៤:៣១]

នួន ជា បានអាននូវការទទួលជោគជ័យដោយមេដឹកនាំកុម្មុយនីស្ត ជុង ជីន *(តាមសូរស័ព្ទ)* – វៀតណាមដែលសរសេរសៀវភៅនៅក្នុងឆ្នាំ១៩៤៧ និងគាត់អានអំពីសង្គ្រាមឧទ្ទាម។ គាត់បានលើក

ឡើងអំពីទស្សនៈរបស់ លូ ឆាវជី ដែលក្រោយមកក្លាយទៅជាជនរងគ្រោះមួយរូបនៃបដិវត្តន៍វប្បធម៌ចិន។ នួន ជា ក៏បានសិក្សាសៀវភៅរបស់ស្តាលីន និងវ្លាឌីមៀរ។ ហើយ ប៉ុល ពត មើលសៀវភៅរបស់លោកឡេនីន ក៏ប៉ុន្តែ នួន ជា ចូលចិត្តអានសៀវភៅ ម៉ៅសេទុង។

នៅត្រង់ចំណុចនេះគឺខ្ញុំសូមលើកឡើងពាក់ព័ន្ធទៅនឹងបញ្ហា នួន ជា "ខ្ញុំចូលចិត្តអានសៀវភៅអំពីរបៀបធ្វើការងារសម្ងាត់ ហើយនិងសៀវភៅវៀតណាមដែលនិយាយអំពីការធ្វើទារុណកម្ម និងការចាប់ខ្លួនសមាជិកកុម្មុយនីស្ត។ នួន ជា បាននិយាយដូច្នេះ។ សៀវភៅចិននិយាយអំពីការងារសម្ងាត់ ហើយនិងប្រជាជនដែលធ្វើខ្លួនហាក់ដូចជាកុម្មុយនីស្ត ការពិតពួកគេជាគិញ"។ បញ្ចប់ការដកស្រង់។

[១០:៥៦:០០]

នៅពេលនេះ ខ្ញុំសូមបង្ហាញនូវឯកសារមួយចំនួនផ្សេងទៀតដែលលើកឡើងអំពីមាគ៌ាបក្ស អនុម័តដោយបក្សកុម្មុយនីស្តកម្ពុជានាពេលនោះ ជាពិសេសមាគ៌ាបក្សប្រឆាំងនឹងខ្មាំង និងការប្រើប្រាស់ហិង្សាបដិវត្តន៍។ ឯកសារសំខាន់ៗដែលលើកឡើងបញ្ហានេះគឺ E3/11។ គឺឯកសារទង់បដិវត្តចុះខែកញ្ញា ៧៧ របស់បក្ស។ ទស្សនាវដ្ដីនេះលើកឡើងអំពីសុន្ទរកថាលើកឡើងដោយ ប៉ុល ពត ក្នុងឱកាសគម្រប់ខួបលើកទី១៧ នៃការបង្កើតបក្ស។

ដើម្បីជាការណែនាំទៅដល់សុន្ទរកថាដែលខ្ញុំនឹងលើកឡើង យើងត្រូវដឹងថា សុន្ទរកថានៅខាងដើមនេះគឺមានសរសេរដូចតទៅ៖ "នៅក្នុងឱកាសប្រារព្ធខួបលើកទី១៧ នៃការបង្កើតបក្សកុម្មុយនីស្តកម្ពុជា បក្សរបស់យើងបានសម្រេចបោះពុម្ពផ្សាយជាផ្លូវការនិងជាសាធារណៈបង្ហាញអំពីបក្សកុម្មុយនីស្តកម្ពុជាទៅដល់ពិភពលោកឲ្យបានជ្រួតជ្រាប"។

ដោយសារតែសុន្ទរកថានេះមានគោលបំណងពីថ្នាក់ដឹកនាំ ដើម្បីជាសារសាធារណៈដល់ពិភពលោកអំពីជំហររបស់បក្ស សុន្ទរកថានេះបានផ្សព្វផ្សាយ តាមវិទ្យុ និងនៅតាមឯកសារនាសម័យនោះផ្សេងទៀត ដែលខ្លឹមសារទាំងអស់នោះក៏បានកត់ត្រានៅក្នុងឯកសារទាំងអស់នោះផងដែរ។ លើសពីនេះលើសពីឯកសារទង់បដិវត្តសុន្ទរកថាដូចគ្នានេះក៏ឃើញមាននៅក្នុងរបាយការណ៍របស់ហ្វីប៊ីសចុះនៅក្នុងខែនោះផងដែរ គឺឯកសារ E3/143, អង់គ្លេស ERN គឺ 00168771 ទៅ 76, ខ្មែរគឺ 00769652 ទៅដល់ 63, បារាំង 00723333 ទៅដល់ 39។

[១០:៥៨:២៨]

របាយការណ៍របស់ហ្វីប៊ីសបានលើកឡើងអំពីសុន្ទរកថារបស់លោក ប៉ុល ពត ធ្វើឡើងនៅក្នុង

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ៧៧ ក្នុងការប្រជុំមហាជន សមាជិកបក្ស ហើយមានកម្មករជាង ១០.០០០នាក់ កសិករ អ្នកដែលនៅក្នុងសហករណ៍ និងក្នុងជួរកងទ័ព និងអ្នកដែលធ្វើការនៅក្នុងការិយាល័យមន្ទីរនានាបានចូលរួមនៅក្នុងទីក្រុងភ្នំពេញផងដែរ។ ហើយគេបានលើកឡើងថាសុន្ទរកថារយៈពេល ៥ម៉ោងនេះក្រោយមកបានផ្សព្វផ្សាយតាមរយៈវិទ្យុនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ៧៧។

ហើយគេ -- ឯកសារមួយទៀតគឺឯកសារ E3/114។ ឯកសារនេះគឺរួមទាំងមានការបកប្រែជាភាសាបារាំង ដែលបោះពុម្ពផ្សាយដោយក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ ១៩៧៨។ សុន្ទរកថានេះមានភាពពាក់ព័ន្ធដោយសារតែមេដឹកនាំបក្សព្យាយាមបង្ហាញអំពីគោលនយោបាយរបស់ខ្លួនទៅដល់ពិភពលោក។

[១០:៥៩:៤៧]

ពាក់ព័ន្ធទៅនឹងឯកសារ ខ្លឹមសារនៃឯកសារនេះ គឺឯកសារ E3/11។ នៅក្នុងនោះគឺមានការរៀបរាប់យ៉ាងវែងអំពីយុទ្ធវិធីរបស់បក្សនៅក្នុងសមាជ នៅត្រង់ខ្មែរ ERN 00063136, អង់គ្លេស 00486227, បារាំង 00492812។ ចំណុចដំបូងដែលលើកឡើងដោយ ប៉ុល ពត -- នេះគឺជាសុន្ទរកថាដែលខ្ញុំលើកឡើង -- គឺពាក់ព័ន្ធទៅនឹងការសន្និដ្ឋានទៅលើសន្និបាតរបស់បក្សនាពេលនោះ ថាប្រទេសកម្ពុជាគឺជាប្រទេសអាណានិគម ពាក់កណ្ដាលអាណានិគម ហើយស្ថិតរងក្រោមនូវឥទ្ធិពលចក្រពត្តិរបស់អាមេរិក។ ខ្ញុំសូមដកស្រង់ "បេសកកម្មរបស់បដិវត្តន៍កម្ពុជាគឺធ្វើការជំរុញពួកចក្រពត្តិចេញពីប្រទេស"។

ចំណុចទី២នៅក្នុងសុន្ទរកថារបស់គាត់គឺឃើញមាននៅត្រង់ខ្មែរ 00063138, អង់គ្លេស 0048 6228, បារាំងមានលេខ 00492814។ គឺមានសរសេរដូចខាងក្រោម សូមដកស្រង់៖ "មហាសន្និបាតបានវិភាគ និងសម្រេចអំពីទំនាស់នៅក្នុងសង្គមកម្ពុជាខាងក្នុងសង្គមកម្ពុជាផ្ទាល់។ សង្គមកម្ពុជាជំនាន់ដែលយើងរៀបចំមាគ៌ា គឺមានបែងចែកវណ្ណៈច្បាស់។ វណ្ណៈកម្មករ វណ្ណៈកសិករ វណ្ណៈអធន វណ្ណៈនាយទុន វណ្ណៈសក្តិភូមិ។ ខាងប្រាំវណ្ណៈច្បាប់។ នៅក្នុងវណ្ណៈនេះ មានសមាភាពទំនាស់យ៉ាងម៉េច? មានទំនាស់ស្មុគស្មាញ ទំនាស់កម្មករជាមួយនាយទុន ទំនាស់អធនជាមួយនឹងទំនាស់កម្មករ ហើយនិងអ្នកម្ចាស់ដី។ ទំនាស់ជាមួយប្រជាជនណាច្រើនជាងគេ? វណ្ណៈណាជិះជាន់? វណ្ណៈណាច្រើនជាងគេ?"។

[១១:០២:៤៣]

បន្តខាងក្រោមបន្តិចនៅក្នុងឯកសារដដែលនេះគឺសរសេរថា "គឺម្ចាស់ដីដែលកសិកររងគ្រោះខ្លាំង

ជាងគេ ជាពិសេសឈ្លានពានដោយផ្ទាល់។ ដូច្នេះប្រជាជន៨៥ភាគរយ គឺវណ្ណៈកសិករនេះឯង។ ទំនាស់ជាមួយវណ្ណៈជិះជាន់មួយ ដែលជាជិះជាន់ខ្លួនផ្ទាល់ គឺវណ្ណៈសក្តិភូមិម្ចាស់ដី"។

បន្តទៅទៀតនៅត្រង់ទំព័រខាងក្រោម ប៉ុល ពត បានសរសេរដូចតទៅ៖ "ទំនាស់នេះ គឺជាទំនាស់ស្លាប់រស់។ វាជាទំនាស់មួយកើតឡើងនៅក្នុងសង្គមកម្ពុជា ហើយដែលវាប៉ះពាល់ប្រជាជន៨៥ភាគរយ។ ដោយសារហេតុផលនេះហើយ ទើបសន្និបាតបក្សលើកទី១ បានលើកឡើងអំពីទំនាស់ដែលកើតមានឡើង។ នេះគឺជាករណីដែលកើតឡើង តើទំនាស់នេះត្រូវដោះស្រាយយ៉ាងណា? កសិករត្រូវតែក្រោកឈរដើម្បីតស៊ូប្រឆាំងទៅនឹងពួកវណ្ណៈកេងប្រវ័ញ្ច គឺពួកសក្តិភូមិម្ចាស់ដី"។

លោកប្រធាន ខ្ញុំប្រហែលជាភ្លេចលើកឡើង។ សហសេវិករបស់ខ្ញុំអាចបង្ហាញឯកសារត្រង់ដែលខ្ញុំដកស្រង់នេះ ចេញទៅតាមអេក្រង់បាន ដើម្បីឱ្យយើងទាំងអស់គ្នាអាចមើលឃើញ និងតាមទាន់ទាំងអស់គ្នា។ ដូច្នេះ ខ្ញុំសង្ឃឹមថាលោកប្រធានអនុញ្ញាត។

[១១:០៤:៣២]

នៅក្នុងកថាខណ្ឌដដែល ចេញពីសុន្ទរកថារបស់លោក ប៉ុល ពត សេចក្តីថ្លែងការណ៍សំខាន់ដែលបង្ហាញអំពីគោលនយោបាយរបស់បក្ស និងការយល់ឃើញចំពោះមេដឹកនាំសាសនា ព្រះពុទ្ធនិងសាសនា។ ប៉ុល ពត បានលើកឡើងដូចតទៅ -- ខ្មែរគឺ 00063141, អង់គ្លេស 00486230, បារាំងមានលេខ 00492816។ សុន្ទរកថានេះគឺមានសរសេរដូចទៅ "ទំនាស់នេះបង្កឱ្យមានកំហឹងខ្លាំង ប៉ុន្តែទំនាស់នេះកប់ដោយសារអី? ដោយសារវណ្ណៈម្ចាស់ដី ពួកនាហ្មឺនកាន់អំណាច និងពួកត្រួតត្រាវណ្ណៈជិះជាន់ ផ្សព្វផ្សាយឱ្យកាយកប់ទំនាស់នេះ។ មនោគមន៍វិជ្ជា ដូចជាថាមកពីអកុសលពីជាតិមុខ មកពីព្រេងសំណាងពីជាតិមុន។ល។ ជាការបំភ័ន្តកសិករមិនឱ្យឃើញទំនាស់"។

ប៉ុន្មានទំព័រខាងក្រោម ត្រង់ខ្មែរ 000631145, អង់គ្លេស 00486233, បារាំង 00492820។ ប៉ុល ពត បានលើកឡើងដូចតទៅ៖"ការវិភាគទំនាស់នៅក្នុងសង្គម នៅក្នុងប្រទេសជាតិកម្ពុជារួចហើយ តើត្រូវកំណត់សត្រូវនៃបដិវត្តន៍យ៉ាងម៉េច និងកម្លាំងបដិវត្តន៍យ៉ាងម៉េច? សត្រូវមានពីរដែលត្រូវវាយ។ សត្រូវទី១ គឺចក្រពត្តិនិយម សេះចក្រពត្តិអាមេរិកាំង។ ទី២ គឺវណ្ណៈសក្តិភូមិម្ចាស់ដី និងកុំប្រាដ័រប្រតិកិរិយា"។ បញ្ចប់ការដកស្រង់។

[១១:០៧:០៨]

សុន្ទរកថានេះបានបន្តលើកឡើងអំពីរបៀបថាតើបុគ្គលមួយចំនួននៅក្នុងវណ្ណៈនាយទុន និងវណ្ណៈ

ម្ចាស់ដីនោះ តើស្ម័គ្រចិត្តក្រោកឈរប្រឆាំងនឹងខ្មាំងដោយរបៀបណា? ហើយគេបានប្រើប្រាស់ពួកនេះដើម្បីជាយុទ្ធសាស្ត្រ យុទ្ធវិធី បង្កើតជាសម្ព័ន្ធមិត្តរបស់ខ្លួន។

នៅទំព័របន្ទាប់ ប៉ុល ពត បានយោងលើប្រភេទខ្មាំងចំនួនបី ដែលបក្សបង្កើតឡើងតាមមាគ៌ារបស់ខ្លួន។ សូមដកស្រង់សម្ដី "យើងបានបែងចែកខ្មាំងជាបីប្រភេទ: ទី១) អូសទាញខ្មាំងណាដែលអាចអូសទាញបានក្នុងឱកាសខ្លះ ទី២) អព្យាក្រឹត្យពួកខ្លះ កុំឱ្យវាធ្វើសកម្មភាពអីវាយយើងក្នុងពេលដែលយើងអាចអព្យាក្រឹត្យបាន ទី៣) ឯកកោពួកអាឃោរឃៅ ដើម្បីវាយវាយ"។ បញ្ចប់ការដកស្រង់។

ខ្មែរ 00063148 ដល់ 49, អង់គ្លេស 00486263 ដល់ 67 (*ស៊ីក*), បារាំង 00492824។ ប៉ុល ពត បានរៀបរាប់អំពីទម្រង់នៃការតស៊ូបដិវត្តន៍ ដែលបក្សបានសម្រេចប្រើប្រាស់ដើម្បីធ្វើការវាយប្រហារនិងប្រយុទ្ធនឹងខ្មាំង។ បាននិយាយ និងសរសេររៀបរាប់ដូចតទៅ "សន្និបាតលើកទី១ របស់យើងគឺបានកំណត់ការតស៊ូរបស់បដិវត្តន៍របស់យើងដូចតទៅ៖ រូបភាពតស៊ូទី១ គឺត្រូវប្រើប្រាស់ហិង្សាបដិវត្តន៍ដោយនយោបាយ ហើយនិងហិង្សាបដិវត្តន៍ដោយអាវុធ គឺយើងតស៊ូនយោបាយផង តស៊ូអាវុធផងដោយប្រើហិង្សាបដិវត្តន៍។ ហិង្សានេះ គឺកម្លាំងដើម្បីទប់ទល់វាយខ្មាំង។ រូបភាពតស៊ូទី២ គឺមានរូបភាពតស៊ូដោយស្របច្បាប់ ពាក់កណ្ដាលស្របច្បាប់ មិនស្របច្បាប់ ដោយយកមិនស្របច្បាប់ជាមូលដ្ឋាន"។

[១១:០៩:៥៣]

ហើយបន្តទៅដល់កថាខណ្ឌខាងក្រោម "រូបភាពទី៣ គឺការតស៊ូជំហរ ការតស៊ូពាក់កណ្ដាលជំហរ និងតស៊ូសម្ងាត់ដោយយកសម្ងាត់ជាមូលដ្ឋាន"។ ប៉ុល ពត ក៏បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសុន្ទរកថានេះផងដែរអំពីការយល់ឃើញរបស់បក្សថាខ្មាំងនៅតាមទីក្រុងក្នុងប្រទេសកម្ពុជា។

ខ្មែរមានលេខ 00063150 ទៅដល់ 51, អង់គ្លេស 00486238, បារាំង 00492826 សូមដកស្រង់៖ "មាគ៌ាអនុវត្តរបស់យើងគឺថានៅតាមទីជនបទគឺជាមូលដ្ឋានគាំទ្រ។ ហេតុអ្វីបានជាយើងយកជនបទជាមូលដ្ឋាន? ហេតុអ្វីមិនយកក្រុងជាមូលដ្ឋានទ្រទ្រង់? ក្រុងមិនអាចប្រើប្រាស់ជាមូលដ្ឋានបង្អែកនោះទេ។ ប្រជាជនច្រើនមែនប៉ុន្តែវាតូច ខ្មាំងនៅពេញ សត្រូវក៏នៅហ្នឹង។ សភាក៏នៅទីហ្នឹង តុលាការក៏នៅហ្នឹង គុកច្រវាក់ក៏នៅហ្នឹង ប៉ូលិសទាហានក៏នៅហ្នឹង គ្រប់ទាំងអស់។ សំណាញ់របស់ខ្មាំងវាណែនណាស់ ហើយវណ្ណភាពនៅទីក្រុងចម្រុះស្មុគស្មាញ។ ឯនៅជនបទធំទូលាយ ខ្មាំងស្តើងណាស់ភូមិខ្លះគ្មានខ្មាំងទេ គ្មានទាហានទេ។ ឃុំខ្លះមានតែទាហានម្នាក់ ពីរនាក់ ឬក៏ប៉ូលិសម្នាក់ពីរនាក់តែប៉ុណ្ណោះ។ នៅតាមជនបទមានភាពទន់ខ្សោយ កសិករមានច្រើន វណ្ណៈចម្រុះគឺល្អនៅក្នុងជនបទ"។

[១១:១២:១៤]

ខ្មែរ00063160 ដល់ 61, អង់គ្លេស 00486245 ដល់ 46, បារាំងមានលេខ 00492834 ទៅដល់ 35។ ប៉ុល ពត បានរៀបរាប់អំពីយុទ្ធសាស្ត្រយោធាប្រើប្រាស់ក្នុងការវាយខ្មាំង។ ហើយជាពិសេសនៅក្នុងខែនិងឆ្នាំដែលឈានទៅដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥។ រៀបរាប់ដូចតទៅ៖ “រីឯមាគ៌ាវាយខ្មាំងវិញបក្សយើងកំណត់ថា វាយខ្មាំងទាំងខាងយោធា ទាំងខាងនយោបាយ។ ពង្រឹងប្រជាជនពីខ្មាំងទាំងខាងសេដ្ឋកិច្ច ផ្តាច់ស្បៀងខ្មាំងទាំងការកម្ចាត់ខ្សែចារកម្មផ្សេងៗរបស់ខ្មាំង”។

បន្តទៅក្រោយបន្តិចនៅក្នុងកថាខ័ណ្ឌដដែលនេះគឺ “ស្បៀងរបស់ពួកគេក៏កាន់តែអស់ រហូតដល់អស់រលីង។ ត្រូវអាមេរិកជាចៅហ្វាយវាដឹកជញ្ជូន មកឲ្យវារៀងរាល់ខែ យ៉ាងត្រដាបត្រដួសបំផុត។ គិតជាមធ្យមត្រូវដឹក ៤ម៉ឺនតោនក្នុង១ខែ សម្រាប់តែពួកវានៅភ្នំពេញមួយក្រវេច។ ចំពោះមាគ៌ាប្រយុទ្ធវាយខ្មាំងបក្សយើងបានលើក និងកំណត់បានពិស្តារ តាមគ្រប់រូបភាពដើម្បីវាយខ្មាំងក្នុងឋានៈម្ចាស់ការ។ វាយសម្រុកជាប់ ច្នៃប្រឌិត និងគំនិតផ្តើមរាល់ពេលវេលា។ ហើយនៅក្នុងសមរភូមិគឺវាយសំបូរបែបផង វាយឈ្លបផង ដោយយកវាយឈ្លបជាមូលដ្ឋានស្អេកស្កះ និងវាយសំបូរបែបដើម្បីកម្ទេចខ្មាំងរស់របស់ខ្មាំង វាយធំផង វាយមធ្យមផងវាយតូចផង រួមផ្សំគ្នាបណ្តាក់ដូចខ្យង”។

[១១:១៤:៥៣]

នៅជិតចុងក្រោយនៃសន្ទរកថានេះ ខ្មែរ00063163 ទៅដល់ 64, អង់គ្លេស 00486248, បារាំងមានលេខ 00492837។ ប៉ុល ពត បានផ្តល់នូវការសង្ខេបអំពីមាគ៌ាគន្លឹះសំខាន់ៗរបស់បក្សដែលបានលើកឡើងនាសន្និបាតលើកទី១។ “មានមាគ៌ារបស់បក្សនៅឆ្នាំ១៩៦០ ចែងថា៖ ១) ធ្វើបដិវត្តន៍ប្រជាជាតិ ដោយកម្ចាត់ចក្រពត្តិ ពិសេសចក្រពត្តិអាមេរិកឲ្យផុតពីប្រទេសជាតិ។ ២) ធ្វើបដិវត្តន៍ប្រជាធិបតេយ្យ គឺវាយរបបសក្តិភូមិម្ចាស់ដី និងកុំប្រាដ័រ ប្រតិកិរិយា ឲ្យរលំរលាយពីសង្គមកម្ពុជា។ យើងបានសម្រេចការ កិច្ចភារកិច្ចបដិវត្តន៍ទាំងពីរនេះ ទាំងស្រុងនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ហើយ”។ បញ្ចប់ការដកស្រង់។

លោក លោកស្រីចៅក្រម ជាទីគោរព! ពីរបីថ្ងៃក្រោយថ្លែងសុន្ទរកថានេះ ប៉ុល ពត បានធ្វើដំណើរទៅប្រទេសចិន។ នៅចុងទស្សនកិច្ចនោះ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៧៧ គាត់បានធ្វើសន្និសីទកាសែតនៅប្រទេសចិន ត្រង់ឯកសារ E3/2072។ ឯកសារនេះមួយផ្នែកនោះ គឺថាបានបង្ហាញជូនលោក លោកស្រីចៅក្រមទៅហើយ។ ខ្ញុំដកស្រង់ចំណុចមួយចំនួនតែប៉ុណ្ណោះ។ គឺឯកសារចេញមកពី

ឈុនហ័រ – សារព័ត៌មាន ឈុនហ័រ*(តាមសូរស័ព្ទ)* ហើយបន្ទាប់មកមានបកប្រែកដោយភ្នាក់ងារចិន ស៊ី.អិន.អេ។ ឯកសារនេះបានផ្សព្វផ្សាយនៅ ប៊ី.ប៊ី.ស៊ី ផងដែរ នៅក្នុងឆ្នាំ១៩៧៧ ខែតុលា របាយ-ការណ៍នេះបានបង្ហាញថា អៀង សារី, វន វ៉េត ក៏មានវត្តមានដែរ នៅពេលធ្វើសន្និសីទកាសែតនាពេលនោះ។

[១១:១៧:១៥]

នៅក្នុងពេលនោះ ប៉ុល ពត បានលើកឡើងអំពីមាគ៌ាបក្សសំខាន់ៗជាមួយនឹងខ្លាំង។ ដោយគាត់លើកឡើងត្រង់ខ្មែរ 00296201 ទៅដល់02, អង់គ្លេស S00080547, បារាំង S00648890។ ប៉ុលពត បានលើកឡើងដូចតទៅ៖ “ក្រោយពីវិភាគ និងសិក្សាលើសភាពការណ៍បដិវត្តន៍អន្តរជាតិ និងសភាពការណ៍ជាក់ស្តែងលើកម្ពុជាកន្លងមក យើងចាប់ផ្តើមបំពេញភារកិច្ចដើម្បីបដិវត្តន៍ប្រជាធិបតេយ្យ ហើយជាពិសេសគឺកំណត់នូវគោលដៅទៅលើបដិវត្តន៍”។ បន្តទៅក្រោមទៀត “យើងបានធ្វើការតស៊ូទាំងសម្ងាត់ និងទាំងចំហ ក៏ប៉ុន្តែយើងក៏បានធ្វើការតស៊ូស្របច្បាប់ និងខុសច្បាប់ផងដែរ។ យើងបានវាយប្រហារ តស៊ូ ពីសន្តិវិធីទៅជាហិង្សា រួមទាំងការតស៊ូនយោបាយ និងការតស៊ូប្រដាប់អាវុធ ហើយការតស៊ូប្រដាប់អាវុធ គឺជាមូលដ្ឋានចម្បងរបស់យើង”។

ប៉ុល ពត នៅក្នុងពេលធ្វើសន្និសីទក៏បានលើកឡើងអំពីបក្ស លើកឡើងអំពីនិន្នាការធ្វើការផ្លាស់ប្តូរពីកុម្មុយនីស្តទៅជាសង្គមនិយម “ចំពោះយើងយើងមិនដឹងជាដើរផ្លូវណាទេ បើសិនបើយើងមិនមានគោលជំហរច្បាស់លាស់”។

[១១:១៩:០៤]

ឯកសារ E3/11747 -- E3/147 រួមទាំងរបាយការណ៍ដែលថ្លែងឡើងដោយ នួន ជា នៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៨ ជាពិសេសនៅពេលប្រារព្ធខួបកងទ័ពបដិវត្តន៍កម្ពុជា ហើយបានផ្សព្វផ្សាយនៅក្នុងវិទ្យុកម្ពុជាក្នុងភ្នំពេញនាពេលនោះ។ នៅក្នុងសុន្ទរកថានោះ នួន ជា បានលើកឡើងអំពីយុទ្ធ-សាស្ត្រ និងយុទ្ធវិធីរបស់បក្ស ហើយខ្ញុំនឹងអានការដកស្រង់ខ្លីមួយតែប៉ុណ្ណោះ។ ខ្មែរគឺ 00679796, អង់គ្លេស 00168467, បារាំង 00698446។ សុន្ទរកថានេះ នួន ជា បានលើកឡើងដូចតទៅ៖ “យើងមានជំហរច្បាស់លាស់ដើម្បីធ្វើការកម្ទេចបណ្តេញពួកចក្រពត្តិអាមេរិក ពួកបរិវាររបស់វា និងពួកកេងប្រវ័ញ្ច។ ប្រសិនបើយើងតស៊ូតែមួយមុខមិនជោគជ័យនោះទេ។ ខ្មាំងប្រើប្រាស់ប្រដាប់អាវុធ និងឧបករណ៍ផ្តាច់ការដើម្បីធ្វើការបង្ក្រាប និងកម្ទេចប្រជាជនយើង។ ដោយសារហេតុនេះក្រោយឆ្នាំ១៩៦០

អង្គការបដិវត្តន៍យើងបានសម្រេចច្បាប់ថា យើងត្រូវប្រើសកម្មភាពនយោបាយ និងអំពើហិង្សាប្រដាប់អាវុធដើម្បីផ្តួលរលំ និងកម្ទេចខ្មាំង”។

ឯកសារមួយក្រុមទៀតដែលខ្ញុំនឹងបង្ហាញនោះគឺ ទស្សនាវដ្តីទង់បដិវត្ត ច្បាប់ចេញផ្សាយផ្សេងទៀតដែលបង្ហាញអំពីមាគ៌ាបក្សប្រើប្រាស់ហិង្សាបដិវត្តន៍ទៅលើខ្មាំង។ ហិង្សាបដិវត្តន៍នេះមិនបានបញ្ចប់ទេ ទោះបីជាក្រោយបក្សកុម្មុយនីស្តកម្ពុជាកាន់កាប់អំណាចនៅថ្ងៃ១៧ ខែមេសា ក៏ដោយ គោលនយោបាយនេះបានបន្តអនុវត្តនៅក្នុងពេញអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១១:២១:៣៩]

ឯកសារដំបូងគឺ E3/760 ចុះខែមិថុនា ឆ្នាំ១៩៧៦។ ផ្នែកទី២នៃទស្សនាវដ្តីនេះ គឺមានមតិយោបល់ និងគោលការណ៍ណែនាំលើកឡើងដោយអ្នកតំណាងបក្សនៅក្នុងពេលធ្វើកិច្ចប្រជុំនៅតាមភូមិភាគធ្វើឡើងនៅដើមខែមិថុនា ឆ្នាំ១៩៧៦។ ខ្មែរ ERN 00062848, អង់គ្លេស 00509614, បារាំង 00487759។ តំណាងបក្សបានលើកឡើងនូវចំណុចមួយចំនួនដូចខាងក្រោមពាក់ព័ន្ធនឹងស្ថានភាពសភាពការណ៍ខ្មាំង។ ខ្ញុំសូមដកស្រង់សម្តី៖ “តើតទៅមុខខ្មាំងវាធ្វើយ៉ាងណាទៀត? វាខ្លាំងឬថមថយ? យើងអាចឆ្លើយថា ខ្មាំងនឹងធ្វើសកម្មភាពប្រឆាំងយើង ប្រឆាំងបដិវត្តន៍យើងតាមរូបភាពផ្សេងៗ។ នេះជាការតស៊ូរវាងបដិវត្តន៍ និងប្រឆាំងបដិវត្តន៍តទៅទៀតគ្មានឈប់ឈរ។ ត្រូវបំពាក់គោលជំហរនេះ ថាខ្មាំងនៅតែមាន១០ឆ្នាំ ២០ឆ្នាំ ៣០ឆ្នាំតទៅទៀត។ ការតស៊ូផ្នែកប្រជាជាតិ ក៏ដូចជាការតស៊ូវណ្ណៈនិយាយមួយម៉ាត់គឺការតស៊ូរវាង -- ការតស៊ូបដិវត្តន៍ប្រឆាំងនឹងបដិវត្តន៍នៅមានតទៅទៀត។ តើវាខ្លាំងឬមិនខ្លាំង? បញ្ហានេះមិនមែនអាស្រ័យលើវាទេ គឺអាស្រ័យលើយើង។ បើយើងមានវិធានការដាច់ខាតជាបន្តបន្ទាប់ ខ្មាំងវានឹងថមថយទៅ។ វានឹងខ្ចាត់ខ្ចាយខ្ទេចខ្ទីជាបន្តបន្ទាប់”។

[១១:២៤:០២]

បន្ទាប់ឯកសារ E3/742 គឺខែមេសា ១៩៧៧ ទង់បដិវត្ត ដែលក្នុងនោះមានសុន្ទរកថាថ្លែងដោយតំណាងបក្សនៅខួបលើកទី២នៃជ័យជម្នះ១៧ មេសា។

នៅផ្នែកទី១នៃសុន្ទរកថានេះគឺ ERN ជាភាសាខ្មែរ 0006298 -- ម្តងទៀត 00062985 ដល់ 86, អង់គ្លេស 00478495 ដល់ 96, បារាំង 00499753 ដល់ 54។ សុន្ទរកថានេះ គឺបាននិយាយដូចតទៅ សូមដកស្រង់៖ “សម្រាប់ខ្មាំង គឺពួកវាបានទទួលការបរាជ័យយ៉ាងខ្លាំងក្នុងរយៈពេល៣ខែកន្លងទៅនេះ ឃើញច្បាស់ថាពួកខ្មាំង កា.ហ្សេ និងពួកយួនបានទទួលការបង្ក្រាប និងបរាជ័យយ៉ាងធ្ងន់ធ្ងរ”។

បន្តទៅកថាខណ្ឌបន្ទាប់ទៀត សូមដកស្រង់៖ "ពួកខ្មាំង ខ្មាំងគ្រប់ប្រភេទនេះវាខិតខំកសាងចារកម្មទាំងបឹងខ្សែធំរបស់វា បង្កប់ស៊ីរូងបំផ្លិចបំផ្លាញបក្ស បដិវត្តន៍ និងកងទ័ពយើងអស់រយៈ២៧ឆ្នាំកន្លងមកហើយ។ ហើយត្រូវយើងរកឃើញនិងកម្ទេចជាមូលដ្ឋាននៃត្រីមាសទី១ នៃឆ្នាំ១៩៧៧ នេះ"។

បន្តទៅទំព័របន្ទាប់ទៀត សូមដកស្រង់៖ "ចំពោះខ្មាំងដែលជា សេ.អ៊ី.អា និង កា.ហ្ស.បេ និងភ្នាក់ងារយួន ពួកអាឆ្កែចោកទាបនេះគឺថាបានជ្រៀតចូលនៅក្នុងបដិវត្តន៍ និងជួរបដិវត្តន៍របស់យើង។ គឺពួកវាគឺថាមានការបាត់បង់យ៉ាងខ្លាំងដោយសារតែការកម្ទេចជាមូលដ្ឋានរបស់យើង។ ហើយពួកនេះគឺថានៅតែកំពុងតែរាត់រាយដូចជាកណ្ដុរដែលត្រូវគេបោះចូលទៅក្នុងទឹកអីយ៉ាងដូច្នេះដែរ។ យើងត្រូវតែបន្តវាយពួកវាយតទៅទៀតពីជំហរដាច់ខាតរបស់យើង ហើយត្រូវតែការពារប្រឆាំងជាមួយពួកវា ជាពិសេសក្នុងឆ្នាំ១៩៧៧ ដើម្បីវាយកម្ទេចពួកវាឲ្យកាន់តែខ្លាំងទៀត ដើម្បីកុំឲ្យពួកវាងើបរួច"។ បញ្ចប់ការដកស្រង់។

[១១:២៧:០៧]

នៅផ្នែកខាងក្រោមនៃសុន្ទរកថាដដែល ERN ជាភាសាខ្មែរ 00062990 ដល់ 91, អង់គ្លេស 00478500 ដល់ 01, បារាំង 00499757 ដល់ 58។ កម្មាភិបាលត្រូវបានណែនាំដូចតទៅនេះ សូមដកស្រង់៖ "អតីតកាលកន្លងមកធ្វើឲ្យយើងបានកាន់តែយល់ល្អប្រសើរ និងច្បាស់ យល់ឃើញច្បាស់ឡើង ទោះបីជាខ្មាំងផ្ទៃក្នុងទទួលបរាជ័យតាំងពីមុនយ៉ាងណាក៏ដោយ ពួកគេមិនបោះបង់យុទ្ធសាស្ត្រដើម្បីជំទាស់ទៅនឹងបដិវត្តន៍កម្ពុជារបស់យើងទេ។ ពួកវាជាផ្នែកមួយនៃ សេ.អ៊ី.អា, កា.ហ្សេ.បេ និងផ្នែកមួយនៃខ្មាំងយួន នៅតែខិតខំតស៊ូបន្តសកម្មភាពឧក្រិដ្ឋរបស់ពួកវាតទៅទៀត។ នេះគឺជាយល់ឃើញដោយយើងត្រូវយល់ឲ្យបានច្បាស់ ដើម្បីឲ្យមានស្មារតីខ្ពស់ ប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ប្រឆាំង និងកម្ចាត់ខ្មាំង ដើម្បីឈានទៅកាន់ភាពម្ចាស់ការ"។

បន្តទៅកថាខណ្ឌមួយខាងក្រោមនេះ សូមដកស្រង់៖ "ក្នុងពេលនេះយើងនឹកឃើញទៅដល់ផែនការរបស់យើងដូចតទៅនេះ៖ ក) គឺដាច់ខាតត្រូវតែយល់ឃើញថាជំហររបស់យើងគឺខ្មាំង ចំពោះខ្មាំងគឺខ្ពស់ជាប់ជានិច្ច ហើយយើងត្រូវតែម្ចាស់ការ និងវាយប្រយុទ្ធគ្រប់ពេលវេលាប្រឆាំងចំពោះខ្មាំង។ ខ) មានទស្សនៈច្បាស់លាស់ចំពោះខ្មាំងសត្រូវទាំងក្នុង ទាំងក្រៅ និងក្នុងចំណោមប្រជាជន។ គ) មានទស្សនៈច្បាស់លាស់ចំពោះខ្មាំងសត្រូវទាំងក្នុងទាំងក្រៅ និងឃើញធាតុពិតរបស់វាជាទំនាស់ស្លាប់រស់។ ឃ) ត្រូវតែដាច់ខាតចំពោះខ្មាំងសត្រូវ បំផុសមហាជន និងរកខ្មាំង ពិនិត្យខ្មាំង វិភាគខ្មាំងតាមដានខ្មាំង

គាបសង្កត់ខ្មាំង ចាប់ខ្មាំង និងកម្ទេចខ្មាំង ធ្វើឲ្យខ្មាំងទៅជាកណ្តុលក្នុងរូងហ៊ុមព័ទ្ធវាយកម្ទេចរបស់របស់ប្រជាជនដ៏កុះករ"។ បញ្ចប់ការដកស្រង់។

[១១:៣០:២៣]

ពីរបីខែក្រោយមកទៀត នៅខែមិថុនា ឆ្នាំ១៩៧៧ ក្នុងទង់បដិវត្តនេះ គឺឯកសារ E3/135, ខ្មែរ ERN 0062802 ដល់ 03, អង់គ្លេស 00446857, បារាំង 00487719។ "ការបោះពុម្ពផ្សាយបានផ្តល់ធ្វើការវាយតម្លៃចំពោះការខំខិតប្រឹងប្រែងប្រយុទ្ធជាមួយនឹងខ្មាំងផ្ទៃក្នុង។ នៅក្នុងជួរយើងបដិវត្តល្អជាងមុន កាន់តែប្រសើរ។ ប្រជាជនមូលដ្ឋានជាច្រើន ហើយប្រជាជនមូលដ្ឋានច្រើនទៀត គឺថាបានស្វែងរកខ្មាំងទាំងអស់នេះ គឺកំពុងតែប្រយុទ្ធដើម្បីស្វែងរកខ្មាំង"។

បន្តមកកថាខណ្ឌខាងក្រោមទៀត សូមដកស្រង់៖ "ប៉ុន្តែខ្មាំងដែលបង្កប់ស៊ីរូងផ្ទៃក្នុងមិនទាន់អស់នៅឡើយទេ។ កម្លាំងជើងចាស់របស់យើងគឺថា ខ្មាំង យល់ឃើញថា ខ្មាំងទាំងអស់នេះ មិនទាន់បាត់ទាំងអស់នៅឡើយទេ។ មិនជាច្រើនទេ ប៉ុន្តែខ្លះនៅកំពុងតែរាត់រាយនៅតាមមូលដ្ឋាន និងអង្គភាព ក្រសួងក៏ដូចជាមន្ទីរផ្សេងៗ។ តើយើងស្វែងរកខ្មាំងទាំងអស់នេះក្នុងពេលខាងមុខដោយរបៀបណាមួយ? គឺថាដាច់ខាត ត្រូវតែមានជំហរដាច់ខាតដើម្បីវាយប្រយុទ្ធជាមួយខ្មាំងបង្កប់ដែលមិនទាន់អស់ទេ។ សំណល់ចាស់របស់ខ្មាំងបង្កប់នៅសល់ ហើយវាពង្រឹង ពង្រីកតទៅទៀត។ ពីរ ត្រូវមានវិធានការដាច់ខាត គ្មានសម្រុះសម្រួល គ្មានអធ្យាស្រ័យ គ្មានញើតញញើមអ្វីទាំងអស់"។

នេះខ្មែរ 0062830, អង់គ្លេស 00446879, បារាំង 00487744។ ថ្នាក់ដឹកនាំបក្សបានផ្តល់ការណែនាំដូចខាងក្រោម សូមដកស្រង់៖ "សំណូមពរក្នុងឆមាសទី២ ឆ្នាំ៧៧នេះ ត្រូវយកចិត្តទុកបោសសម្អាតខ្មាំងឲ្យអស់ជាមូលដ្ឋាន នៅតាមមូលដ្ឋានផ្សេងៗ ពិសេសនៅក្នុងសហករណ៍តែម្តង"។ បញ្ចប់ការដកស្រង់។

[១១:៣៣:៣១]

នៅក្នុងទង់បដិវត្តដដែលនេះ គឺ E3/135។ "ថ្នាក់ដឹកនាំបក្សក៏បានកំណត់អតីតព្រះសង្ឃដែលវណ្ណៈ -- ជាផ្នែកមួយនៃវណ្ណៈមូលធន និងបញ្ជាក់ថាវណ្ណៈនេះអាចជាវណ្ណៈមួយដែលជាខ្មាំងនៅក្នុងជួរបក្ស"។ គឺ ERN ជាភាសាខ្មែរ 00062805 ដល់ 06, អង់គ្លេស 00446859 ដល់60 និងបារាំង 00487722 ដល់23។ ផ្នែកទី៤នៃឯកសារនេះគឺសរសេរដូចតទៅ សូមដកស្រង់៖ "ឈរលើបទពិសោធន៍ដែលយើងវាយខ្មាំងបង្កប់កន្លងមក។ បញ្ហាវណ្ណភាពកាន់តែចោទជាបញ្ហាសំខាន់ណាស់ទៀត

កន្លងមកពួកខ្មាំងបង្កប់ច្រើនជាសមាសភាពវណ្ណៈអធន”។

ហើយបន្តទៅកថាខណ្ឌចុងក្រោយនៃផ្នែកទី៤នៃទង់បដិវត្តនេះ សូមដកស្រង់៖ “នេះគឺជាប្រភពដែលខ្មាំងអាចបង្កប់គ្រប់ឱកាសបាន។ ទោះបីជាមួយអាពួកអនុធនក្តី ឬក៏ពួកវណ្ណៈអធននេះ គឺថាមាននៅក្នុងជួរព្រះសង្ឃ ឬក៏ពួកពាណិជ្ជករតូចតាច។ យោងតាមបទពិសោធន៍នេះ យើងត្រូវតែប្រកាន់ជំហរដាច់ខាតចំពោះបញ្ហាវណ្ណៈនៅក្នុងជួរបក្ស។ កាលពីមុនមក យើងអនុវត្តមាគ៌ានយោបាយបក្ស ប៉ុន្តែមានការស្ទាក់ស្ទើរ។ ប៉ុន្តែចាប់ពីពេលនេះតទៅ យើងត្រូវតែអនុវត្តមាគ៌ានយោបាយបក្សប្រឆាំងជាមួយវណ្ណៈនេះឲ្យបានជាដាច់ខាត។” បញ្ចប់ការដកស្រង់។

[១១:៣៥:៥៥]

ហើយពីឆ្នាំ១៩៧៨ ឯកសារ E3/727 គឺឯកសារចុះខែមិថុនា ឆ្នាំ១៩៧៨ នៅក្នុងទង់បដិវត្តដែលយើងឃើញថា ការគោលនយោបាយកម្ចាត់ខ្មាំងហ្នឹង គឺថានៅតែមានដដែរ។ ERN ជាភាសាខ្មែរ 00064556, អង់គ្លេស 00185323 ដល់ 24 និងបារាំង 00524450 ដល់ 51។ ការបោះពុម្ពផ្សាយរបស់បក្សគឺយោងតាមបទពិសោធន៍ទី១ គឺសូមដកស្រង់ដូចតទៅ “បទពិសោធន៍ការប្រយុទ្ធរបស់យើងជាហូរហែពីមុន ពិសេសចាប់ពីរំដោះមកទាល់នឹងបច្ចុប្បន្ននោះ យើងប្រយុទ្ធបាន១ឆ្នាំ រវាងយើង និងខ្មាំងតឹងតែងជាប់រហូតមកដល់បច្ចុប្បន្ន យើងវាយកម្ទេចវាច្រើនផ្ទាំងថែមទៀត”។

ហើយបន្តពីរបី កថាខណ្ឌមកខាងក្រោម សូមដកស្រង់៖ “វិធានការដែលយើងអនុវត្ត គឺមិនខុសពីវិធានការពីមុនមកនោះទេ។ ប៉ុន្តែយើងត្រូវតែសម្រួចសម្រាវ កម្ទេចខ្មាំងផ្ទៃក្នុងឲ្យបានស្រួចស្រាវថែមទៀត”។

[១១:៣៧:៤៣]

ហើយនៅក្នុងសេចក្តីណែនាំនិយាយអំពីកាតព្វកិច្ច ភារកិច្ចជាសំខាន់ ដែលមាន ERN ជាភាសាខ្មែរ 00064578 ដល់ 79, អង់គ្លេស 00185342 ដល់ 43, បារាំង 00524469 ដល់ 70។

ការបោះពុម្ពផ្សាយនេះ គឺសរសេរដូចតទៅ សូមដកស្រង់ “ភារកិច្ចរបស់យើង ដូច្នេះគឺវាយកម្ទេចពួកភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារយួន និងភ្នាក់ងារ កា.ហ្សេ.បេ។ នេះជាដាច់ខាតខ្លាំងក្លា ជាបន្តបន្ទាប់ វាយហើយវាយទៀត វាយវារលំរលាយ ហើយរលំរលាយជាបន្តបន្ទាប់។ លុះត្រាតែវាយៗយ៉ាងនេះបានកម្លាំងចាស់របស់វាត្រូវខ្ទេចខ្ទី ហើយកម្លាំងនៅសេសសល់របស់វា ក៏ត្រូវខ្ទេចខ្ទីទៀតកម្លាំងថ្មីមួយទៀត។ យើងស្ថិតនៅក្នុងស្ថានភាពសម្រុក ម្ចាស់ការ ហើយឈានទៅមុខជាន់ខ្មាំងដណ្តើម

យកជ័យជម្នះជាបន្តបន្ទាប់។ ឯពួកខ្មាំងវិញត្រូវខ្ទេចខ្ទីរ ខ្ចាត់ខ្ចាយ និងរលំរលាយ"។ បញ្ចប់ការដកស្រង់។

ទង់បដិវត្តដែលបានចេញផ្សាយនេះ គឺបញ្ជាក់សំខាន់ទៅលើបញ្ហាវៀតណាមដែលជាគោលដៅ។ ERN ជាភាសាខ្មែរគឺ 00064567, អង់គ្លេស 00185323 និងបារាំង 00524460។ ផ្នែកដែលមានចំណងជើងថា តើកម្លាំងកងទ័ពរបស់យើងជំទាស់ជាមួយបក្សដោយរបៀបម៉េច? កម្លាំងអ្វីខ្លះដែលប្រឆាំងជាមួយបដិវត្តន៍យើង? សូមដកស្រង់ដូចតទៅ "ជាសង្ខេបគូទំនាស់ជាមួយយើងគឺ សេ.អ៊ី.អា, យួន និងកា.ហ្សេ.បេ ហើយនៅក្នុងនេះពិសពុលស្រួចស្រាវជាងគេគឺយួន ឈរលើការវិភាគទំនាស់ស្លាប់រស់ស្រួចស្រាវនេះ តើវិធានការរបស់យើងវាយវាយ៉ាងម៉េចតទៅទៀត? ១) វាយស្រួចស្រាវជាងគេគឺយួនឈ្លានពានវាត ទីលេបទឹកដី។ ២) ព្រមជាមួយគ្នានេះ វាយសេ.អ៊ី.អា និងកា.ហ្សេ.បេ។ វាយព្រមជាមួយគ្នា ប៉ុន្តែយកចិត្តទុកដាក់ជាងគេគឺយួន ពីព្រោះវាស្រួចស្រាវពិសពុលជាងគេ"។

[១១:៤១:00]

ហើយនៅក្នុងទង់បដិវត្តន៍ចុះខែកក្កដា ឆ្នាំ១៩៧៨ ឯកសារ E3/746 -- ជាភាសាដុតរោលដែលបក្សបានប្រើដើម្បីកំណត់គោលដៅទៅលើពួកវៀតណាម។ នៅក្នុងអត្ថបទដើមដំបូងនៃលេខចុះផ្សាយនេះគឺតួនាទីរបស់យើងទាំងអស់គ្នា។ ERNជាភាសាខ្មែរ 00064486 ដល់ 87, អង់គ្លេស 00428289, បារាំង 00611871។ ការបោះពុម្ពផ្សាយនេះគឺមានដូចតទៅសូមដកស្រង់៖ "ខ្មាំងយួនបានប្រព្រឹត្តការឈ្លានពានឈោរឃៅនិងលេបទឹកដី និងប្រព្រឹត្តអំពើ ប្រល័យពូជសាសន៍ប្រឆាំងជាមួយនឹងជាតិសាសន៍កម្ពុជាយើងពីមួយជំនាន់ទៅមួយជំនាន់។ គេគឺជាខ្មាំងសួព្វជរបស់យើងតាំងពីមុនរហូតដល់បច្ចុប្បន្ន ហើយនិងជាខ្មាំងទៅថ្ងៃមុខ ទៅអនាគតទៀត"។

បន្តបីកថាខណ្ឌមកខាងក្រោម សូមដកស្រង់៖ *"ភារកិច្ចជាតិរបស់យើងទាំងអស់គ្នាគឺដើម្បីប្រឆាំងវាយប្រយុទ្ធកម្ទេចចំពោះពួកវាតទីនិយមលេបទឹកដី និងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ គឺពួកខ្មាំងយួន"*។

[១១:៤២:៥២]

ហើយ ERNត្រង់ភាសាខ្មែរ 00064502, អង់គ្លេស 00428303 ដល់ 04, បារាំង 00611884 ថ្នាក់ដឹកនាំបក្សបានផ្តល់មតិយោបល់ សូមដកស្រង់៖*"ភាសាដែលដុតរោលចំពោះបញ្ហាកំហឹងដែលក្លាយទៅជាចលនាមហាជនដ៏ធំធេងដើម្បីកម្ទេចពួកវាតទីនិយមលេបទឹកដីខ្មាំងយួន និងបោសសម្អាតឲ្យជ្រះស្រឡះ ខ្មាំងបង្កប់ក្នុងជួរ"*។

អង្គជំនុំជម្រះជាទីគោរព! ឯកសារដែលពាក់ព័ន្ធត្រូវបង្ហាញទៅនឹងមាគ៌ានយោបាយបក្សពាក់ព័ន្ធទៅនឹងខ្មាំង ហើយនិងការប្រើប្រាស់អំពើហិង្សាបដិវត្តន៍ គឺតំណាងទៅដល់ការយល់ដឹងជារួមនៅក្នុងចំណោមថ្នាក់ដឹកនាំបក្សដែលត្រូវអនុវត្តនៅទូទាំងផ្ទៃប្រទេសតែម្តង គឺឯកសារE3/130។ ដូច្នេះ ខ្ញុំនឹងមិនចំណាយពេលវេលាទៅលើឯកសារនេះក្រៅតែពីការលើកឡើងនូវមាត្រា៦(១)នៃលក្ខន្តិកៈ។ សូមដកស្រង់៖ “បក្សកុម្មុយនីស្តកម្ពុជា គឺថាប្រកាន់គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំធ្វើជាមូលដ្ឋានចាត់តាំងរបស់ខ្លួន។ ហើយមាត្រា៦នេះគឺថា គ្រប់អង្គការដឹកនាំរបស់បក្សត្រូវអនុវត្តរបបដឹកនាំសមូហភាព”។ បញ្ចប់ការដកស្រង់។

[១១:៤៥:00]

អស់លោកលោកស្រីចៅក្រមជាទីគោរព! ឯកសារមួយប្រភេទទៀត ដែលយើងខ្ញុំនឹងបង្ហាញជូន គឺជាឯកសារដែលបានជ្រើសរើសថា តើអង្គការសំខាន់ៗនីមួយៗនៃបក្សកុម្មុយនីស្តកម្ពុជា ទាំងគណៈមជ្ឈិម ក៏ដូចគណៈអចិន្ត្រៃយ៍ក្រសួង អង្គភាពយោធា ក៏ដូចភូមិភាគមួយៗ ថាតើផ្នែកនីមួយៗនេះបានយល់ស្រប និងបានចូលរួមនៅក្នុងផែនការដែលបានចែករំលែកគ្នាដើម្បីកម្ទេចខ្មាំងនៅក្នុងជួរបក្សដោយរបៀបណានោះ។ ខ្ញុំសូមចាប់ផ្តើមជាមួយនឹង គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍។ ដែលឯកសារភាគច្រើននៃឯកសារទាំងនេះ គឺជាឯកសារដែលបានដឹងរួចរាល់ហើយ។ ដូច្នេះយើងខ្ញុំមិនលើកឡើងលម្អិតនោះទេ។

ឯកសារ E3/1173 ជាឯកសារចុះថ្ងៃទី២៧ កុម្ភៈ ១៩៧៦ ពីគណៈកម្មាធិការ៨៧០ ជាសេចក្តីណែនាំពីមន្ទីរ៨៧០ លេខ០២/៧៦ គឺនិយាយអំពីការទម្លាក់គ្រាប់បែក ឬក៏ការផ្ទុះគ្រាប់បែកនៅខេត្តសៀមរាប នៅក្នុងអំឡុង ២៦ ខែកុម្ភៈ ៧៦ ដែលគណៈអចិន្ត្រៃយ៍នេះ (នៅក្នុងឯកសារនេះ) ថាបណ្តាលមកពីកប៉ាល់ហោះចម្បាំងអាមេរិកាំង។ ឯកសារចុងក្រោយ គឺមានការណែនាំដូចតទៅ សូមដកស្រង់៖ “គណៈអចិន្ត្រៃយ៍សូមឲ្យប្រើការតាមដាន និងអប់រំកម្មាភិបាលក្នុងបក្ស កម្មាភិបាលស្នូល កងទ័ព មហាជន ដើម្បីឲ្យមានកំហឹងចំពោះខ្មាំងស្រួចស្រាវគ្រប់ពេលវេលា។ កសាងជំហរបដិវត្តន៍ តាមដានជាដាច់ខាត”។ បញ្ចប់ការដកស្រង់។

[១១:៤៧:០៩]

មួយសប្តាហ៍ក្រោយពីឯកសារនេះចេញរួចមក គឺនៅថ្ងៃទី០៨ មីនា ឆ្នាំ៧៦ គណៈអចិន្ត្រៃយ៍បានកោះប្រជុំ។ កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ គឺនៅក្នុងឯកសារ E3/232។ កំណត់ហេតុ

នេះ "គឺបង្ហាញអំពីអ្នកចូលរួមនៅក្នុងអង្គប្រជុំ រួមមានលេខាបក្ស ប៉ុល ពត, អនុលេខាបក្ស នួន ជា, ខៀវ សំផន ហៅ ហែម, អនុប្រធានភូមិភាគ ៣០៣ មានសមមិត្ត ស្រេង និងប្រធានតំបន់ ១០៦ សៀមរាប និងតំបន់ព្រះវិហារ ដែលបានរាយការណ៍ជូនបក្សអំពីស្ថានភាពនៅក្នុងតំបន់របស់ខ្លួន។ នៅក្នុងតំបន់ -- នៅក្នុងចំណុច ២.១ ស្រេង ដែលជាភូមិភាគ -- មេភូមិភាគកណ្ដាល និយាយអំពីក្រុមពីរនៅក្នុងភូមិភាគរបស់ខ្លួន។ ក្រុម អាឈឿន និងគ្នាវា ៣៤នាក់ ដែលកងទ័ពភាគចាប់ខ្លួនបានអស់ហើយ។ ហើយពួកអាអ៊ុក មឿន ហៅ អ៊ុក ហុង ដែលប៉ុនប៉ងរត់ទៅវៀតណាមខាងត្បូង និងគ្នាវាប្អូនប្រាំនាក់ទៀត ហើយស្នើមតិណែនាំរបស់អង្គការ។

នៅក្នុងផ្នែក២.២ នៃកំណត់ហេតុនៃទំព័រខាងក្រោមនេះ សមមិត្ត សុត លេខាតំបន់សៀមរាប ឬក៏ថាតំបន់១០៦ រាយការណ៍អំពីស្ថានភាពខ្លាំងនៅក្នុងតំបន់របស់គាត់ ហើយទាក់ទងទៅនឹងការផ្ទុះគ្រាប់ ឬក៏ទម្លាក់គ្រាប់បែកនៅសៀមរាប (ដែលខ្ញុំយោងឯកសារពីមុនអម្បាញ់មិញនេះ)។ សមមិត្ត សុត បានរាយការណ៍ថា មិនមានដានច្បាស់លាស់ចំពោះការផ្ទុះគ្រាប់បែកនៅថ្ងៃទី២១ កុម្ភៈ នៅសៀមរាបនោះទេ"។ បញ្ចប់ការដកស្រង់។

[១១:៤៩:៣៩]

ហើយនៅក្នុងផ្នែកបន្ទាប់នៃកំណត់ហេតុ ផ្នែក២.៣ លេខាភូមិភាគ១០៣ រាយការណ៍ និង៣០៣ រាយការណ៍អំពីស្ថានភាពខ្មាំងនៅតាមព្រំដែនថៃ ជាពិសេសប្រាសាទព្រះវិហារ មិនមានសកម្មភាពអ្វីទេ ប៉ុន្តែពួកវាបានបញ្ជូនគិញដែលជាជនជាតិថៃចូលមកទឹកដីយើង យើងបានចាប់ខ្លួន។ សូមដកស្រង់៖ "ចាប់តាំងពីខែមករា មកគឺថាយើងចាប់បានជាង១00នាក់ហើយ"។

ហើយក្រោយពីរបាយការណ៍ចេញអំពីតំណាងតំបន់នីមួយៗ នៅផ្នែក៣.១ នៃកំណត់ហេតុនេះ គណៈអចិន្ត្រៃយ៍បានផ្ដល់ការណែនាំដូចតទៅទាក់ទងទៅនឹងបញ្ហានៅក្នុងភូមិភាគ -- នៅក្នុងតំបន់៣០៣។ សូមដកស្រង់ "ជាវិធានការត្រូវហៅអ្នកដែលមានឈ្មោះមកសាកសួរ តើឆ្លើយយ៉ាងម៉េច? យើងមិនទាន់ដកពីតំណែកទេ។ បន្ទាប់មកហៅមកសាកសួរទៀតនៅចំពោះមុខចោទ ហើយចាំមើលតើមានប្រតិកម្មយ៉ាងណា? ដូច្នេះមានពីរដំណាក់កាល។ ១) សួរហើយទុកមួយកន្លែងសិន ហើយរាយការណ៍មកខាងលើ ដោយមានសំណុំរឿងមកផង"។ បញ្ចប់ការដកស្រង់។

[១១:៥១:០៨]

ឯកសារបន្ទាប់មកទៀត ដែលធ្លាប់បានដឹងគឺ E3/12 ជាឯកសារចុះថ្ងៃទី៣0 ខែមីនា ៧៦

ជាសេចក្តីសម្រេចរបស់គណៈមជ្ឈិម។ ផ្នែកទី១ និយាយអំពីសិទ្ធិសម្រេចកម្មេចក្នុងជួរ និងក្រៅជួរ។

បាទ ខ្ញុំនឹងសូមរំឭកឡើងវិញ ទាក់ទងទៅនឹងសិទ្ធិសម្រេចកម្មេចគឺគណៈមជ្ឈិមបាននិយាយដូចតទៅ “ប្រសិនណាជានៅមូលដ្ឋាន អាចសម្រេចដោយគណៈកម្មាធិការភូមិភាគ។ ជុំវិញមជ្ឈិមគឺត្រូវសម្រេចដោយគណៈមជ្ឈិម។ នៅក្នុងតំបន់ឯករាជ្យត្រូវសម្រេចដោយគណៈអចិន្ត្រៃយ៍។ ជួរកងទ័ពត្រូវសម្រេចដោយអគ្គសេនាធិការ ដោយសេនាធិការ”។

ឯកសារនេះបានដាក់ជូនអង្គជំនុំជម្រះរួចហើយ ដោយសារវាទាក់ទងទៅនឹងអាទិភាពនៃសហឧក្រិដ្ឋកម្មរួម ឬក៏ផែនការរួមនៅក្នុងចំណោមសមាជិកនៃគណៈមជ្ឈិម និងអង្គការដទៃទៀតដែលបង្កើតបានទៅជាកម្ពុជាប្រជាធិបតេយ្យដើម្បីកម្មេចជួរខ្មាំងទាំងក្នុងជួរ និងក្រៅជួរ។

[១១:៥២:៣៦]

ឯកសារ E3/763 ជាឯកសារដែលចេញដោយគណៈមជ្ឈិមនៅថ្ងៃទី៣០ មីនា ៧៦។ បាទ ដូច្នេះក្នុងពេលនេះ ខ្ញុំសូមអានតែចំណងជើងនៃឯកសារនេះតែប៉ុណ្ណោះ។ សូមដកស្រង់ “សេចក្តីណែនាំរបស់គណៈអចិន្ត្រៃយ៍បក្សនៃបក្សកុម្មុយនីស្តកម្ពុជាអំពីគោលនយោបាយបក្ស ចំពោះអ្នកដែលយល់ខុសដែលចូល សេ.អ៊ី.អា ចូលយួន ឬចូលជាមួយ កា.ហ្សេ.បេ ហើយប្រឆាំងជាមួយនឹងបក្សបដិវត្តន៍កម្ពុជាប្រឆាំងជាមួយនឹងប្រជាជនយើង”។

ឯកសារមួយទៀតចេញពីគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ ដែលខ្ញុំសូមបង្ហាញជូនផងដែរ ដែលពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់បក្សពាក់ព័ន្ធទៅនឹងព្រះពុទ្ធសាសនាគឺ E3/99 ដែលជាសេចក្តីណែនាំលេខ៦ ចុះថ្ងៃទី២២ កញ្ញា ៧៥, មានចំណងជើងថា “តាមដានការអនុវត្តមាគ៌ានយោបាយ និងកងទ័ពប្រជាធិបតេយ្យ”។ ERN ជាភាសាខ្មែរ 00072402, អង់គ្លេស 00244275, បារាំង 00611 567។ សេចក្តី -- សារាចរណែនាំនេះ--

[១១:៥៤:៤១]

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន ផ្អាកបន្តិចសិន!

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំអន្តរាគមន៍ដោយគោរពទៅនឹងសេចក្តីសម្រេចរបស់តុលាការ

កាលពីព្រឹកមិញ ហើយដោយសារចំណងជើងអត្ថបទនេះទាក់ទងនឹងការអនុវត្តគោលនយោបាយ។ អ៊ីចឹង គាត់បង្ហាញអត្ថបទនេះ ហាក់ដូចជាប្រាស់ចាកពីការសម្រេចរបស់ចៅក្រមកាលពីព្រឹកមិញលោកប្រធាន។

**លោក ខេល លីសាក់៖**

ខ្ញុំសូមឆ្លើយតបទៅនឹងមេធាវី ខៀវ សំផន។ បញ្ហានេះជាបញ្ហាបច្ចេកទេស។ ពាក្យថា "អនុវត្ត" ដែលមាននៅត្រង់នេះ មានន័យថាឯកសារនេះមិនមែនមាននិយាយអំពីបញ្ហានេះ ហើយមិនមែនមានន័យថាឯកសារនេះជាឯកសារមិនវិភាគទៅលើមាគ៌ានយោបាយរបស់បក្សនោះទេ។ គឺថាដោយសារឯកសារនេះវាផ្ទុះបញ្ចាំងអំពីគោលនយោបាយរបស់បក្ស ហេតុដូច្នេះឯងបានជាខាងតំណាងសហព្រះរាជអាជ្ញាលើកឡើងយ៉ាងដូច្នេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៦:៣៤]

**ប្រធានអង្គជំនុំ៖**

ការបង្ហាញឯកសារនេះគឺស្ថិតនៅក្នុងវិសាលភាពនៃការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងកាលពីព្រឹកមិញ។ ដូច្នេះសេចក្តីជំទាស់ក្នុងការដាក់បង្ហាញឯកសារនេះរបស់មេធាវីការពារក្តីលោក ខៀវ សំផន មិនត្រឹមត្រូវទេ។ សូមលោកតំណាងសហព្រះរាជអាជ្ញាបន្តការដាក់ការបង្ហាញឯកសារបន្តទៅទៀត។

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអានសម្រង់ខ្លីនៅក្នុងឯកសារនេះ ហើយទើបខ្ញុំនឹងបង្ហាញជូននូវឯកសារថ្មីទៀត។ សូមដកស្រង់ចេញពីសារាចរណែនាំរបស់បក្ស សូមដូចតទៅ៖ "វត្តអារាមដែលជាបង្អែកលោកសង្ឃត្រូវលះបង់ចោលជាច្រើន មូលដ្ឋានបង្អែករបស់ព្រះពុទ្ធសាសនាត្រូវលះបង់ចោល ប្រជាជនលែងទៅវត្ត លែងធ្វើបុណ្យ ហើយគិតតែពីធ្វើទំនប់ ធ្វើប្រឡាយ។ បង្អែកនេះត្រូវខ្ចាត់ខ្ចាយ ព្រះពុទ្ធសាសនាត្រូវបាត់បង់។ បញ្ហានយោបាយ មូលដ្ឋានសេដ្ឋកិច្ច មូលដ្ឋានវប្បធម៌ត្រូវគាស់ឲ្យរលីងដល់អ៊ីចឹងចលនាវាទៅមុខ ហើយមិនងាកថយក្រោយទេ។ ដូច្នេះគឺជាភាសាសំខាន់ៗ។ ដូច្នេះសង្គមយើងប្រែមិនមានអ្វីដែលគួរឲ្យព្រួយបារម្ភទៀតទេ"។

[១១:៥៨:២៧]

ខ្ញុំសូមចូលទៅប្រភេទឯកសារផ្សេងទៀតលោកប្រធាន ប៉ុន្តែដោយសារដល់ពេលម៉ោងសម្រាក

ពិសាបាយថ្ងៃត្រង់ហើយ តើគួរសម្រាកសិនឬក៏យ៉ាង? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងឲ្យនាំខ្លួនគាត់ត្រឡប់ចូលមកសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥៩ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក ឌេល លីសាក់៖**

សូមគោរពលោកប្រធាន។ ខ្ញុំសូមចូលទៅឯកសារដែលបង្ហាញអំពីគោលនយោបាយប្រឆាំងនឹងខ្មាំងនៅក្នុងក្រសួងនានារបស់កម្ពុជាប្រជាធិបតេយ្យ។ ឯកសារទី១ ដែលខ្ញុំបង្ហាញរសៀលនេះ គឺ E3/818។ បាទ ជាបទបង្ហាញរបស់លេខាបក្ស ប៉ុល ពត នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីដែលប្រព្រឹត្តទៅថ្ងៃទី២២ មេសា ១៩៧៦។ ERN ជាភាសាខ្មែរ 00072756, អង់គ្លេស 00143463, បារាំង 00548896។ ប៉ុល ពត បានណែនាំទៅដល់រដ្ឋមន្ត្រីនៃក្រសួងនានាដូចតទៅ៖ "ដោយមិនគិតពីអ្វីដែលយើងធ្វើល្អ មិនល្អទេ គឺចក្រពត្តិនៅរស់នៅឡើយ ឲ្យតែពួកប្រតិកិរិយាមិនទាន់បានបំបាត់ចោលអស់អំពីចេញពីមុខមាត់នៃពិភពលោកនេះទេ ពួកវានៅតែបន្តប្រឆាំងបដិវត្តន៍ ប្រឆាំងនឹងយើង ប្រឆាំងយើងទាំង

ពីចម្ងាយ។ បាទ យើងទារប្រឆាំងទាំងអ្វីៗទាំងអស់”។

[១៣:៣៤:១០]

ខ្មែរ 00072760 ដល់61, អង់គ្លេស 00548896, បារាំង 00548899 ដល់900។ ប៉ុល ពត បានធ្វើការណែនាំទាក់ទងទៅដល់ភារកិច្ចរបស់រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យដែលមានសរសេរដូចតទៅ៖ “ត្រូវការពាររដ្ឋអំណាចបដិវត្តន៍ ការពារបក្ស ការពារប្រជាជន ការពារកងទ័ព និង ឯករាជ្យភាព ប្រធិបតេយ្យភាព ប្រឆាំងរាល់ទម្រង់នៃសកម្មភាពរបស់ខ្មាំង ទាំងខ្មាំងលាក់មុខ ខ្មាំងចេញមុខ។ យើងត្រូវតែមានស្មារតីបដិវត្តន៍ខ្ពស់ ត្រូវតែម្ចាស់ការ”។ បញ្ចប់ការដកស្រង់។

ឯកសារពីរទៀត គឺបង្ហាញអំពីគោលនយោបាយប្រឆាំងនឹងខ្មាំងនៅក្រសួងការបរទេស។ គឺឯកសារ E3/522, ជាកំណត់ត្រារបស់កម្មាភិបាលមកពីក្រសួងការបរទេសជាឯកសារមួយវែង។ បាទ ខ្ញុំសូមអានចំណុចមួយខ្លីទេដែលជាកំណត់ត្រារបស់កម្មាភិបាលចូលប្រជុំនៅមហាសន្និបាតមួយ នៅថ្ងៃទី១៨ មករា ៧៧។ ERN ជាភាសាខ្មែរ 00427940 ដល់ 41, អង់គ្លេស 00003330 ដល់ 31, និងភាសាបារាំង 00657902។ នេះគឺជាផ្នែកមួយនៃសន្និបាតនៅក្រសួងការបរទេស ដែលមាននិយាយដូចតទៅ សូមដកស្រង់៖ “នៅឆ្នាំ១៩៧៦ គឺជាឆ្នាំគន្លឹះ ខ្មាំងឥឡូវនេះចុះខ្សោយហើយ ហើយវានឹងឈានទៅរកការងាប់ហើយ។ បដិវត្តន៍យើងចាក់ឫសយ៉ាងជ្រៅ ហើយពួកប្រតិកិរិយាទាំងអស់ត្រូវបានកម្ទេច។ ខ្មាំងវណ្ណៈទាំងអស់គឺថាត្រូវលុបបំបាត់អស់ហើយ។ ប៉ុន្តែនៅតែមានពួកចក្រពត្តិអាមេរិក ពួកលោកសេរី ពួកកា.ហ្សេ.បេ និងពួកវៀតណាម។ ទោះបីជាពួកវាបរាជ័យក៏ដោយ ពួកវានៅតែរាំងដល់យើង។ ចំណុចមួយទៀត គឺថាខ្មាំងវាស្ថិតនៅក្នុងខ្លួនរបស់យើង នៅក្នុងជួរកងទ័ពយើង នៅក្នុងកម្មករនៅសហករណ៍ និងនៅក្នុងជួរកម្មាភិបាល ដែលធ្វើឲ្យបក្សបដិវត្តន៍សង្គមនិយម -- ដើម្បីធ្វើឲ្យបដិវត្តន៍សង្គមនិយាយខ្លាំង និងរឹងមាំ គឺថាត្រូវតែដោះស្រាយជាមួយខ្មាំងទាំងនេះឲ្យបានឆាប់រហ័ស”។

[១៣:៣៧:៣១]

គឺត្រូវបន្តមកផ្នែកខាងក្រោម “សមាជក្រសួងគឺនិយាយអំពីការទំនាស់គ្នា និងការទំនាស់ផ្ទៃក្នុង។ ការទំនាស់ផ្ទៃក្នុងដូចខាងក្រោម ការទំនាស់ផ្ទៃខាងក្រោម គឺដែលប្រឆាំងជាមួយនឹងបដិវត្តន៍។ បើសិនណាមានការទំនាស់បែបនេះ យើងត្រូវតែបញ្ជូនទៅដល់មន្ទីរសន្តិសុខឲ្យដោះស្រាយ មានន័យថា ត្រូវស្រាវជ្រាវវែកមុខ វែករកខ្សែសង្វាក់ជាប្រព័ន្ធ។ ទំនាស់បែបនេះមិនត្រូវធ្វើការអប់រំអីនោះទេ”។ បញ្ចប់ការដកស្រង់។

ឯកសារ E3/857 ជារបាយការណ៍ការមកពីក្រសួងការបរទេសមានចំណងជើងថា “ធ្វើការជាមួយគណៈកម្មាធិការ គ្រប់គណៈកម្មការទាំងអស់”។ ផ្នែកទី១នៃឯកសារនេះមានចំណងជើងថា “សកម្មភាពខ្មាំង” គឺចាប់ផ្តើមដូចខាងក្រោម។ សូមដកស្រង់ “ក្នុងសន្និបាតក្រសួងយើង យើងបានកត់សម្គាល់ថាយើងបានកម្ទេច និងបោសសម្អាតជាមូលដ្ឋានខ្មាំងដែលជា សេ.អ៊ី.អា, កា.ហ្សេ.បេ និងយួនលេបទឹកដី។ យើងកម្ទេចទាំងបោសសម្អាតខ្មាំងជាមូលដ្ឋាន មានន័យថាក្បាលម៉ាស៊ីនធំៗ ខ្មាំងដែលធ្វើផែនការ និងចង់ -- យើងហេតុដូច្នេះឯង យើងត្រូវតែកម្ទេច និងបោសសម្អាតនៅគ្រប់អង្គភាពទាំងអស់ អង្គភាពនីមួយៗ។ ដូច្នេះ វាស្អាតជ្រះស្រឡះក្នុងក្រសួង”។

[១៣:៣៩:៣០]

បន្តមកផ្នែកខាងក្រោមពាក់ព័ន្ធទៅនឹងសកម្មភាពខ្មាំងនេះដែរ។ “និយាយរួមក្រសួងរបស់យើងមានការភ្ញាក់ផ្អើលខ្ពស់ដែរ មានភេទអ្វីបន្តិចបន្តួចបងប្អូនចេះចាប់អារម្មណ៍ លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ ហើយរាយការណ៍។ ឧទាហរណ៍ ខ្មាំងវាបន្លឺថាបន្តិចទៀតចាប់អស់ហើយ នៅតែបងខៀវ សំផន ទេដែលត្រូវគេ -- ដែលមិត្តយើងមិនចេះវិភាគ ហើយរាយការណ៍។ ដល់យើងចាប់ហើយសួរចម្លើយ យើងឃើញខ្សែខ្មាំងយ៉ាងច្បាស់លាស់”។

លោក លោកស្រីចៅក្រម ពាក់ព័ន្ធទៅនឹងផ្នែកពាក់ព័ន្ធទៅនឹងខ្មាំងនេះ ក៏មានលើកឡើងនៅក្នុងឯកសារមួយចំនួនមកពីក្រសួងពាណិជ្ជកម្មផងដែរ។ ឯកសារ E3/1110 គឺឯកសារ E3/1110 ជារបាយការណ៍មកពីកិច្ចប្រជុំក្រសួងពាណិជ្ជកម្ម ដែលធ្វើឡើងនៅថ្ងៃទី២៥ ដល់ថ្ងៃទី២៦ កក្កដា ១៩៧៦។ របៀបវារៈទី១ នៅក្នុងកិច្ចប្រជុំនេះ គឺនិយាយអំពីស្ថានភាពខ្មាំង ហើយនៅក្នុងផ្នែកស្តីអំពីស្ថានភាពខ្មាំងនេះ គឺយើងអាចរកបាននៅ ERN ភាសាខ្មែរ 00381695 ដល់ 96, អង់គ្លេស 00583829, បារាំង 00766077 ដល់ 78។

[១៣:៤១:៣៨]

ត្រង់ផ្នែកនេះ គឺមានលើកឡើងដូចតទៅ សូមដកស្រង់ “សកម្មភាពរបស់សមាសភាពមិនល្អ គឺថាបានចុះខ្សោយហើយក្រោយពីយើងចាត់វិធានការ និងការអប់រំ”។ បញ្ចប់ការដកស្រង់។ ហើយជាពិសេសព្រឹត្តការណ៍ជាក់ស្តែង សូមដកស្រង់ “ពួកអា អ៊ិន តាំ” គឺគេយោងទៅលើពួកមហាក្បត់មួយក្នុងចំណោមពួកមហាក្បត់ទាំងប្រាំពីរនៃរបបលន់នល់។ ទាក់ទងទៅនឹងវិធានការនៅពេលដើម្បីដោះស្រាយខ្មាំង ឯកសារបញ្ជាក់ថា -- សូមដកស្រង់ “ការពិនិត្យ និងការចម្រាញ់ប្រវត្តិរូបគឺថាត្រូវតែពង្រឹង”។

ឯកសារ E3/846 -- E3/846 ជាសេចក្ដីព្រាងចុះរបាយការណ៍ចុះថ្ងៃទី២៤ តុលា ១៩៧៦ នៃរបាយការណ៍សហការដែលមានរយៈពេល១០ថ្ងៃ។ ផ្នែកទី១ នៃរបាយការណ៍នេះគឺនិយាយអំពីស្ថានភាពខ្មាំង ដែលចាប់ផ្ដើមរាយការណ៍ថា -- សូមដកស្រង់ "ពួកធ្លាប់ជិតស្និទ្ធជាមួយពួកខូច ដែលយើងដកហូតពីមុនពីក្រសួងនៅតែមានហេតុភេទជាច្រើន"។

កថាខណ្ឌពីរខាងក្រោមមកទៀត គឺរាយការណ៍អំពីបុគ្គលម្នាក់ៗដែលត្រូវបញ្ជូនទៅមន្ទីរអប់រំរៀនសូត្រ ដោយបញ្ជាក់អំពីឈ្មោះអ្នកដែលត្រូវបញ្ជូនទៅរៀនសូត្រ បានកត់សម្គាល់បញ្ជីដែលរាយជូនអង្គការនៅថ្ងៃទី២១ តុលា ១៩៧៦។

[១៣:៤៣:២៩]

នៅទំព័រទី២ នៃឯកសារនេះ កថាខណ្ឌស្ដីអំពីខ្មាំងនៅក្នុងអង្គភាព គឺសរសេរដូចតទៅ សូមដកស្រង់៖ "ពួកដែលជិតស្និទ្ធជាមួយ ពួកដែលមិនល្អនៅតែមានសញ្ញាណជាច្រើន ដែលថាពួកគេសេរី ស្មុគស្មាញ ហើយមិនធ្វើការ។ ក្រសួងបានចាត់វិធានការបន្ថែម ដោយបញ្ជូនពួកគេទៅមន្ទីរអប់រំរៀនសូត្រ និងបានរាយជូនអង្គការនៅថ្ងៃ២១ តុលា"។

ហើយឯកសារមួយទៀតគឺ E3/174 និងឯកសារ E3/1962 គឺជារបាយពីក្រសួងដែលរាយ-ការណ៍អំពីឈ្មោះកម្មាភិបាលដែលបញ្ជូនទៅកន្លែងមន្ទីរអប់រំកែប្រែ។ ឯកសារ E3/174 គឺរបាយការណ៍របស់ក្រសួង ដែលថាក្រោយពីពិគ្រោះយោបល់ជាមួយផ្នែកទាំងអស់ គឺថាបានសម្រេចបញ្ជូនកម្មា-ភិបាលទាំងនេះទៅមន្ទីរអប់រំកែប្រែនៅថ្ងៃទី១៧ តុលា ១៩៧៦។ បុគ្គលមួយចំនួនគឺបាន -- នៅក្នុងបញ្ជីឈ្មោះនេះបាននិយាយថា មានទំនាក់ទំនងជាមួយអ្នកដែលគេត្រូវបានចាប់ខ្លួនពីមុនរួចមកហើយនោះ។ ឧទាហរណ៍ដូចជានៅផ្នែកទីពីរនៃឯកសារ E3/174 នេះ កម្មាភិបាលម្នាក់ដែលគេបញ្ជូនទៅរៀនសូត្រនោះបានរៀបរាប់ដូចតទៅនេះ៖ "បុគ្គលម្នាក់ឈ្មោះ ឡោម អនុក្រុមឃ្លាំងអង្ករគឺជាជំនិតរបស់ អាអឿន មេក្បត់នៅផ្សារថ្មីដែលត្រូវចាប់ខ្លួនហើយ"។

[១៣:៤៥:៣៨]

ឯកសារ E3/962 ក៏ជារបាយការណ៍មកពី ក្រសួងពាណិជ្ជកម្មដែលនិយាយអំពីក្រសួងបានបញ្ជូន -- នៅថ្ងៃដដែល -- គឺសូមដកស្រង់៖ "បានចាប់ខ្លួន និង បញ្ជូនទៅមន្ទីរសន្តិសុខដើម្បីសួរចម្លើយយកព័ត៌មានបន្ថែម"។ ខុសពីបញ្ជីដទៃទៀតនោះ គឺថាមនុស្សមួយចំនួននៅក្នុងបញ្ជីនេះគឺថាមានការជាប់ពាក់ព័ន្ធឬក៏មានបណ្ដាញការងារជាប់ទាក់ទងទៅនឹងអ្នកដែលគេចាប់ខ្លួនពីមុនហើយនោះ។

លោក លោកស្រីចៅក្រម! ឯកសារមួយប្រភេទទៀតដែលខ្ញុំនឹងបង្ហាញជូន បង្ហាញអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ហើយនិងគោលនយោបាយចំពោះខ្មាំងនៅក្នុងជួរកងទ័ព ប្រជាជនបដិវត្តន៍កម្ពុជារួមទាំងនៅអគ្គសេនាធិការដ្ឋានផងដែរ។

ឯកសារទី១ ដែលសំខាន់ដែលត្រូវលើកយកមកបង្ហាញជូនអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងគោលនយោបាយចំពោះខ្មាំង គឺឯកសារ E3/5 ចុះខែសីហា ១៩៧៥ គឺទង់បដិវត្តន៍ដែលក្នុងនោះមានសុន្ទរកថាថ្លែងដោយ ប៉ុល ពត ទៅកាន់កងទ័ពប្រជាជនបដិវត្តន៍កម្ពុជានៅឆ្នាំ១៩៧៥ គឺ ERN ជាភាសាខ្មែរ 00063328, អង់គ្លេស 004091 (*ស៊ីក*), បារាំង00538966 -- និយាយអំពីគោលនយោបាយបក្សសូមដកស្រង់៖ "កងទ័ពបដិវត្តន៍យើងកកើតឡើង មកពីមាគ៌ានយោបាយជាយុទ្ធសាស្ត្រនៃបក្សកុម្មុយនីស្តកម្ពុជាដែលបានចែងនៅក្នុងខ១ថា -- ក្នុងវង់ក្រចក (ខ្មាំងវាប្រើហិង្សាវាយប្រហារអំពើឃោរឃៅជានយោបាយនិងជាយោធា ជាអាវុធដើម្បីជិះជាន់កាប់សម្លាប់បំផ្លិចបំផ្លាញប្រជាជនយើង បក្សយើង។ ហេតុដូច្នេះបក្សត្រូវតែចាត់វិធានការគឺត្រូវប្រើហិង្សាជានយោបាយ ដើម្បីសងឈាមវិញ ជានយោបាយក្តី ជាយោធាក្តី។) គឺមានន័យថាបក្សត្រូវប្រើហិង្សាបដិវត្តន៍ ត្រូវប្រមូលប្រជាជន ប្រើហិង្សាបដិវត្តន៍ប្រឆាំងពួកប្រតិកិរិយា ពួកវណ្ណៈជិះជាន់ ប្រឆាំងពួកអាណានិគមចក្រពត្តិនិយម"។

[១៣:៤៨:៤៥]

នៅក្នុងសុន្ទរកថានេះដដែល ERN ជាភាសាខ្មែរ 00063340 ដល់ 42, អង់គ្លេស 00401501, និងបារាំង 00538975 ដល់76។ ប៉ុល ពត បានណែនាំដល់កងទ័ពបដិវត្តន៍ប្រជាជនថា បក្សកុម្មុយនីស្តកម្ពុជាគឺកាន់កាប់អំណាចហើយនៅពេលនេះគឺសូមដកស្រង់ដូចតទៅ "ភារកិច្ចទី១ ភារកិច្ចចម្បងរបស់កងទ័ពគឺការពារប្រទេស។ យ៉ាងម៉េចបានជាត្រូវការពារប្រទេស បើប្រទេសយើងរំដោះទាំងស្រុងហើយ។ នៅពេលដែលយើងបានកម្ចាត់កម្ចាយពួកចក្រពត្តិនិយម គឺថាមិនមានអ្នកណានៅទីនោះទៀតទេ។ ប៉ុន្តែបញ្ហាមិនមែនយ៉ាងដូច្នោះទេ។ យើងបានរំដោះប្រទេសទាំងស្រុងហើយ ប៉ុន្តែស្ថានភាពសង្គ្រាមនៅតែមិនទាន់ល្អនៅឡើយដែលថាពួកចក្រពត្តិនិងពួកអាណានិគមនិយមទាំងថ្មីទាំងចាស់នៅតែមានដដែល"។

[១៣:៥០:០៦]

ហើយបន្តមកកថាខណ្ឌខាងក្រោម "ពួកចក្រពត្តិ ហើយនិងពួកវណ្ណៈជិះជាន់ គឺថាត្រូវបានកម្ទេចនិងកម្ចាត់ហើយ ក៏ប៉ុន្តែទោះបីជាកម្ចាត់បែបនេះក៏ដោយ តើពួកគេបាត់ទាំងស្រុងទេ មិនត្រូវឡប់

មកវិញទេឬ? មិនមែនយ៉ាងដូច្នេះទេ។ ពួកវាត្រូវបានកម្ចាត់ អង្គការរបស់វាត្រូវបានកម្ចាត់របបរបស់វាហើយ ប៉ុន្តែមុខមាត់របស់វាជំហររបស់វា និងផែនការរបស់វាដើម្បីប្រឆាំងជាមួយបដិវត្តន៍ ហើយនិងដណ្ដើមរដ្ឋអំណាចមកវិញ គឺនៅតែដដែល នៅសល់ដដែល។ គេប្រើតាមគ្រាប់រូបភាពជាចំហ ជាសម្ងាត់ ជាផ្ទាល់ ជាប្រយោល ហើយជួនកាលចូលមកក្នុងជួរយើងទៀត”។

ហើយនៅក្នុងកថាខណ្ឌបន្ទាប់ សូមដកស្រង់ “ស្ថានភាពគឺដូច្នេះ ដោយសារតែបញ្ហានេះ កងទ័ពរបស់យើងត្រូវតែបំពេញភារកិច្ចការពារប្រទេសក្នុងជំហរប្រុងប្រយ័ត្នខ្ពស់។ ចំពោះការការពារទីក្រុងភ្នំពេញ និងការកម្ទេចពួកធ្វើវិទ្ធង្សនាដែលចង់បំផ្លិចបំផ្លាញបដិវត្តន៍យើង យើងត្រូវតែបន្តធ្វើឲ្យពួកខ្មាំងបរាជ័យដើម្បីបង្រួបបង្រួមជ័យជម្នះរបស់យើង”។

[១៣:៥១:៣៩]

ឯកសារបន្ទាប់មកទៀត គឺឯកសារដែលពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងអាទិភាពនៃសហឧក្រិដ្ឋកម្មរួមពាក់ព័ន្ធទៅនឹងអង្គការបក្សសំខាន់ៗ ពាក់ព័ន្ធទៅនឹងស-២១។ ឯកសារនេះ គឺ E3/811 -- E3/811 ដែលជាកំណត់ហេតុចុះថ្ងៃទី០៩ កញ្ញា ១៩៧៦ ដែល សុន សេន បានចូលរួមនៅក្នុងកិច្ចប្រជុំនេះ ហើយនិងមានលេខាកងពល៧០៣, ដោយប្រធានស-២១ គឺ ឌុច និងដោយប្រធានស-៧១ ប៉ង់ ដែល -- គឺដោយសារកិច្ចប្រជុំនេះមាននិយាយអំពីការចែកខិត្តប័ណ្ណប្រឆាំងជួយនឹងរបបនោះតែម្ដងនៅតាមបណ្ដោយផ្លូវនៅភ្នំពេញ។ ប្រធានស-២១ – ឌុច – បានកត់សម្គាល់ឃើញថា កម្មាភិបាលមកពីកងពល ១៧០ ចាន់ ចក្រី មានការពាក់ព័ន្ធទៅនឹងការចាប់ខ្លួននេះ នៅក្នុងឧប្បត្តិវហេតុពាក់ព័ន្ធទៅនឹងការចែកចាយខិត្តបណ្ណនេះ។

[១៣:៥៣:០៨]

សុន សេន នៅក្នុងការលើកឡើងរបស់គាត់ត្រង់ទំព័រទី២ បានលើកឡើងថានេះមិនមែនជាបញ្ហាមកពីខាងក្រៅនោះទេ ហើយបានកំណត់អត្តសញ្ញាណមុខសញ្ញាពីរនាក់ដែលត្រូវទទួលខុសត្រូវគឺការជាប់ទាក់ទងទៅនឹងកងពល១៧០ និងកងពល៧០៣ ក៏ដូចជាតំបន់១០៥ គឺបានលើកឡើងដូចតទៅៈ សូមដកស្រង់ “ទី១ ទស្សនៈប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ដោយទំនាស់កាន់តែស្រួចស្រាវណាស់ កំហឹងវណ្ណៈរបស់ខ្មាំងចំពោះបដិវត្តន៍កម្ពុជា គឺទាំងខាងលិច ទាំងខាងកើត កាន់តែខ្លាំងណាស់។ ២) បញ្ហាចាត់តាំងសមមិត្ត ប៉ង់ និង ខាំមី ត្រូវឃើញភារកិច្ចធ្ងន់ធ្ងរខំអប់រំនយោបាយសតិអារម្មណ៍ឲ្យជាប់ គឺថាត្រូវតែក្ដាប់ប្រវត្តិរូប ក្ដាប់សតិអារម្មណ៍ពួកគេឲ្យជាប់ ប្រយ័ត្នកុំឲ្យមានទំនាស់សតិអារម្មណ៍ ហើយនៅខាង

ក្រៅសមមិត្ត ពីន ពិនិត្យអង្គភាពឡើងវិញ។ តើយប់ហ្នឹង ម៉ោងហ្នឹងសកម្មភាពយ៉ាងម៉េច? ទិសរកទិស ខ្សែអាមុខចាស់ គឺយើងត្រូវប្រៀបធៀប។ ខ្ញុំស្នើសុំឲ្យសមមិត្ត ប៉ង់ ទាក់ទងក្រសួងផ្សេងៗពួក១៧០ គួរប្រមូល"។

ដូចខ្ញុំបានលើកឡើងហើយឯកសារនេះ គឺបានជាយើងខ្ញុំលើកឡើងដោយវាពាក់ព័ន្ធទៅនឹងអង្គការផ្សេងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ ថាតើគេនោះបានចូលរួមជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម ការប្រព្រឹត្តិចំពោះខ្មាំងដោយរបៀបណានោះ។

[១៣:៥៥:២២]

ឯកសារE3/822 ជាកំណត់ហេតុចុះថ្ងៃទី១៦ កញ្ញា ១៩៧៦ គឺជាកិច្ចប្រជុំរវាង សុន សេន, ឌុច, កងពល១៧០ គឺលេខាឈ្មោះ សុខ និងកងពល២៩០ លេខាកងពលឈ្មោះ ថាល់។ របៀបវារៈនៃកិច្ចប្រជុំនេះ គឺដើម្បីពិភាក្សា និងសម្រេចអំពីការចាប់ខ្លួនកម្មាភិបាលមួយចំនួនបន្ថែមទៀតពីកងពល១៧០ និងកងពល២៩០។ ហើយនៅទំព័រទី១នៃកំណត់ហេតុកិច្ចប្រជុំនេះ សុន សេន បានផ្តល់យោបល់អំពីស្ថានភាពបច្ចុប្បន្ន គឺបានលើកឡើងដូចតទៅនេះ សូមស្រង់ "ក្រោយយើងចាប់ខ្លួនអា ចក្រី លេខាកងពល១៧០ ដោយមានការជាប់ទាក់ទងជាមួយវៀតណាម និងសូវៀតដើម្បីវាយបដិវត្តន៍យើងនៅថ្ងៃទី៣០ ខែកញ្ញា ១៩៧៦។ ដូច្នេះហើយ មេកងពលនេះគឺថាត្រូវបានចាប់ខ្លួនហើយឈ្មោះ ឈូក ហើយគេបានសារភាពរួចហើយ"។ បញ្ចប់ការដកស្រង់។

កំណត់ហេតុនៃកិច្ចប្រជុំនេះគឺនៅត្រង់ទំព័រទី២ ក្រោយពីប្រជុំ និងមានការយល់ព្រមគ្នាដែលត្រូវចាប់សមាសភាពពីកងពល១៧០ គឺថាយើងត្រូវបានយល់ព្រមដូចតទៅ "យោងតាមផែនការដែលអង្គការបានដាក់ចេញមក រាល់ខ្សែអា ចក្រី ត្រូវតែចាប់ខ្លួនទាំងអស់"។ បញ្ចប់ការដកស្រង់។

[១៣:៥៧:១៨]

កំណត់ហេតុកិច្ចប្រជុំនេះ គឺថាគ្រាន់តែនិយាយអំពីការចាប់ខ្លួនប្រពន្ធ ចក្រី ឈ្មោះ មាស នោះផងដែរ។ ឯកសារនេះក៏បង្ហាញអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម និងការយល់ស្របរបស់មេដឹកនាំកងទ័ពកម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធទៅនឹងគោលនយោបាយចំពោះខ្មាំង គឺឯកសារ E3/13។ ឯកសារ E3/13 គឺជាកំណត់ហេតុកិច្ចប្រជុំចុះថ្ងៃទី០៩ តុលា ១៩៧៦ រវាងលេខា និងអនុលេខាកងពល និងវរសេនាធំនានា វរសេនាធំឯករាជ្យនានា។ ឯកសារនេះគឺថាខ្ញុំមិនចង់លើកឡើងដដែលៗទេ។ ដោយក្នុងនោះក៏មានផ្នែកដែលចាប់ផ្តើម ដែល សុន សេន បានលើកឡើងអំពីការរាយការណ៍លម្អិតជូនមេកងពល

ដោយចោទប្រកាន់អ្នកមួយចំនួន ដែលថាមេកងពល ចក្រី – ១៧០, មេកងពល២៤ ឈ្មោះ ឈូក ហើយនិង -- មេតំបន់២៤ ហើយនិងមេតំបន់ឈ្មោះ យ៉ា, ដែល សុន សេន បានលើកឡើងថា ត្រូវតែមានការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ និងបន្តការវែកមុខចាប់ខ្លួនចំពោះសមាសភាពទាំងនេះ។

អ្វីដែលខ្ញុំចង់ផ្តោតនៅថ្ងៃនេះគឺការឆ្លើយតបពីមេកងពលនានាមកកាន់កងពល អ៎! មកកាន់ សុន សេន គឺបានបង្ហាញអំពីការយល់ព្រមរបស់មេកងពលទាំងនោះជាមួយគោលនយោបាយ។

[១៣:៥៩:១៤]

នៅក្នុងឯកសារ E3/13, ERN ជាភាសាខ្មែរ 00052408, អង់គ្លេស 00183987, បារាំង 00334977 ដល់ 78។ ចំណុចទី១ គឺឆ្លើយតបទៅនឹងលេខាកងពល១៦៤ ឈ្មោះ ឌឿន ដែលឆ្លើយតបទៅនឹង សុន សេន។ “ខ្ញុំសូមចូលរួម -- ខ្ញុំសូមឯកភាពតាមបទឧទ្ទេសនាមរបស់អង្គការ”។ បញ្ចប់ការដកស្រង់។ ឌឹម បានលើកឡើងថា ក្រោយពីការពិនិត្យកងទ័ពរបស់គាត់ -- សូមដកស្រង់៖ “៩០ ទៅ ៩៥ភាគរយគឺថាគួរឲ្យទុកចិត្តបាន ស្មោះត្រង់ជាមួយបក្ស តែជំនឿជ្រះស្រឡះថាកងទ័ពនេះស្អាតហើយដូចនៅមិនទាន់ស្អាតទេ ត្រូវតែតាមដានសម្រិតសម្រាំងតទៅទៀត” បញ្ចប់ការដកស្រង់។

ឯកសារបន្ទាប់គឺសមមិត្ត សុខ គាត់និយាយថា សូមដកស្រង់៖ “កងពល១៧០ គឺថាបានសម្រិតសម្រាំងពួកមិនល្អ៧០នាក់ បញ្ហាអាវុធដកហើយៗ ទុកមួយកន្លែង។ ខ្ញុំឯកភាពជាមួយបក្ស” បញ្ចប់ការដកស្រង់។

[១៤:០០:៥៥]

នៅទំព័របន្ទាប់លេខាកងពល៧០៣ ឈ្មោះ ពីន បានរាយការណ៍ សូមដកស្រង់៖ “ទាក់ទងទៅនឹងបញ្ហាពួកអាក្បត់ និងវិធានការរបស់បក្ស ខ្ញុំយល់ស្របទាំងស្រុងជាមួយបក្ស” បញ្ចប់ការដកស្រង់។

កងពល៥៥០ ឈ្មោះ សួង -- បាទ កងពលឈ្មោះ សួង គឺបានរាយការណ៍អំពីសមាសភាពមិនល្អនៅក្នុងកងពលរបស់គាត់ សូមដកស្រង់៖ “បានចាប់ -- បានឃាត់ខ្លួនហើយ ប៉ុន្តែមិនទាន់បោសសម្អាតទាំងស្រុងទេ”។

កងពល៣១០ ឈ្មោះ អឿន បានលើកឡើងពីបញ្ហាកម្មាភិបាល ប្រវត្តិរូបរបស់ពួកគេ “គឺថាមិនទាន់បានក្តោបក្តាប់ឲ្យច្បាស់លាស់ពេញលេញ ហើយប្រហែលជាវា ពួកនេះនៅស៊ីរូងផ្ទៃក្នុងនៅឡើយ អាចរស់ជាមួយពួកវៀតណាម ឬជាពូជពួកខ្មែរស”។

ហើយនៅក្នុងឯកសារនេះ ERN ជាភាសាខ្មែរ 00052411, អង់គ្លេស 00183990, បារាំង

00334980។ មេកងពល៥០២ ស៊ូ ម៉េត បានលើកឡើងដូចតទៅ សូមដកស្រង់៖ “ក្រោយបក្សបានបង្ហាញខ្សែពួកអាក្បត់ជាមួយពួកចក្រពត្តិអាមេរិក និងពួកសេរីនិយម ខ្ញុំមានការរីករាយនិងកាន់តែជឿលើបក្សឡើងថែមទៀត ពិសោធន៍នេះបញ្ជាក់ថាបក្សយើងក្តាប់បាន មានជំហរប្រុងប្រយ័ត្នជាប់ជានិច្ចបើទំនាស់ក្តាប់ទំនាស់បានច្បាស់ ជាជ័យជម្នះរបស់បក្សយើងហើយ។ ទាក់ទងនឹងបញ្ហានេះកំណត់ថាបើកម្លាត់ខ្មាំងជាមូលដ្ឋានហើយ ត្រូវតែមានវិធានការបន្តទៀតកុំឲ្យមានកើតឡើងជាលើកទី២, ទី៣, ទី៤ និងបន្តទៅទៀត។ គឺថាវាត្រូវតែពង្រឹងបក្សជាដាច់ខាត ទាំងខាងនយោបាយចាត់តាំងសតិអារម្មណ៍ត្រូវតែសម្រិតសម្រាំងដាច់ខាត”។

[១៤:០៣:៣៤]

បន្ទាប់មក ស៊ូ ម៉េត ដែលជាមេកងពល១៦៤ និង មាស មុត -- មាស មុត ក៏បានយល់ស្របថា -- សូមដកស្រង់៖ “គឺការចាប់ខ្លួន គឺជាជ័យជម្នះដ៏ខ្លាំងក្លារបស់បក្សយើង ដែលជាកម្រិតពីជំហរប្រុងប្រយ័ត្នបដិវត្តន៍យើងខ្ពស់មួយកម្រិតទៀត”។ គាត់បានបន្ថែមថា “សមាសភាពមិនល្អ ឬខ្មាំងនៅតែលួចបន្លំបង្កប់ក្នុងជួរបក្សទៀត” ហើយគាត់នៅថា “សុំយល់ព្រម និងឯកភាពជាបក្សទាំងស្រុង ធ្វើម៉េចកុំឲ្យស្ថានភាពជ្រុលហួស” បញ្ចប់ការដកស្រង់។

នៅទំព័របន្ទាប់មកទៀត សុន សេន ឬក៏ហៅថា បង៨៩ បានលើកឡើងដូចតទៅ សូមដកស្រង់៖ “អ្នកដែលមានវត្តមាននៅក្នុងអង្គប្រជុំនេះគឺថាបានយល់ស្របជាមួយបក្សទាំងស្រុង ចំពោះការចាប់ខ្លួនពួកអាខ្មាំងដែលជាជ័យជម្នះ ដែលយើងត្រូវបន្តចំពោះផ្លូវសម្ងាត់ដែលយើងបានធ្វើជាង១០ឆ្នាំកន្លងមកនេះ”។ ហើយគឺនៅត្រង់ខ្មែរ 00052413 ទៅដល់ 15, អង់គ្លេស 00183992 ដល់ 93, ហើយបារាំង 00334982 ដល់ 83។ កំណត់អំពីវិធានការដែលត្រូវដោះស្រាយជាមួយស្ថានភាពខ្មាំង។

[១៤:០៥:៣២]

វិធានការទី១ គឺត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ថែមទៀត សំខាន់បំផុតប្រុងប្រយ័ត្នក្នុងន័យអនុវត្តជាក់ស្តែង។ ដែល សុន សេន បានពន្យល់ដូចតទៅនេះ ខ្ញុំសូមធ្វើការដកស្រង់៖ “ត្រូវក្តាប់ទំនាស់នៅក្នុងសង្គមជាតិយើងឲ្យជាប់ ដើម្បីធានាថាខ្មាំងមិនអាចធ្វើការប្រឆាំង ហើយនិងមិនអាចធ្វើអ្វីដែលគេធ្វើ ធ្វើយ៉ាងណាដើម្បីឲ្យកងកម្លាំងរបស់យើងស្អាតបរិសុទ្ធ។ វិធានការទី២ គឺយើងត្រូវតែយល់ឲ្យច្បាស់អំពីសង្គមរបស់យើង ទាំងការជំទាស់ ក៏ដូចជាការប្រឆាំង ហើយក្នុងនាមជាកងទ័ពយើងត្រូវតែដឹងអំពីប្រធានបទដែលយើងត្រូវយល់ដឹង ហើយនិងអ្នកដែលយើងត្រូវប្រឆាំង ដូច

ជាពួកចក្រពត្តិអាមេរិក ពួកវៀតណាម និងពួកក្បត់នានា។ ហើយវិធានការអនុវត្តនៅក្នុងប្រភេទទី៣ គឺមានដូចតទៅនេះ យើងចាំបាច់ត្រូវតែបោសសម្អាតពួកសភាពមិនល្អ ដើម្បីជាការតស៊ូវណ្ណៈ។ ការបោសសម្អាតត្រូវតែធ្វើឲ្យបានល្អ។ ប្រភេទទី១ ប្រភេទអន្តរាយត្រូវសម្រិតសម្រាំងជាដាច់ខាត។ ប្រភេទទី២ ប្រភេទសេរីធម្មតា ត្រូវអប់រំជាបន្តបន្ទាប់ក្នុងសាលាអប់រំរបស់យើង។ ទី៣ ប្រភេទពួកទើបតែខ្លាំងញុះញង់ ទើបតែគេជឿគេញុះញង់ ជាជំហានដំបូង ត្រូវអប់រំកសាងគេ កុំឲ្យជឿខ្មាំងទៀត"។ សូមបញ្ចប់ការដកស្រង់។

[១៤:០៧:៣០]

លោក លោកស្រីចៅក្រម នៅមានរបាយការណ៍ជាច្រើនទៀត ដែលលើកឡើងដោយលេខាភូមិភាគទាក់ទងទៅនឹងគោលនយោបាយខ្មាំង។ ខ្ញុំនឹងពិភាក្សាទៅលើរបាយការណ៍មួយដែលសំខាន់ផងដែរ គឺឯកសារ E3/1164 -- E3/1164 គឺជារបាយការណ៍ពីកងពល៨០១ គឺលេខាឈ្មោះ វឿន កងពល ៨០១ ដែលផ្ញើជូនបង សុន សេន (៨៩) ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ៧៦។ ហើយនៅក្នុងផ្នែកទី២នៃរបាយការណ៍របស់លេខាកងពលហ្នឹង គឺបាននិយាយអំពីសកម្មភាពខ្មាំងនៅក្នុងកងពលរបស់គាត់ គឺកងពល៨០១។ គឺការរាយការណ៍អំពីសកម្មភាពរបស់ខ្មាំងនៅក្នុងកថាខណ្ឌ៣(ក)។ ខ្ញុំសូមដកស្រង់៖ "វាអូសទាញកម្មាភិបាល និងយុទ្ធជន កុំឲ្យជឿបដិវត្តន៍យើង។ គឺវាលើកអំពីរបបស៊ីចុកមិនគ្រប់គ្រាន់។ កថាខណ្ឌ៣(ឃ) វាបំផុសឲ្យសេរីក្នុងការដើរហើរ និងនិយាយស្តី។ ឲ្យលើកពីបញ្ហាសិទ្ធិសេរីភាពនៅវៀតណាមនិងឡាវ"។ ហើយចំពោះវិធានការដើម្បីដោះស្រាយនៅក្នុងផ្នែកទី៤ នៃរបាយការណ៍នេះ គឺបានលើកតទៅនេះ -- លេខ៦បានលើកឡើងថា "ត្រូវសហការជាមួយមូលដ្ឋានដើម្បីបោសសម្អាតខ្មាំងនៅក្នុងអង្គភាព ហើយនិងស្វែងរកបណ្តាញខ្មាំងស្រាវជ្រាវខ្សែនៅក្នុងអង្គភាពឲ្យអស់"។

[១៤:០៩:៤២]

ឯកសារ E3/1060 គឺជារបាយការណ៍របស់លេខាកងពល៨០១ ផ្ញើជូនបង៨៩ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ៧៧។ ហើយនៅក្នុងឯកសារនេះ លេខាកងពលបានរាយការណ៍អំពីស្ថានភាពខ្មាំងនៅមូលដ្ឋាននៅភូមិភាគពាយ័ព្យ។ ជាឧទាហរណ៍នៅក្នុងផ្នែកចុងក្រោយដែលមានចំណងជើងថា "ផ្សេងៗ"។ កថាខណ្ឌទី៣បានរាយការណ៍អំពីភូមិភាគ១០១ នៅខាងពាយ័ព្យដែលបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់ "នៅខាង១០១ កន្លងមកប្រយុទ្ធនឹងខ្មាំងជាបន្តបន្ទាប់ តែឃើញចំណុចមួយចាប់ខ្មាំងបាន ឬកងទ័ពប្រគល់ខ្មាំងឲ្យច្រើនតែឆាប់កម្ទេច មិនបានសួរបញ្ជាក់រាយរកខ្សែខ្មាំងឲ្យបានហ្មត់ចត់ នាំឲ្យបាត់

ដានខ្មាំង។ ឧទាហរណ៍ដូចជាយួន៧នាក់ ឬក៏ក្រុមចោរព្រៃ១២នាក់ជាដើម។ ប៉ុន្តែរឿងនេះខាងខ្ញុំបានទៅជួបជាមួយសមមិត្ត ធិន ហើយ ដែលធិន ហ្នឹងគឺជាលេខាតំបន់១០១។

កថាខណ្ឌ៥នៃផ្នែកចុងក្រោយនេះ គឺនិយាយអំពីសកម្មភាពអង្គការ។ ខ្ញុំដកស្រង់ "យើងកំពុងតែតាមដានសមាសភាពដែលអន្តរាយដល់បដិវត្តន៍ទាំងថ្មី ទាំងចាស់ គឺអ្នកទំនាស់នឹងមាគ៌ា និងពួកខ្មាំងឆ្លើយដាក់ទាំងចាស់ទាំងថ្មី។" សូមបញ្ចប់ការដកស្រង់។

[១៤:១១:៤១]

ឯកសារE3/1877 គឺជាសារទូរលេខចុះថ្ងៃ២០ ខែឧសភា ឆ្នាំ៧៧ មកពី ឡេង លេខាតំបន់១០៥ ដែលមានឈ្មោះហៅថា ចាន់ ផ្ញើទៅមន្ទីរ៨៧០។ ឯកសារនេះបន្ថែមពីលើឯកសារដែលលើកឡើងពីមុនគឺរបស់កងពល៨០១នោះ គឺឯកសារមួយនេះបង្ហាញយ៉ាងច្បាស់ថា តើកងពលមជ្ឈិម និងកងពលតំបន់ឯករាជ្យធ្វើយ៉ាងណាទាក់ទងទៅនឹងគោលនយោបាយរបស់បក្សចំពោះខ្មាំង។

កថាខណ្ឌទី៣ នៃទូរលេខរបស់លេខាតំបន់១០៥ បាននិយាយអំពីការវាយប្រហារនៅក្នុងតំបន់។ ហើយគឺបានរាយការណ៍ដូចតទៅនេះ៖ "តាមការវាយតម្លៃរបស់យើង គឺថាមិនមែនជាខ្មាំងមកពីខាងក្រៅទេ។ យើងសង្ស័យថាជាដៃជើងរបស់ អាសោម, អាឈិន ដែលគេនិយាយយោងទៅដល់លេខា និងអនុលេខារបស់តំបន់។ បញ្ហានេះបានរាយការណ៍ខាងសមមិត្ត សាន ហើយ។ គឺជាលេខាថ្មីរបស់កង៩២០។ ទោះបីជាយើងមានការចាប់ខ្លួនរបស់ពួកកង៩២០ ក៏នៅមានសកម្មភាពជាបន្តទៀត តែយើងចាប់បន្តបន្ទាប់ដែរ"។ សារទូរលេខនេះក៏រាយការណ៍អំពីខ្មាំងយួនផងដែរ។ ដោយនៅចុងក្រោយបាននិយាយថា "ចែមអំពីបញ្ហាយួននេះបានសម្រេចហើយ។" សូមបញ្ចប់ការដកស្រង់។

[១៤:១៣:៤៨]

ឯកសារបន្តគឺ E3/970 គឺជាលិខិតរបស់លេខាកងពល៥០២ គឺរបស់ ស៊ូ ម៉េត ផ្ញើជូនបងឌុច ចុះថ្ងៃ២៤ ខែ៥ ឆ្នាំ៧៧។ ស៊ូ ម៉េត បាននិយាយថាបានបញ្ជូននូវពួកក្បត់២៧នាក់មកពីខ្សែពួកអាក្បត់នៅកងពល៣១០ និង៤៥០។ ហើយនៅក្នុងកថាខណ្ឌទី៣ គាត់បានបញ្ជាក់ដូចតទៅនេះ "ម៉ោង១០ ឬ ១១យប់នេះ សូមបញ្ជូនចំនួន៧នាក់ទៀតជាខ្សែពួក អាម៉ៅ"។ ហើយនៅក្នុងកថាខណ្ឌទី៤ ស៊ូ ម៉េត បានសរសេរដូចតទៅនេះ "ពីថ្ងៃមុន បងថាឲ្យចម្លើយរបស់ឈ្មោះម៉ៅ មកខ្ញុំ។ បើអង្គការមិនជំទាស់ទេ ខ្ញុំសុំឯកសារនេះដើម្បីស្រាវជ្រាវរកខ្មាំងបន្តទៀត។" សូមបញ្ចប់ការដកស្រង់។

ឯកសារមួយទៀតដែលពាក់ព័ន្ធផងដែរ គឺឯកសារ E3/3655 -- E3/3655 ដែលជាចម្លើយ

សារភាពរបស់ស-២១ ជាសារភាពរបស់ឈ្មោះ ស ធឿន ដែលជាកងពល៥០២ ដូចដែល ស៊ូ ម៉េត បានបញ្ជាក់នៅមុននេះ។ នៅលើទំព័រដើមនៃចម្លើយសារភាពរបស់ ម៉ៅ ដែលលោកឃើញថា នៅភាសាខ្មែរមានលេខ 00173999, ភាសាអង់គ្លេសមានលេខ 00224628 និងភាសាបារាំងមានលេខ 0027 1447។ គឺមានកំណត់ត្រាសរសេរដោយផ្ទាល់ដៃរបស់ សុន សេន ដែលមានឈ្មោះហៅក្រៅថា ខៀវ ផ្ញើជូនលេខា៨០១ គឺ សារឿន ចុះនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ៧៥ ដែលបានបញ្ជាក់ដូចតទៅនេះ "ជូនសមមិត្ត រឿន សូមសមមិត្តអានឯកសារ អាម៉ៅ ហើយស្រង់ឈ្មោះដែលទាក់ទងនឹងកង៨០១។ ទី២ ស្អែកខ្ញុំជួបដោយសារតែល្ងាចនេះខ្ញុំជាប់រវល់"។

[១៤:១៦:២៥]

លោក លោកស្រីចៅក្រម ឯកសារទាំងពីរនេះគឺឯកសារចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ៧៧ និងឯកសារមួយទៀតគឺថ្ងៃទី០២ ខែមិថុនា ដែលជាកំណត់ត្រាទៅលើចម្លើយសារភាពរបស់ឈ្មោះ ម៉ៅ គឺជាភស្តុតាងដែលបង្ហាញថាតើស-២១ -- តើចម្លើយសារភាពនៅស-២១ ធ្វើការរាយការណ៍យ៉ាងដូចម្តេចទៅដល់កម្មាភិបាលរបស់កងពល ឬក៏តំបន់ដែលត្រូវបានគេចោទប្រកាន់។

ឯកសារយោធាចុងក្រោយដែលខ្ញុំធ្វើការបង្ហាញ គឺពាក់ព័ន្ធទៅនឹងគោលនយោបាយប្រឆាំងនឹងវៀតណាម។ ឯកសារ E3/915 គឺជាទូរលេខរបស់លេខាកងពល១៦៤ ឈ្មោះ មាស មុត គឺចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ៧៧ ដែលជាសារទូរលេខផ្ញើជូនគណៈកម្មការ៨៧០ ផ្ញើជូនអ៊ំ, អ៊ំនួន, បងវ៉ាន់, បងវន, បងខៀវ, មន្ទីរ និងឯកសារ។ ហើយក្នុងសារទូរលេខនេះ គឺថាប្រធានកងពល មាស មុត បានសរសេរដូចតទៅនេះ ខ្ញុំសូមធ្វើការដកស្រង់ "យើងខ្ញុំបានទទួលមតិណែនាំ និងសេចក្តីថ្លែងការណ៍របស់បក្ស ស្តីពីការឈ្លានពានរបស់យួនមកលេបទឹកដីមាតុភូមិកម្ពុជារបស់យើង។ យើងខ្ញុំដែលមានភារកិច្ចការពារមុខសញ្ញាសមុទ្រ សូម: ទី១ ឯកភាពទាំងស្រុងជាមួយបក្ស, ទី២ ប្តេជ្ញាកសាងកម្លាំងជាឧបករណ៍ការពារបក្ស ការពាររដ្ឋអំណាច កម្មករ កសិករ សមូហភាព និងការពារមាតុភូមិកម្ពុជាសង្គមនិយមដាច់ខាតដោយបោសសម្អាតគ្មានស្ទាក់ស្ទើរសមាសភាពបង្កប់ជាមួយយួន និងខ្មាំងដទៃទៀត។

[១៤:១៨:៣៣]

ឯកសារមួយទៀតគឺ E3/928 គឺជាឯកសារដែលជាការកត់ត្រាទូរស័ព្ទពីលេខា មុត កងពល ១៦៤ គឺប្រហែលគឺនៅថ្ងៃទី០១ ខែមេសា ឆ្នាំ៧៨។ ឯកសារនេះគឺផ្ញើជូន អ៊ំ, អ៊ំនួន, បងវ៉ាន់។ ហើយនៅក្នុងផ្នែកទី១នៃឯកសារហ្នឹងគឺ មាស មុត បានរាយការណ៍ដូចតទៅនេះ "ដែលថាសរុបយួន១២០ក្បាល

ត្រូវបានសម្លាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៨ ខែមីនា ឆ្នាំ៧៨"។

ក្រោយមកនៅខែដដែលនេះ គឺនៅក្នុងសុន្ទរកថារបស់ ប៉ុល ពត ដែលមានផ្សាយនៅទស្សនាវដ្ដីទង់បដិវត្ត ខែមេសា ឆ្នាំ៧៨ ឯកសារដែលមានលេខ D243/2.1.16 -- គឺឯកសារដែលមានលេខ D243/2.1.16។ គឺខ្មែរមានលេខ 00064717, ភាសាអង់គ្លេសមានលេខ 00519836 និងភាសាបារាំងមានលេខ 00520348។ ប៉ុល ពត បានថ្លែងដូចតទៅនេះ៖ "រហូតដល់ឥឡូវយួនយ៉ាងម៉េច? យួនអត់នៅក្នុងទឹកដីកម្ពុជា។ ពីដើមជិត១លាននាក់ ឥឡូវតែមួយគ្រាប់គ្មានទេ"។

[១៤:២០:៤៥]

ពាក់ព័ន្ធទៅនឹងវៀតណាមជាង១៥លាននាក់ដែលរស់នៅក្នុងប្រទេសវៀតណាម ប៉ុល ពត បានបង្គាប់បញ្ជាបានណែនាំដូចតទៅនេះគឺឯកសារខ្មែរ មានលេខ 00064712 ដល់ 14, អង់គ្លេសមានលេខ 00519833 ដល់ 34 និងភាសាបារាំងមានលេខ 00520343 ដល់ 45។ នៅត្រង់លេខERN ទាំងនេះ ប៉ុល ពត បានថ្លែងដូចតទៅនេះ ខ្ញុំសូមធ្វើការដកស្រង់ "យួនមានប្រជាជន ១៥លាននាក់។ ហើយកម្ពុជាមានប្រជាជនតែ៨លាននាក់ទេ។ ដូច្នេះតើយើងឈ្នះដោយរបៀបណា? វាជាការលំបាកដោយសារតែពួកយួនវាមានទាហានជាង១លាននាក់។ ខ្ញុំចង់ប្រាប់លោកអំពីទាហានរបស់យើង។ គឺកងកម្លាំងទូទៅរបស់យើងមានតិចជាង១០០.០០០នាក់ទេជាកម្លាំង។ ដូច្នេះតើធ្វើយ៉ាងណាដើម្បីឲ្យ៨លាន វ៉ៃ៥០លានបាននោះ។ កងទ័ពយើងមានមិនដល់១០០.០០០នោះទេ ប៉ុន្តែយើងទៅវ៉ៃជិតមួយលានយ៉ាងម៉េច?" ឥឡូវនេះខ្ញុំសូមដកស្រង់នៅខាងក្រោមបន្តិច "ប្រសិនបើយើងមើលតែតួលេខ គឺថាយើងម្នាក់ត្រូវតែវ៉ៃយួន៥០នាក់។ ប្រសិនបើយើងសម្រេចបានជោគជ័យ ទាំងអស់នេះគឺយើងឈ្នះ។ ទោះបីថាយួនមានច្រើនប៉ុនណាក៏ដោយ យើងនៅតែអាចវាយពួកវាបាន ហើយជោគជ័យទៀត"។

[១៤:២២:៣៤]

ហើយខ្ញុំសូមអានបន្តនៅក្នុងកថាខ័ណ្ឌដដែល "ប៉ុល ពត បានបញ្ជាក់ច្បាស់ថា គាត់និយាយអំពីប្រជាជនវៀតណាមទាំងមូលតែម្ដង។ ដូច្នេះ នៅពេលដែលយើងមាន២លាន យើង គឺថាប្រជាជនយើងលើសពួកវាទៅទៀតព្រោះវាមានត្រឹមតែ៥០លានទេ។ យើងមិនចាំបាច់ត្រូវការប្រើ៨លាននោះទេ។ យើងប្រើកម្លាំងតែ២លានវាយកម្ទេចពួកយួន ហើយយើងនៅសល់៦លាននាក់ទៀត។ គឺប្រជាជនខ្មែរនៅសល់៦លាននាក់ទៀត។ ហើយបន្តទៅក្រោមខ្ញុំសូមធ្វើការដកស្រង់៖

"នេះគឺជាមាគ៌ាវាយប្រឆាំងគ្នាដែលត្រូវអនុវត្តនៅសមរភូមិ។ បើសិនជាយើងមិនអាចសម្រេច

បានគោលដៅនេះទេ យើងមិនអាចទទួលបានជោគជ័យនោះទេ។ បញ្ហានេះមិនមែនប្រើតែចំពោះយោធានោះទេ។ គឺថាទាំងបក្សទាំងគោលនយោបាយ ទាំងប្រជាជនទាំងអស់ត្រូវគោរពទៅតាមមាគ៌ាទាំងអស់នេះ”។ សូមបញ្ចប់ការដកស្រង់។

[១៤:២៣:៥៣]

ផ្នែកចុងក្រោយដែលខ្ញុំចង់ធ្វើការបង្ហាញ គឺឯកសារពាក់ព័ន្ធទៅនឹងគោលនយោបាយទូទៅនៅរបស់ភូមិភាគនិងតំបន់ស្វ័យតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងអស់នេះយើងនឹងមើលឃើញថា នៅតាមភូមិភាគ ឬក៏តំបន់ស្វ័តនីមួយៗនោះ គឺឯកភាពគ្នាជាមួយនឹងគោលនយោបាយទាក់ទងទៅនឹងខ្មាំង។ ឯកសារ E3/871 -- E3/871 គឺជាសារទូរលេខចុះថ្ងៃទី២១ មីនា ឆ្នាំ៧៦ របស់ខាងភូមិភាគខាងបូព៌ា ផ្ញើជូន ប៉ុល ពត, នួន ជា និង អៀង សារី។ កថាខណ្ឌដំបូងនៃរបាយការណ៍នេះបានរៀបរាប់អំពីការចាប់ប្រជាជនវៀតណាម៥នាក់ ដែលបានលាក់ខ្លួនហើយត្រូវបានសម្លាប់ហើយ ៣នាក់ទៀតត្រូវបានគេចាប់ឃុំខ្លួននៅមន្ទីរសន្តិសុខ។ កថាខណ្ឌទី២នៃរបាយការណ៍បានរៀបរាប់អំពីការចាប់ និងការសួរបុគ្គលដែលបានបោកគ្រាប់បែក ហើយមានការរាយការណ៍ដូចតទៅនេះ៖ “យើងវាយពួកវានៅពេលស៊ើបសួរ ហើយបន្ថែមទៀត គឺថាយើងសួររកខ្សែចាត់តាំងរបស់វាបានចំនួន២០ប្លាយនាក់ទៀត នៅតាមមូលដ្ឋានក្នុងស្រុកព្រះស្តេច។ ពួកអានេះខ្សែចាត់តាំងមកពីវៀតណាមខាងត្បូង”។ សូមបញ្ចប់ការដកស្រង់។

[១៤:២៥:៣៨]

ចំពោះខាងពាយ័ព្យវិញ គឺមានឯកសារមួយចំនួនដែលខ្ញុំចង់លើកយកមកបង្ហាញដែរ គឺឯកសារ E3/178 -- E3/178 គឺជារបាយការណ៍ប្រចាំសប្តាហ៍របស់គណៈកម្មការភូមិភាគ៥ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ៧៧។ ផ្នែកដំបូងនៃរបាយការណ៍នេះ គឺនិយាយអំពីសភាពការណ៍ការពារប្រទេស។ ខ្ញុំសូមធ្វើការដកស្រង់៖ “ក្រោយពីបានផ្សព្វផ្សាយនូវសភាពការណ៍ការពារប្រទេសតាមខ្លឹមសារនៃបទឧទ្ទេស-នាមរបស់បក្សក្នុងឱកាសសន្និបាតភូមិភាគ និងតាមខ្លឹមសារនៃសេចក្តីសម្រេចចិត្តរបស់អង្គសន្និបាតមកពិនិត្យឃើញថា ចលនាវាយសម្រុកការពារប្រទេសដោយវាយកម្ទេចគ្រប់របាយកលរបស់ខ្មាំងទាំងមកពីខាងក្រៅ ទាំងខាងក្នុងមានសន្ទុះនិងល្បឿនលោតផ្លោះជាងមុន។ ដោយបានបន្តយ៉ាងសកម្មប្រយុទ្ធវាវរកពួកក្បត់ និងបន្តបោសសម្អាតពួកក្បត់ដែលបានទទួលលទ្ធផលដូចតទៅនេះ...”។

[១៤:២៦:៥២]

ខ្មែរមានលេខ 00275587, ភាសាអង់គ្លេសមានលេខ 00342709 និងភាសាបារាំងមានលេខ 00623305។ របាយការណ៍នេះ គឺបន្ទាប់មកទៀតបានរៀបរាប់អំពីការសម្រេចនានារបស់ខាងតំបន់ទាក់ទងទៅនឹងខ្មាំង។ ខ្ញុំសូមធ្វើការដកស្រង់៖ "...រកឃើញពួកក្បត់ គឺសមាសភាព ១៧មេសា ដែលមកពីភ្នំពេញ ដែលមានចេតនាបំផ្លាញអាងស្តុកទុករបស់យើង ហើយយើងរកឃើញពួកខ្មាំងដែលជាសមាសភាព ១៧ មេសា មកពីភ្នំពេញ ដែលផ្អែកទៅតាមចម្លើយសារភាពរបស់ខ្សែពួកវា ហើយនិងផ្អែកទៅតាមរូបថតដែលអង្គការបានស្នើឱ្យសួរ។ យើងធ្វើការបោសសម្អាតពួកអ្នកដែលក្បត់ ដែលខុសសីលធម៌ ដែលធ្វើការលួច និងការ -- ហើយពួកបុគ្គលទាំងអស់នេះ គឺជាសមាសភាព ១៧មេសា មកពីភ្នំពេញ និងពួកមូលដ្ឋានផងដែរ"។

នៅក្នុងផ្នែកដដែលពីរបីកថាខណ្ឌខាងក្រោម គឺឯកសារបានរាយការណ៍ដូចតទៅនេះ -- ឯកសារបានរាយការណ៍ដូចតទៅ គឺនិយាយពាក់ព័ន្ធទៅនឹងពួកចាមនៅក្នុងតំបន់។ "សមាសភាព ១៧ មេសា មកពីភ្នំពេញដែលជាជនជាតិចាម បានធ្វើការតវ៉ានៅក្នុងរោងបាយរួម ដោយតវ៉ាអំពីជំនឿ និងការហូបចុករបស់ពួកគេតាមសាសនា។ ដោយយោងទៅតាមមាត្រា៥ -- មាត្រា១០ នៃរដ្ឋធម្មនុញ្ញ--" ខ្ញុំគិតថាក្នុងនេះប្រហែលជាគេចង់និយាយអំពីមាត្រា២០ នៃរដ្ឋធម្មនុញ្ញទេមើលទៅ។ ខ្ញុំសូមបន្តទៅទៀត "--ចំពោះសភាពការណ៍នេះ គឺយើងបានចាត់វិធានការពិសេស ដើម្បីរកអំពីកម្លាំង ដើម្បីរកមេចលនា ដើម្បីបោសសម្អាតពួកទាំងអស់នេះ"។ សូមបញ្ចប់ការដកស្រង់។

ហើយនៅក្នុងផ្នែកនេះ គឺបានសន្និដ្ឋានដោយធ្វើការកត់សម្គាល់ដូចតទៅនេះ៖ ផ្អែកទៅតាមការណែនាំជាបន្តបន្ទាប់របស់បក្ស ផ្អែកទៅតាមសេចក្តីសម្រេចរបស់ភូមិភាគ ផ្អែកទៅតាមការជាក់ស្តែងយើងបានបន្តការវាយប្រយុទ្ធយ៉ាងខ្លាំងដោយបន្តឃោសនាអប់រំ និងជំរុញ ដល់កម្មាភិបាលបក្ស សមាជិកបក្ស ដោយប្រឹងប្រែងទាំងខាងឆ្វេង ទាំងខាងស្តាំ ដើម្បីបន្តបោសសម្អាត ដើម្បីជំរុញ ក៏ដូចជាលើកកម្ពស់ការសហការ និងដើម្បីបន្តបោសសម្អាតទៅដល់ពួកក្បត់ដែលបានបង្កប់ស៊ីរូងផ្ទៃក្នុង ដូចជាពួកសេ.អ៊ី.អា, កា.ហ្សេ.បេ ឬក៏វៀតណាម។

[១៤:៣០:១៨]

ឯកសារបន្តទៀតគឺ E3/1120 គឺជាសារទូរលេខដែលរាយការណ៍អំពីស្ថានភាពខ្មាំងផ្ញើជូនពីភូមិភាគពាយ័ព្យដែលគេហៅថា ម-៥៦០ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ៧៧ ដោយចម្លងជូនអ៊ំ អ៊ំនួន,

បងវ៉ាន់, បង វ៉ន, បងខៀវ។ បន្ទាប់ពីបានរាយការណ៍អំពីបញ្ហាខ្មាំងមួយចំនួននៅតំបន់៣ និងតំបន់៥នៃភូមិភាគពាយ័ព្យ របាយការណ៍បានបញ្ជាក់ដូចតទៅនេះ ខ្ញុំសូមធ្វើការដកស្រង់៖ "តំបន់បានដោះស្រាយទៅលើបញ្ហាទាំងអស់នេះ នៅក្នុងនោះរួមមាន ខិតខំរកក្បាលម៉ាស៊ីនខ្មាំងតទៅទៀត។ ទី២ ខិតខំឃោសនាអប់រំប្រជាជនឲ្យគេយល់ពីបដិវត្តន៍សង្គមនិយមឲ្យច្បាស់។ ទី៣ មូលដ្ឋាន និងយោធាត្រូវសហការគ្នាឲ្យជិតស្និទ្ធដើម្បីកម្ទេចខ្មាំងគ្រប់បែបយ៉ាង"។ សូមបញ្ចប់ការដកស្រង់។

[១៤:៣១:៣០]

ឯកសារមួយទៀតពីខាងពាយ័ព្យពី E3/950 គឺជារបាយការណ៍របស់លេខាឈ្មោះ ញឹម ភូមិភាគពាយ័ព្យផ្ញើជូនអង្គការ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ៧៨។ នៅក្នុងកថាខណ្ឌដំបូងនៃឯកសារនេះ ញឹមបានរាយការណ៍ដូចតទៅ៖ បន្ទាប់ពីមានការប្រជុំជាមួយអង្គការដែលគាត់បានទទួលការផ្ដល់អនុសាសន៍ពីមន្ទីរ៨៧០ បន្ទាប់មកគាត់បានជម្រាបទៅដល់គណៈកម្មាធិការរបស់ខាងភូមិភាគ។ របាយការណ៍ទាំងនេះគឺថារបាយការណ៍ដែលនិយាយអំពីភូមិភាគពាយ័ព្យ គឺជារបាយការណ៍និយាយអំពីសកម្មភាពខ្មាំងខាងក្នុង និងខាងក្រៅ"។ ហើយរបាយការណ៍នេះបានបញ្ចប់ដោយរាបរាប់ពីវិធានការដូចតទៅនេះ៖ "ត្រូវមានស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់។ វាយកម្ទេចខ្មាំងឈ្លានពាន បោសសម្អាតពួកសមាសភាពអន្តរាយជាបន្តទៅទៀត។ ទប់ទល់ការរត់លួន បូកលួចនេះ លួចនោះឲ្យអស់"។

ហើយឯកសារចុងក្រោយពីខាងភូមិភាគពាយ័ព្យ គឺឯកសារ E3/863 គឺជារបាយការណ៍របស់លេខាភូមិភាគពាយ័ព្យផ្ញើជូនអង្គការចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ៧៨។ នៅក្នុងកថាខណ្ឌ៥ នៃរបាយ-ការណ៍នេះ លេខាភូមិភាគស្នើសុំឲ្យមានការផ្ដល់មតិយោបល់ពីអង្គការទៅលើបញ្ហាដូចតទៅនេះ៖ "អង្គប្រជុំបានលើកឡើងអំពីការដោះស្រាយជាមួយទាហានមកពីតំបន់ ក៏ដូចជាពួកយួនដែលមានប្រពន្ធប្ដីជាខ្មែរ ហើយនិងពួកកាត់យួន។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ កិច្ចប្រជុំចង់ស្នើសុំដល់អង្គការ៨៧០ តើត្រូវធ្វើយ៉ាងដូចម្ដេច? តើអង្គការសម្រេចយ៉ាងណា? សូមមានមតិណែនាំមកចុះ។ និយាយជារួមពួកនេះកំពុងខ្លាចព្រួយ។ តែសកម្មភាពប្រឆាំងពុំទាន់មាននោះទេ។ បើអ្នកណាមានសកម្មភាពឲ្យសម្រេចចោលដែរ"។

[១៤:៣៤:០១]

ទាក់ទងទៅនឹងភូមិភាគនិរតីវិញម្ដង ឯកសារ E3/798 គឺជាកំណត់ហេតុចុះថ្ងៃទី៣០ សីហា ១៩៧៦ នៃកិច្ចប្រជុំរបស់លេខា និងអនុលេខាកងពល និងពួកកងវរៈឯករាជ្យ ដែលរាយការណ៍អំពីស្ថានភាពខ្មាំងនៅមូលដ្ឋាន។ នៅក្នុងផ្នែកនេះ សុន សេន បានរាយការណ៍អំពីការចាប់ខ្លួនមនុស្ស៦០នាក់នៅ

តំបន់២៥នៃភូមិភាគនិរតី។ ហើយអំពើដែលពាក់ព័ន្ធទៅនឹងអ្នកចាប់ខ្លួនទាំង៦០នេះ គឺពាក់ព័ន្ធមានដូចតទៅ៖ "ពួកគេបានលើកទង់សមានពាក្យស្លោកថា ជយោ! ព្រះពុទ្ធសាសនា, ជយោ! រណសិរ្សខ្មែរសរំដោះអង្គរកំប៉ុង។ វាបម្រុងបះបោលធំនៅថ្ងៃទី២០ ខែសីហា ប៉ុន្តែវាមិនអាចធ្វើបាន ហើយពន្យារពេលធ្វើទៀត"។ ហើយពីភូមិភាគនិរតីនេះផងដែរ មានឯកសារដែលនៅសល់ពីសម័យនោះ ដែលនៅសល់ពីស្រុកត្រាំកក់ ដែលបង្ហាញដល់បក្សអំពីគោលនយោបាយចំពោះខ្មាំង។

ឯកសារ E3/2424 បាទ សូមសាឡើងវិញ គឺឯកសារ E3/2424 ពាក់ព័ន្ធទៅនឹងការប្រមូលរបាយការណ៍ទាំងអស់ពីស្រុកត្រាំកក់ ដែលខ្ញុំសូមបង្ហាញតែរបាយការណ៍ពីរទេ របាយការណ៍ទី១ ERN ជាភាសាខ្មែរ 00027077, អង់គ្លេស 00322218, បារាំង 00612216។ នេះគឺជារបាយការណ៍មកពីឃុំមួយចុះថ្ងៃទី១៨ សីហា ១៩៧៨ ដែលរបាយការណ៍នេះបានលើកឡើងដូចតទៅ-- សេចក្តីរាយការណ៍--គឺនិយាយអំពីកសិករជាស្ត្រីម្នាក់ដែលបាននិយាយ។ សូមដកស្រង់៖ "អ្វីដែលយើងធ្វើបដិវត្តន៍អត់ --ដែលយើងធ្វើណាស់បដិវត្តន៍អត់ណាស់ គោរពណាស់ ខុសណាស់។ និយាយនេះកាលពីថ្ងៃទី១៣ គឺការនិយាយនេះគឺនិយាយនៅថ្ងៃទី១៣ មិថុនា ៧៨។ កាលពីឆ្នាំ៧៧ នារីនេះបានលួចស្រូវមួយផ្តិល បន្ទាប់មកនារីនេះបាននិយាយថា បដិវត្តន៍របបស៊ីសុទ្ធតែកំណត់ គឺឱ្យស៊ីប៉ុន្មានបានស៊ីប៉ុណ្ណឹង។ ប្តីនារីនេះឈ្មោះ បេ សត្យា ឫសគល់ជាតិអារ៉ាប់ ចៅកែហាងសាំង ដែលចេញពីភ្នំពេញបែកគ្នាពាក់កណ្តាលផ្លូវសកម្មភាពការងារមធ្យម ច្រើន -- ធឿន គឺថាបានគេសួរចម្លើយជាច្រើន ពីព្រោះអង្គការបានសម្រេចហើយថាត្រូវតែសម្រេចយកគេចេញទៅ"។ របាយការណ៍ទី២ ដែលមាននៅក្នុងឯកសារ E3/2424 នេះដែលខ្ញុំចង់បង្ហាញផងដែរ ខ្មែរ ERN គឺ 00270755 ដល់ 56, អង់គ្លេស 00322220, និងបារាំង 00612219។ នេះគឺជារបាយការណ៍មកពីឃុំអង្គតាសោម ផ្ញើជូនសមមិត្តបង ស្រុកមួយរយ -- លេខា ១០៥ ចុះថ្ងៃទី១៨ សីហា ១៩៧៨ ដែលរាយការណ៍អំពីមនុស្សបីនាក់ពីក្នុងឃុំនុំងដែលត្រូវសម្រេចថា គឺជាខ្មាំង។

[១៤:៣៨:០៤]

ពីរកថាខណ្ឌចុងក្រោយនៃរបាយការណ៍នេះគឺបានសរសេរដូចតទៅ សូមដកស្រង់៖ "វៀតណាម អែម សម្បត្តិ ជាកូនរបស់អា គីម ឡុង សកម្មភាពរបស់វាគឺវាបានបំបាក់ផាលនង្គ័ល វាមិនឱ្យគោស៊ីស្មៅ វាដើរលួចអ្នកថ្មីៗនេះ វាបោះនង្គ័លទម្លាក់ចោលក្នុង -- ទម្លាក់ស្ពានបណ្តាលឱ្យគោបាក់ជើង។ ហេតុដូច្នេះស្នើបញ្ជូនខ្មាំងបីរូបនេះជាមួយនឹងរបាយការណ៍ភ្ជាប់ជាមួយ ដើម្បីឱ្យសួរចម្លើយ និងចាត់

វិធានការបន្ថែមទៀតដើម្បីស្រាវជ្រាវរកខ្សែបង្កប់របស់វា និងចាត់វិធានការតទៅទៀត ដើម្បីសម្រេចបានតាមទិសរបស់បក្ស។ ចុះថ្ងៃទី១៨ សីហា ៧៨ ឃុំអង្គតាសោម"។

លោកប្រធាន ខ្ញុំត្រូវចូលទៅបង្ហាញឯកសារមួយប្រភេទទៀត ថាតើគួរឈប់សម្រាកសិន ឬក៏យ៉ាងណា? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាមានឱកាសបន្តការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ មុនពេលដែលខ្ញុំចាប់ផ្តើមការបង្ហាញ ខ្ញុំសូមជម្រាបបន្ថែមបន្តិចទាក់ទងទៅនឹងការវិវត្តន៍របស់យើងទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម ហើយនិងការពិភាក្សារបស់យើងដែលបានធ្វើជាមួយដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងផែនការនៅថ្ងៃស្អែកនេះ។

គឺថាពីដើមមកយើងបានបញ្ជាក់ថាយើងស្នើសុំ២ថ្ងៃសម្រាប់ទៅលើគោលនយោបាយសហឧក្រិដ្ឋកម្មរួម និង១ថ្ងៃទៀត សម្រាប់តួនាទីរបស់ជនជាប់ចោទ នួន ជា, ខៀវ សំផន ប៉ុន្តែខ្ញុំគិតថា ខ្ញុំប្រហែលជាអាចស្នើសុំដល់ថ្ងៃស្អែកព្រឹកត្រឹមមួយពេលមុនសម្រាក។ ដូច្នេះ គឺខ្ញុំស្នើសុំអនុញ្ញាតប្រើប្រាស់តែបីភាគបួននៃថ្ងៃសម្រាប់តួនាទីជនជាប់ចោទ នួន ជា និង ខៀវ សំផន។ ដូច្នេះនៅថ្ងៃស្អែកព្រឹក ត្រឹមមួយពេលមុនសម្រាកគឺខ្ញុំអាចបញ្ចប់ការបង្ហាញរបស់ខ្ញុំ ហើយបន្ទាប់មកទៀត សហការីរបស់ខ្ញុំជាសហព្រះរាជអាជ្ញាជាតិគាត់នឹងចំណាយពេលប្រហែលជា១ម៉ោង ឬក៏កន្លះម៉ោងទាក់ទងទៅនឹងគោលនយោ-

បាយនៃការរៀបការដោយបង្ខំ។

ខ្ញុំបានពិភាក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណី ហើយពួកគាត់បានបញ្ជាក់ថាគាត់យល់ស្រប។ យ៉ាងណាក៏ដោយអាស្រ័យទៅលើការសម្រេចរបស់តុលាការ។ ហើយចំពោះគោលនយោបាយសហឧក្រិដ្ឋកម្មរួម គឺយើងអាចនឹងមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ហើយខ្ញុំសង្ឃឹមថា ខាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងជម្រាបជូនតុលាការអំពីការវិវត្តន៍របស់គេ ក៏ដូចជាការបង្ហាញរបស់ពួកគាត់ចំពោះសហឧក្រិដ្ឋកម្មរួម។ ហើយបន្ទាប់មក ថាតើត្រូវឲ្យខាងមេធាវីការពារក្តីគាត់ធ្វើការឆ្លើយតបទៅនឹងបញ្ហាសហឧក្រិដ្ឋកម្មរួម ឬមួយក៏ខ្ញុំនិយាយអំពីតួនាទីរបស់ជនជាប់ចោទ ហើយសឹមខាងមេធាវីការពារក្តីគាត់ធ្វើការឆ្លើយតបទៅនឹងការលើកបង្ហាញរបស់ខាងសហព្រះរាជអាជ្ញាទាំងអស់តែម្តង?

[១៥:០៣:០១]

**ប្រធានអង្គជំនុំ៖**

ទំនងជាអង្គជំនុំជម្រះបានជម្រាបជូនសហព្រះរាជអាជ្ញា ហើយនិងភាគីដទៃទៀតរួចហើយ តាំងពីថ្ងៃដំបូងនៃការចាប់ផ្តើមសវនាការបង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺអង្គជំនុំជម្រះផ្តល់ពេលវេលារួមទៅឲ្យភាគីតំណាងសហព្រះរាជអាជ្ញាធ្វើការបង្ហាញឯកសារទាំងពីរប្រធានបទ។ ទាំងអង្គហេតុសហឧក្រិដ្ឋកម្មរួម បន្ទាប់មកគឺតួនាទីរបស់ជនជាប់ចោទ។ បន្ទាប់មកពេលវេលាបន្ទាប់គឺផ្តល់ឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងដូចគ្នា គឺបង្ហាញនូវប្រធានបទទាំងពីរនេះ និងចំណាយពេលវេលា១ថ្ងៃកន្លះ។ ហើយបន្ទាប់មកទៀត អង្គជំនុំជម្រះនឹងទុកពេលវេលាសមស្របសម្រាប់ឲ្យខាងមេធាវីការពារក្តីមានឱកាសនៅក្នុងការពិភាក្សាជាមួយនឹងកូនក្តីរបស់ខ្លួន ដើម្បីមានលទ្ធភាពក្នុងការឆ្លើយតប ឬក៏ធ្វើការកត់សម្គាល់ អត្ថាធិប្បាយទៅលើបណ្តាឯកសារដែលដាក់បង្ហាញដោយភាគីទាំងពីរនៅសប្តាហ៍ក្រោយ។

ដូច្នេះ អង្គជំនុំជម្រះបានជម្រាបជូនច្បាស់លាស់ហើយ។ ដោយសារមានការបារម្ភអ៊ីចឹងបានអង្គជំនុំជម្រះ គឺរូបយើងជាប្រធានបានរំឭកម្តងទៀត មុននឹងផ្តល់វេទិកាចុងក្រោយជូនទៅតំណាងសហព្រះរាជអាជ្ញា។ ប្រហែលជាមកពីមានការផ្លាស់ប្តូរ ទើបក្តាប់បញ្ហានេះមិនបាន។

[១៥:០៤:៣៦]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំមិនស្នើសុំពេលវេលាម៉ោងបន្ថែមទេ គឺថាខាងព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីគឺថាបំពេញការងារនៅក្នុងពេលវេលាដែលបែងចែករួចមកហើយ។ គ្រាន់តែថា យើងខ្ញុំចង់ជម្រាបអង្គជំនុំជម្រះថា យើងមានចេតនាថាយើងទាំងពីរហ្នឹង ធ្វើការបង្ហាញអំពីសហឧក្រិដ្ឋកម្មរួម គឺថាសហព្រះរាជអាជ្ញានិងខាងដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការបង្ហាញអំពីសហឧក្រិដ្ឋកម្មរួម ហើយបន្ទាប់មកសឹមយើងទាំងពីរនាក់ហ្នឹងគឺយើងធ្វើការបង្ហាញអំពីតួនាទីរបស់ជនជាប់ចោទ។ គឺយើងខ្ញុំមិនបានស្នើសុំពេលវេលាបន្ថែមទៅលើការធ្វើបទបង្ហាញពីអង្គជំនុំជម្រះនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យធ្វើដូច្នេះបាន មិនមានបញ្ហាអីទេ ប្រសិនបើមានបំណងធ្វើដូច្នេះពីព្រោះដូចជាការខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះ។

[១៥:០៥:៣៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានឯកសារមួយចំនួនទៀត ដែលត្រូវលើកឡើងទាក់ទងទៅនឹងគោលនយោបាយខ្មាំង ហើយបន្ទាប់មកទៀតខ្ញុំនឹងលើកឡើងអំពីគោលនយោបាយ ដែលផ្ដោតគោលដៅទៅលើមន្ត្រី និងយោធារបបសាធារណរដ្ឋខ្មែរ។

ឥឡូវនេះខ្ញុំនឹងបន្តអំពីគោលនយោបាយទូទៅទាក់ទងទៅនឹងខ្មាំង ឯកសារដែលមានលេខ E3/156 គឺជាគោលនយោបាយរបស់ខាង -- គឺជាឯកសាររបស់តំបន់១០៥ នៅក្នុងខេត្តមណ្ឌលគិរី នៅខែមេសាឆ្នាំ៧៨ គឺជាសារទូរលេខបញ្ជូនឡើងដោយសាក្សីមួយឈ្មោះ សៅ សារុន។ នៅក្នុងកថាខណ្ឌ៣ នៃរបាយការណ៍នេះគឺផ្ញើជូន បង, អ៊ំ, អ៊ំនួន, អ៊ំវ៉ាន់, វ័ន្ត(*ស៊ុត*) ហើយបានបញ្ជាក់ដូចតទៅនេះ៖ “បញ្ហាសភាពការណ៍ផ្ទៃក្នុងបក្ស គឺមានសមមិត្ត សុត ប្រធានរោងចក្រជួសជុលបានប៉ះពាល់សីលធម៌ជាមួយនារី។ ឥឡូវនេះគឺបានចាប់ហើយ គឺចាប់ទាំងបុរស ចាប់ទាំងនារី។ មិត្តនេះមានជាប់ចម្លើយពួកអាក្បត់អាជួន។ ក្នុងតំបន់ពេលនោះនៅតាមដានសកម្មភាពវាថែមទៀត។ តែឥឡូវវាមានប៉ះពាល់សីលធម៌យ៉ាងនេះបានចាប់ឃុំឃាំងទុកហើយ។ ឯបញ្ហានេះសូមជូនយោបល់ ត្រូវទុកដាក់កម្រិតណា ឬឲ្យជូនទៅណា”។

[១៥:០៧:២១]

ឧទាហរណ៍មួយទៀតពីខាងនិរតី គឺករណីរបស់លេខាតំបន់ ប៊ូ ខាវ គឺថាតាមផ្នែកទៅតាមបញ្ជីរបស់មន្ទីរស-២១ គឺចុះនៅថ្ងៃ០៥ ខែមីនា ឆ្នាំ៧៥។ ហើយឯកសារ E3/1508, E3/1508 គឺជាឯកសារដែលមានឯកសារចំនួនបី។ ឯកសារទី១ គឺជាកំណត់ត្រាជាលាយលក្ខណ៍អក្សរ ជាផ្ទាល់ដៃរបស់ សុន សេន ផ្ញើជូន ឌុច នៅថ្ងៃទី០៧ ខែ០១ ឆ្នាំ៧៧ បន្ទាប់មកពីការចាប់លេខាតំបន់ ប៊ូ ខាវ ហើយជាការផ្ញើជូនទៅ ឌុច។ ហើយខ្ញុំសូមអានដូចតទៅនេះ៖ “អ្នកក្រៅនៅខាងក្រៅយោធា បូកជាមួយនឹងកម្មាភិបាលខាងក្នុងត្រូវបានចាប់ខ្លួន។ ប៊ូ ខាវ ដែលខាងពួកសានបញ្ជូនមកនេះ គឺថាជាអ្នកជំនាន់តស៊ូ។ សមមិត្ត តែន ដែលជាលេខាតំបន់មួយដែរបានចាប់ខ្លួនគាត់ ហើយបញ្ជូនគាត់មកទីនេះ។ សូមសួរចម្លើយឲ្យចាប់ដើម្បីកម្ទេចខ្សែនៅខាងពួកសានឲ្យបានទាន់ពេលវេលា”។ សូមបញ្ចប់ការដកស្រង់។

ហើយនេះគឺជាកំណត់ត្រាផ្ទាល់ដៃដែលផ្ញើជូន ឌុច ហើយចុះនៅថ្ងៃទី០៧ ខែ០១ ឆ្នាំ៧៧ ពីខាងតំបន់ផងដែរ ដែលជាការរៀបរាប់ពីចម្លើយសារភាពរបស់ ប៊ូ ខាវ ដែល ប៊ូ ខាវ បានឆ្លើយថាគាត់បានធ្វើទាក់ទងជាមួយនឹងពួកយួន។

[១៥:០៩:២៩]

ហើយឯកសារពាក់ព័ន្ធមួយទៀត ទាក់ទងទៅនឹង ប៊ូ ខាវ គឺ E3/1061 គឺជារបាយការណ៍ពីលេខាកងពល៨០១ ឈ្មោះ រឿន, ផ្ញើជូន សុន សេន ចុះថ្ងៃទី២៤ ខែ៣ ឆ្នាំ៧៧។ ហើយនៅក្នុងផ្នែកទី២នៃរបាយការណ៍នេះ គឺកង -- គឺរបាយការណ៍រាយការណ៍អំពីស្ថានភាពខ្មាំងនៅក្នុងតំបន់៨០១។ ហើយនិយាយអំពីកងពលដែលត្រូវ -- ពីកម្មាភិបាលដែលត្រូវបានគេចោទថាស្ថិតក្នុងខ្សែរបស់ ប៊ូ ខាវ ហើយបានបញ្ជាក់ថា ប៊ូ ខាវ បានខុសសីលធម៌ជាមួយនឹងស្ត្រីជាច្រើនរួមបញ្ចូលទាំងអនុលេខាកងពល ផងដែរ។ ហើយក៏មានកំណត់ត្រាផ្ទាល់ដៃរបស់ សុន សេន ដែលរាយការណ៍ជូនអង្គការ។

លោក លោកស្រីចៅក្រម! ឯកសារទាំងអស់នេះគឺពាក់ព័ន្ធទៅនឹងលេខាស្រុកនៅក្នុងតំបន់១០១នៃភូមិភាគពួកសាន។ ហើយក៏បញ្ជាក់អំពីការឯកភាពពីខាងភូមិភាគ ខាងមន្ទីរ ក៏ដូចជាខាងតំបន់នានាទាក់ទងទៅនឹងបញ្ហាខ្មាំង។ អង្គជំនុំជម្រះបានឃើញនូវឯកសារជាច្រើនពីខាងភូមិភាគឧត្តរ។ ដូច្នេះ ខ្ញុំសូមនិយាយទៅលើឯកសារចំនួនពីរពីខាងភូមិភាគឧត្តរ។

[១៥:១០:៥៨]

E3/1077 គឺជាសារទូរលេខពីខាងភូមិភាគឧត្តរដែលឈ្មោះ សែ ផ្ញើជូនមន្ទីរ៨៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ៧៨។ ផ្នែកទី១នៃរបាយការណ៍នេះគឺនិយាយអំពី ការចាប់ខ្លួនអតីតលេខាតំបន់ឈ្មោះ ហង់

ហើយនិងដៃជើងរបស់វាដែលត្រូវបានគេចោទថា គាំទ្រដល់ពួកក្រុម អ៊ិន តាំ។ ដូច្នេះ គឺគេនិយាយម្តងទៀតហើយទាក់ទងទៅនឹង អ៊ិន តាំ ដែលជាជនក្បត់ទាំងប្រាំពីរ។ នៅក្នុងផ្នែកទី៣ នៃរបាយការណ៍នេះគឺនិយាយអំពីសភាពខ្មាំងនៅខាងក្នុង។ ហើយខ្ញុំសូមធ្វើការដកស្រង់៖ “ស្ថានភាពគ្មានអ្វីប្រែប្រួលធំដុំនោះទេ។ យើងកំពុងបន្តបោសសម្អាតពួកអានៅសេសសល់ជាបន្តបន្ទាប់ទៀត ដែលវាប្រឆាំងបដិវត្តន៍យើងទាំងចំហក្តី ទាំងដោយសម្ងាត់ក្តី”។

ឯកសារ E3/175 គឺជាលិខិតរបស់ខាងលេខាគណៈលេខាភូមិភាគឧត្តរចុះថ្ងៃទី១៧ ខែ៤ ឆ្នាំ៧៨។ ខ្ញុំសូមធ្វើការដកស្រង់៖ “ខ្ញុំសូមជូនឯកសារចម្លើយរបស់ឈ្មោះ៖ ១) ឈ្មោះ សាន់ អ៊ាប ហៅ ខុន ពាណិជ្ជកម្ម១០៣ប្រចាំនៅភ្នំពេញ។ ២) ឈ្មោះ សោយ ហៅ ផង់ សន្តិសុខ១០៣ ដើម្បីគណៈពិនិត្យហើយនិងជាឯកសារស្រាវជ្រាវខ្សែក្បត់បង្កប់ស៊ីរូងផ្ទៃក្នុង”។ សូមបញ្ចប់ការដកស្រង់។

[១៥:១៣:០២]

ហើយឯកសារចុងក្រោយរបស់ភូមិភាគដែលខ្ញុំធ្វើការបង្ហាញទាក់ទងទៅនឹងគោលនយោបាយរបស់បក្សទាក់ទងទៅនឹងឯកសារខ្មាំងគឺឯកសារ E3/1094 គឺ E3/1094។ ជារបាយការណ៍ប្រចាំខែរាយការណ៍ជូនអង្គការរបស់ខាងបស្ចិមគឺចុះខែឧសភា ឆ្នាំ៧៨ -- ខែមេសា ឆ្នាំ៧៨។របាយការណ៍នេះបាននិយាយនៅក្នុងចំណុច១ ចុចពីរ ដែលនិយាយអំពីសកម្មខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង។ ហើយខ្ញុំធ្វើការអានជូន៖ “ពិនិត្យជារួមសកម្មភាពខ្មាំងដែលនៅបង្កប់ស៊ីរូងផ្ទៃក្នុង ក្នុងរយៈពេល១ខែនេះវាធ្វើសកម្មភាពបំផុស ខែទំនាស់ វាយប្រហារប្រឆាំងនិងបំផ្លាញយើងតាមគ្រប់រូបភាពជាបន្តបន្ទាប់ទៀត និងកាន់ស៊ីជម្រៅដែលលេចចេញពីសមាសភាពមិនល្អមួយចំនួនតូចដែលជាដៃជើងរបស់ខ្មាំង ឬអ្នកជាប់ចម្លើយខ្មាំង។ សមាសភាពដែលសម្រិតសម្រាំងចេញពីអង្គការផ្សេងៗ និងចេញពីកងទ័ពជាដើម ព្រមទាំងសមាសភាព ១៧មេសា ជារដ្ឋការចាស់ និងអាណិកជនចិន និងយួនមួយចំនួន”។

[១៥:១៤:៤០]

ហើយនៅក្នុងកថាខណ្ឌបន្ទាប់ខ្ញុំសូមធ្វើការដកស្រង់៖ “យើងមានផែនការដើម្បីអនុវត្តៗនូវមាគ៌ាបក្ស ដើម្បីធ្វើការដកចោលក៏ដូចជាបោសសម្អាតពួកវា”។ ហើយរបាយការណ៍លម្អិតរាយរាប់ដូចតទៅនេះ ពីខាងភូមិភាគបស្ចិមទាក់ទងទៅនឹងមាគ៌ាបក្ស ហើយនិងខ្មាំងនៅក្នុងភូមិភាគ។ ខ្មែរមានលេខ 00143610, អង់គ្លេសមានលេខ 00315374 ដល់ 75 និងភាសាបារាំងមានលេខ 00593930។ ហើយផ្នែកដែលគេរាយកាណ៍គឺពីខាងតំបន់៤៧ ដែលនិយាយអំពីការសម្រិតសម្រាំងសមាសភាពយួន

ភ្នាក់ងារ សេ.អ៊ី.អា និងសមាសភាពមិនល្អ។ គឺគេរាយការណ៍ដូចតទៅនេះ៖

"ទី១ កម្ទេចជនជាតិយួនទាំងតូច ទាំងធំ ទាំងចាស់ ទាំងក្មេង អស់ចំនួន១០០នាក់។ កម្ទេចពួកបណ្ដាស័ក្តិ និងពួក សេ.អ៊ី.អា របស់ចក្រពត្តិអាមេរិកាំងដែលនៅបង្កប់ក្នុងអង្គភាព និងសហករណ៍ អស់ចំនួន៦០នាក់"។

ហើយឯកសារចុងក្រោយដែលខ្ញុំចង់បង្ហាញអំពីគោលនយោបាយទូទៅចំពោះខ្មាំង។ មុនពេលដែលខ្ញុំបន្តទៅឯកសារថ្មីមួយទៀតនោះ គឺឯកសារដែលនិយាយអំពីគោលនយោបាយផ្ដោតទៅលើទាហាន និងមន្ត្រី លន់ នល់ គឺជាឯកសារដែលបង្ហាញអំពីការធ្វើសហឧក្រិដ្ឋកម្មរួមនៅក្នុងទូទាំងប្រទេស។ គឺឯកសារ E3/2365។ គឺជាផែនទីមួយដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបង្ហាញពីមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដែលត្រូវកំណត់នៅទូទាំងប្រទេស ហើយនេះគឺជាគម្រោងរៀបចំផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅក្នុងផែនទីនេះគឺចំណុចពណ៌លឿង គឺជាមន្ទីរសន្តិសុខដែលខាងមជ្ឈមណ្ឌលឯកសារកម្ពុជាបានកំណត់។ ចំណែកចំណុចពណ៌ក្រហម គឺជាផ្នូររួម ឬមួយក៏ជាទីតាំងសម្លាប់មនុស្ស។ ផែនទីនេះធ្វើឡើងនៅក្នុងឆ្នាំ២០០១។ ដូច្នេះ វាមិនបានរួមបញ្ចូលនៅក្នុងផែនទីនេះនៅទីតាំងទាំងអស់នោះទេ។--

[១៥:១៧:៣៥]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា ផ្អាកបន្តិចសិន!

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនៅស្ងាត់ស្ងៀមហើយនៅរសៀលនេះ ទោះបីជាមានបញ្ហាដែលខ្ញុំត្រូវតែលើកឡើងក៏ដោយ។ ខ្ញុំសូមបញ្ជាក់ថា យើងកំពុងតែងាកចេញអំពីវិសាលភាពរបស់យើងហើយយើង -- នេះមិនមែនត្រឹមតែនិយាយអំពីគោលនយោបាយទេ គឺនិយាយអំពីការអនុវត្តគោលនយោបាយ។ ដូច្នេះ សហព្រះរាជអាជ្ញាគាត់បានបង្ហាញឯកសារដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមិនមែនជាឯកសារដែលកើតឡើងនៅពេលអង្គហេតុនោះទេ។ ដូច្នេះ យើងខ្ញុំសូមជំទាស់ទៅនឹងការបង្ហាញឯកសារទាំងអស់នេះ។ យើងមិនដឹងថាតើអ្នក -- គេធ្វើឯកសារនេះយ៉ាងម៉េច យើងមិនដឹងអំពីលក្ខខណ្ឌនៃការធ្វើការឯកសារនេះទេ។ យើងដឹងថាឯកសារនេះមានលេខ E3 ក៏ប៉ុន្តែសវនាការយើង

នេះគឺថាពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម។ ដូច្នេះឯកសារផែនទីនេះ គឺថាវាងាកចេញអំពីវិសាលភាពនៃសវនាការយើងហើយ។ ហើយឯកសារនេះទៀត គឺថាវាមិនពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១ នោះទេ។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅនឹងការបង្ហាញឯកសារមួយនេះ ដែលថាវាពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម និងការជម្លៀសប្រជាជន ហើយនិងក៏ពាក់ព័ន្ធទៅនឹងការសម្លាប់ទាហាននោះ។ ដូច្នេះសូមជំទាស់ទៅនឹងការបង្ហាញឯកសារនេះ។

[១៥:១៩:១០]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតប។ ការពិតគឺថាវាមាននៅមន្ទីរសន្តិសុខរាប់រយដែលត្រូវបានគេរកឃើញនៅទូទាំងប្រទេស។ ហើយទាំងអស់នេះ គឺជាភស្តុតាងពាក់ព័ន្ធដែលបង្ហាញអំពីសហឧក្រិដ្ឋកម្មរួមនៅទូទាំងប្រទេស ដែលរួមបញ្ចូលទាំងគ្រប់អង្គការស្ថាប័នទាំងអស់នេះ។ នេះគឺជាផែនទី។ ហើយឯកសារពីរទៀតដែលខ្ញុំត្រូវបង្ហាញវាគ្រាន់តែជាបញ្ជីនៃមន្ទីរសន្តិសុខ ហើយនិងផ្នូរកប់សពរួមដែលកំណត់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយខ្ញុំគិតថា មេធាវីការពារក្តីអាចពិនិត្យមើលទៅលើអ្វីដែលយើងបានលើកឡើង ដែលជាព័ត៌មានលម្អិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាផែន -- គម្រោងផែនទី ឬក៏ជារណ្តៅសាកសពរួមជាដើម ដែលខ្ញុំនឹងមិនបង្ហាញអំពីព័ត៌មានលម្អិតអំពីរណ្តៅសាកសព ឬក៏មន្ទីរសន្តិសុខនោះឡើយ។ ប៉ុន្តែអ្វីដែលយើងធ្វើនៅពេលនេះគឺថាវាជាការពិត វាជាអង្គហេតុមួយដែលថាមានមន្ទីរសន្តិសុខរាប់រយនៅទូទាំងប្រទេស។ ហើយការដែលនិយាយអំពីចំនួននេះ គឺជាការបង្ហាញអំពីវត្តមាននៃសហឧក្រិដ្ឋកម្មរួមនៅទូទាំងប្រទេស។ សូមអរគុណ។

[១៥:២០:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២២:០០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន ដែលបានលើកឡើងនេះមិនសមស្របទេ។ ដូច្នេះសេចក្តីជំទាស់មិនមានប្រសិទ្ធភាព។ ឯកសារនេះបានដាក់បញ្ចូលនៅក្នុងសំណុំរឿងហើយ ហើយចំពោះឯកសារវាយតម្លៃភស្តុតាង និងទម្ងន់នៃភស្តុតាងនោះ គឺអង្គជំនុំជម្រះនឹងពិនិត្យពិចារណានៅពេលរៀបចំសាលក្រម។

លោកតំណាងសហព្រះរាជអាជ្ញាបន្តការបង្ហាញឯកសារតទៅទៀត!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជាចុងក្រោយនេះ ខ្ញុំសូមថាជាការកំណត់ត្រាប្រតិចារិកមួយ គឺឯកសារពីរដែលខ្ញុំគិតថាអង្គជំនុំជម្រះទើបតែទទួលបានព័ត៌មានថ្មីៗនេះ។ គឺបញ្ជីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានលេខ E3/2764។ គឺជាឯកសាររបស់មជ្ឈមណ្ឌលកម្ពុជាដែលមានចំណងជើងថា "មន្ទីរឃុំឃាំងរបស់កម្ពុជាប្រជាធិបតេយ្យ"។ នៅខែកុម្ភៈ ឆ្នាំ២០០៨ ហើយវាមានមន្ទីរសន្តិសុខរាប់រយដែលត្រូវបានគេរកឃើញនៅទូទាំងប្រទេសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ គឺគម្រោងរៀបចំផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៥:២៣:២៥]

ឯកសារមួយទៀត E3/2763 គឺជាបញ្ជីរបស់រណ្តៅសាកសពរួមចំនួន៣៩០ ដែលត្រូវបានកំណត់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងគម្រោងផែនទីរបស់ខ្លួន។

ខ្ញុំគិតថា ខ្ញុំបានបញ្ចប់ផ្នែកទី១នៃការបង្ហាញរបស់ខ្ញុំទាក់ទងទៅនឹងគោលនយោបាយរបស់ខ្មែរក្រហមចំពោះខ្មាំង។ ឥឡូវនេះ ខ្ញុំនឹងនិយាយឯកសារមួយទៀត ដែលខាងមេធាវីការពារក្តី នួន ជា បានសួរជាច្រើនដងរួចមកហើយ អំពីបញ្ហាដែលថាតើមានឯកសារណាដែលបង្ហាញអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាផ្តោតទៅលើមន្ត្រី និងយោធារបស់ លន់ នល់ នោះ។

ជាដំបូងខ្ញុំសូមចាប់ផ្តើម ហើយសូមឲ្យអស់លោក លោកស្រីទាំងអស់គ្នាមេត្តាតាមដានជាមួយខ្ញុំដែលខ្ញុំប្រើប្រាស់ទស្សនាវដ្តីទង់បដិវត្តផង ទស្សនាវដ្តីយុវជនយុវនារីបដិវត្តផង ដែលនិយាយអំពីគោលនយោបាយរបស់បក្ស ក៏ដូចជាក្រុមដែលគេចាត់ទុកថាជាខ្មាំង។

[១៥:២៥:៣៥]

ឯកសារទី១ ដែលដែលខ្ញុំនឹងប្រើប្រាស់ គឺឯកសារដែលមានលេខ E3/146 គឺជាទស្សនាវដ្តីទង់បដិវត្តចុះខែ៨ ខែ៩ ឆ្នាំ៧៤។ ហើយនៅក្នុងឯកសារនេះ គឺខ្មែរមានលេខ 00283409, ភាសាអង់គ្លេសមានលេខ 00538746, ភាសាបារាំងមានលេខ 00611810 នៅក្នុងទំព័រនេះគឺការបោះពុម្ពផ្សាយបានបញ្ជាក់ដូចតទៅនេះ៖ "ក្រុមសក្តិភូមិត្រូវបែងចែក -- វណ្ណៈសក្តិភូមិបែងចែកជាពីរប្រភេទ។ សក្តិភូមិអភិជនទី១ និងសក្តិភូមិម្ចាស់ដីទី២"។ ខ្ញុំសូមធ្វើការដកស្រង់៖ "សក្តិភូមិអភិជន សំដៅទៅលើពួកសក្តិភូមិកាន់អំណាចដែលមានអំណាចដើម្បីជិះជាន់ប្រជាជន មានតាំងពីស្តេច នាហ្មឺន ជាកុង្សី

ជាចៅហ្វាយខេត្ត ចៅហ្វាយស្រុក រហូតដល់មេឃុំ ជំទប់"។ បញ្ហាដដែល -- នៅក្នុងឯកសារដដែលនេះគឺពីរបីសន្លឹកចុះមកក្រោមទៀត គឺបានបញ្ជាក់អំពីប្រភេទនៃសក្តិភូមិទី២ គឺមានដូចជាសិស្ស និស្សិត អ្នករដ្ឋការ ដែលរស់នៅដោយប្រើបញ្ញាជាសំខាន់។ គឺក្រុមដែលគេហៅថា ជាពួកអភិជនមានបញ្ញា--

[១៥:២៦:៤៧]

ហើយឯកសារបន្តគឺ E3/10 គឺជាទស្សនាវដ្តីទង់បដិវត្តចុះខែ៩ ខែ១០ ឆ្នាំ៧៦។ ហើយផ្នែកដែលខ្ញុំនឹងធ្វើការបង្ហាញនៅពេលនេះ គឺជាពិពណ៌នាអំពីភាពខុសគ្នានៃវណ្ណៈនៅក្នុងសង្គមកម្ពុជា។ ភេទទំនាស់វណ្ណៈនៅក្នុងសង្គមកម្ពុជា ឯកសារដែលមាន 00063093 ដល់ 94, អង់គ្លេសមានលេខ 00450529 ដល់ 30, បារាំងមានលេខ 00491895 ដល់ 96។ នៅក្នុងទស្សនាវដ្តីទង់បដិវត្តនេះគឺមានដូចតទៅនេះ ខ្ញុំសូមអាន៖ "ជាមូលដ្ឋានគឺទំនាស់រវាងវណ្ណៈអធន និងវណ្ណៈនាយទុន ក្រៅពីនេះនិងមានទំនាស់វណ្ណៈជាមួយវណ្ណៈសក្តិភូមិជាម្ចាស់ដី ជាអភិជន ហើយមានការបកស្រាយថា ជាអភិជនដែលរួមមានមេឃុំ ចៅហ្វាយស្រុក ចៅហ្វាយខេត្ត អ្នករដ្ឋការ ប៉ូលិស ទាហាន"។ ហើយបន្តមកកថាខណ្ឌបន្ទាប់ "គឺមានទំនាស់វណ្ណៈរវាងកសិករចាស់ គឺកសិករក្រីក្រ និងកសិករកណ្តាលថ្នាក់ក្រោម។ ក្រៅពីនេះក៏មានទំនាស់ជាមួយសក្តិភូមិជាទំនាស់ស្លាប់រស់ បើបុគ្គលវាកែមិនទំនាស់ស្លាប់រស់ទេ តែវាមិនងាយកែទេ ទំនាស់វាកប់ដោយសារកម្លាំងផ្តាច់ការរបស់វណ្ណៈអធន វាខ្លាំងជាង វារើមិនបាន។ អាចមានសមាសភាពមួយចំនួនធ្វើការកែប្រែ ប៉ុន្តែសមាសភាពជាច្រើនមិនផ្លាស់ប្តូរទេ នៅពេលដែលពួកគេស្លាប់ទៅ វាផ្តាំកូនវាឲ្យតស៊ូជាមួយកុម្មុយនីស្តតទៅទៀត"។ ហើយខ្ញុំបន្តនៅកថាខណ្ឌក្រោមមួយទៀត ខ្ញុំសូមធ្វើការដកស្រង់៖

[១៥:២៨:៣១]

"នៅមូលដ្ឋានភេទជាទំនាស់ដែលយើងចាប់បាន ភាគច្រើនគឺជាមន្ត្រីរដ្ឋការ ប៉ូលិស យោធា ហើយនិងនិស្សិត គឺពួកទាំងអស់នេះជាវណ្ណៈសក្តិភូមិម្ចាស់ដី ពួកគេជាអ្នកបង្កជម្លោះ ប៉ុន្តែពួកគេមិនបង្ហាញមុខនោះឡើយ។ នៅពេលដែលគេមានអំណាច គេមិនបង្ហាញមុខឡើយ។ ក្រៅពីការទាស់គ្នាស្លាប់រស់នេះ ជាមួយនឹងពួកសក្តិភូមិម្ចាស់ដី គឺថាវាមានទំនាស់ផ្ទៃក្នុងដែលកើតឡើងចេញពីការយល់ដឹងអំពីផ្នែកនយោបាយកម្រិតទាប និងកម្រិតខ្ពស់។ យើងត្រូវដោះស្រាយបញ្ហានេះ តាមរយៈការអប់រំ។ ជាសង្ខេបនៅក្នុងសង្គមបច្ចុប្បន្នហ្នឹង គឺថាមាន ទី១ គឺថាទំនាស់ផ្ទៃក្នុងជាបន្ទាប់បន្សំ និងទី២ គឺជាទំនាស់ស្លាប់រស់រវាងពួកកម្មករ និងកសិករ ហើយនិងជាមួយពួកមូលធនសក្តិភូមិនិយម គឺម្ខាងទៀត"។

[១៥:៣១:០៣]

លោក លោកស្រីចៅក្រម មាគ៌ានយោបាយដដែលនេះ ក៏បានលើកឡើងនៅលើឯកសារ E3/138 ផងដែរ ដែលជាសេចក្ដីណែនាំរបស់បក្សកុម្មុយនីស្ដកម្ពុជានិយាយអំពីមនោគមន៍វិជ្ជាទៅលើវណ្ណៈនាយទុន ដែលក្នុងនោះ គឺថាប្រើភាសាដដែលនៅក្នុងមាគ៌ានយោបាយរបស់បក្ស។ ហើយយើងមានសេចក្ដីថ្លែងការណ៍ពីថ្នាក់ដឹកនាំពាក់ព័ន្ធទៅនឹងមន្ត្រី និងទាហានលន់ នល់ ក្នុងរយៈពេលឆ្ពោះទៅកាន់ថ្ងៃ១៧ មេសា ១៩៧៥។ ឯកសារទី១ ដែលខ្ញុំចង់បង្ហាញនោះ គឺ E3/707 ។ កិច្ចសម្ភាសន៍ខែមេសា ១៩៧៨ ដែល ដេន ប៊ឺសហ៊ីន *(តាមសូរស័ព្ទ)* ដែលជាអ្នកនិពន្ធនាយកនៃកាសែតរបស់សហរដ្ឋអាមេរិកសម្ភាស ជាមួយលោក អៀង សារី។ ERN ជាភាសាខ្មែរ 00728134, អង់គ្លេស S00049323, បារាំង S00742550។ ដែល អៀង សារី រៀបរាប់ឲ្យសមាជបក្ស ក្រោយពីឆ្នាំ១៩៧៣។ ឧបនាយករដ្ឋមន្ត្រី គឺនិយាយសំដៅទៅលើ អៀង សារី។ ដែលក្នុងពេលនោះ គឺថាយើងផ្ដោតទៅលើកម្លាំងផ្សេងៗ វណ្ណៈផ្សេងៗគឺវណ្ណៈជិះជាន់ ហើយក្រៅពីនេះគឺមានពួកលន់ នល់ ដែលជាពួកប្រតិកិរិយាទាំងស្រុង ហើយនិងគឺពួកចក្រពត្តិ -- ដែលជាបរិវាររបស់ចក្រពត្តិបរទេស។ ហើយនៅផ្នែកកណ្ដាល គឺមាន សីហនុ ដែលជាប្រមុខរដ្ឋ ដែលគាំទ្រទៅដល់ឯករាជ្យភាពរបស់ប្រទេស។ ហើយទៅខាងឆ្វេង -- ក្នុងខាងឆ្វេងនិយមវិញ មាន ខៀវ សំផន ដែលសព្វថ្ងៃគឺជាប្រធានគណៈប្រធានរដ្ឋ ដែលពេលនោះ គឺជាបញ្ញវន្តនិងអ្នកនយោបាយល្បីល្បាញមួយរូប។ គោលជំហរប្រឆាំងនឹងពួកចក្រពត្តិនិយមរបស់គាត់ ភាពរឹងមាំខ្លាំងក្លាដែលបណ្ដាលឲ្យគាត់ត្រូវគេបង្ខំភៀសចេញទីក្រុងភ្នំពេញ ក្រោមសម្ពាធធ្ងន់ធ្ងររបស់វណ្ណៈពួកកាន់អំណាច។ ហើយក្នុងនោះក៏មានសាររបស់ អៀង សារី៖ "យើងច្របាច់បញ្ចូលគ្នាទាំងពួកស្ដាំនិយម ឆ្វេងនិយម ក៏ដូចជាក្រុមរណសិរ្សប្រឆាំងទៅនឹងការគាបសង្កត់របស់ពួកបរទេស និងពួកលន់ នល់"។ បញ្ចប់ការដកស្រង់។

[១៥:៣៤:៣៧]

ឯកសារ E3/783 គឺឯកសារចុះខែតុលា ឆ្នាំ១៩៧២ ខែតុលា វិច្ឆិកា ៧២ ទង់បដិវត្តន៍។ គឺខ្មែរ ERN 00442285, អង់គ្លេស 00720205 និងបារាំង 00721041។ ទង់បដិវត្តនេះគឺបក្សនិយាយសំដៅទៅលើ លន់ នល់, សិរិមតៈ និង សឺង ង៉ុកថាញ់ ថាជាពួកក្បត់ដែលជាប់ទាក់ទងជាមួយនឹងពួកចក្រពត្តិអាមេរិក គឺថាដែលត្រូវកម្ទេចចោលទាំងស្រុងតែម្ដង។

ហើយឯកសារមួយទៀត គឺលោក លោកស្រីចៅក្រមបានជ្រាបហើយ ខ្ញុំសូមលើកយកមក

យោងសង្ខេបទេគឺឯកសារ E3/117។ ជាឯកសារគន្លឹះទាក់ទងទៅនឹងការកំណត់គោលដៅទៅលើមន្ត្រី និងទាហាន លន់ នល់ ចុះថ្ងៃទី២៦ កុម្ភៈ ១៩៧៥ ដែលជាលិខិតឆ្លើយឆ្លងតាមសារព័ត៌មានចុះហត្ថលេខាដោយ ខៀវ សំផន ដែលជាប្រធានរបស់សមាជជាតិរបស់ ហ្វ្រុង និងហ្វុងលើកទី២នោះ។

[១៥:៣៦:២៦]

នៅក្នុងកថា*វ័ន* ថាតើសមាជជាតិហ្នឹងបានកំណត់ចំពោះពួកក្បត់ទាំងប្រាំពីរ ដែលមាន លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, អ៊ិន តាំ, ឡុង បូរ៉េត និង សូស្តែន ហ្វែណង់ណេស និងបានប្រកាសសូមដកស្រង់ថា៖ "ត្រូវតែសម្លាប់ពួកក្បត់ទាំងប្រាំពីរនេះជាដាច់ខាត"។ ទាក់ទងទៅនឹងឯកសារនេះដែរនោះ គឺឯកសារ E3/189 ដែលជាការចម្លងពីសមាជលើកទី២ និយាយអំពីពួកក្បត់ទាំងប្រាំពីរនេះដែរដែលផ្ញើជូនដោយរដ្ឋមន្ត្រីក្រសួងការបរទេសគឺ សារិន ឆាក ជូនអង្គការសហប្រជាជាតិ និងបង្ហាញជូនអង្គការសហប្រជាជនដោយតំណាងអចិន្ត្រៃយ៍នៃសាធារណរដ្ឋប្រជាមានិតចិន។

ហើយឯកសារពាក់ព័ន្ធមួយទៀតនោះគឺ E3/3334 ។ ជារបាយការណ៍ពីស្ថានទូតសហរដ្ឋអាមេរិក ចុះថ្ងៃទី០៤ មីនា ១៩៧៥ កថាខណ្ឌ១៥នៃរបាយកាណ៍នេះនិយាយអំពីការផ្សាយ ការប្រកាសប្រហារជីវិតពួកមហាក្បត់ទាំងប្រាំពីរនេះ។

[១៥:៣៨:០៨]

ឯកសារមួយទៀតនោះ គឺឯកសារ E3/120។ នេះគឺជាសេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន ដែលផ្សាយតាមរយៈវិទ្យុផ្សាយសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា នៅថ្ងៃទី១៥ មីនា ១៩៧៥។ ឯកសារនេះគឺសេចក្ដីថ្លែងការណ៍អាចរកឃើញនៅត្រង់ ERN ជាភាសាខ្មែរ 00700236 ដល់ 37, អង់គ្លេស 00166828 និងបារាំង 00700226 ដល់ 27។ ហើយនៅក្នុងការផ្សាយតាមវិទ្យុនេះ ខៀវ សំផន បានកំណត់ជាថ្មីម្ដងទៀតនូវឈ្មោះរបស់ពួកក្បត់ លន់ លន់ ហើយគាត់អំពាវនាវដល់ប្រជាជនឲ្យពង្រឹងការតស៊ូរបស់ខ្លួនប្រឆាំងទៅនឹងពួកក្បត់ លន់ នល់ ដោយបានលើកឡើងដូចខាងក្រោមនេះ៖

"យើងខ្ញុំសូមអំពាវនាវដល់ប្រជាជនទាំងអស់ឲ្យពង្រឹងសកម្មភាពតស៊ូ វាយប្រហារបនក្បត់ឲ្យបានខ្លាំងក្លា និងត្រឹមត្រូវបំផុត។ កម្ទេចឃ្លាំងស្រូវ ឃ្លាំងសាំង វាយឃ្លាំងផ្គត់ផ្គង់របស់ខ្មាំងទាំងអស់ក៏ដូចស្ថានីយ៍នគរបាល ពន្ធនាគារ ហើយរឹបអូសព្រះសង្ឃ បងប្អូនទាំងអស់ដែលកំពុងតែត្រូវគេឃុំខ្លួន។ ហើយនិងដើម្បីបញ្ចប់ចំពោះពួកក្បត់ទាំងអស់នេះ" បញ្ចប់ការដកស្រង់។

[១៥:៤០:១៧]

នៅក្នុងឯកសារ E3/118 -- ឯកសារ E3/118 ជាសេចក្តីថ្លែងការណ៍ មួយទៀតដែលផ្សាយតាមវិទ្យុរណសិរ្សរួបរួមជាតិនៅថ្ងៃទី១៣ មេសា ១៩៧៥។ ERNជាភាសាខ្មែរ 00700278, អង់គ្លេស 00166949, បារាំង 00700262 នៅក្នុងការផ្សាយតាមវិទ្យុនេះ ខៀវ សំផន បានធ្វើសេចក្តីថ្លែង-ការណ៍ដូចតទៅទាក់ទងទៅនឹងគណៈកម្មាធិការដឹកនាំរដ្ឋាភិបាល លន់ នល់ ដែលត្រូវបានបង្កើតថ្មី។ សូមដកស្រង់ "អ្វីដែលគេហៅថាគណៈកម្មាធិការកំពូលនេះគឺជាអង្គការក្បត់មួយរៀបចំឡើង ដើម្បីការបង្ហូរឈាមផ្នែកខាងព្រះពុទ្ធសាសនា យុវជន កុមារ និងបំផ្លិចបំផ្លាញ ហើយនេះគឺជាការអំពើដែលរៀបចំឡើងដើម្បីក្បត់របស់ពួកក្បត់ទាំងនេះ។ ដោយសារហេតុផលទាំងអស់នេះហើយ យើងសូមអំពាវនាវដល់ជនរួមជាតិទាំងនៅភ្នំពេញក៏ដូចទីបណ្តាទីរួមខេត្តដទៃទៀតដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងដោយពួកក្បត់នោះសូមចូលរួមជាមួយពួកយើងដើម្បី ហើយនិងសូមឲ្យជួយប្រគល់ខ្លួនពួកក្បត់ទាំងអស់នេះ។

ហើយនៅក្នុងឯកសារ E3/118 នេះដដែល គឺERN ជាភាសាខ្មែរ 00905195 ដល់ 96, អង់គ្លេស 00166974 -- ការបកប្រែជាភាសាបារាំងគឺមិនទាន់រួចរាល់នៅឡើយទេ។ នេះគឺគេផ្សាយតាមវិទ្យុដោយកងទ័ពប្រជាជនរំដោះជាតិកម្ពុជាដែលផ្សាយនៅវេលាម៉ោង ០៥:៥៩ ជី.អឹម.ធី ឬក៏អាចថាម៉ោងដប់ពីរ ឬក៏ម៉ោងមួយរសៀលនៅភ្នំពេញ។ ការផ្សាយនេះគឺមានផ្សាយដូចតទៅនេះ៖ "តាមរយៈនេះ ខ្ញុំសូមជម្រាបជូនទៅដល់បនក្បត់ លន់ នល់ និងមេបញ្ជារបស់ពួកគេទាំងអស់ដែលថាយើងមិនមែនមកទីនេះដើម្បីចរចានោះទេ។ យើងចូលមកទីក្រុងដោយចុងកាណុង កងកម្លាំងរបស់យើង កងកម្លាំងរំដោះជាតិប្រជាជនរបស់យើងពីភូមិភាគបានកាន់កាប់វិទ្យុផ្សាយសំឡេងនៅម៉ោងប្រាំបួន ហើយចំពោះសមាជិកនៃបនក្បត់ លន់ នល់ ដទៃទៀតយើងមិនត្រូវការចរចាជាមួយពួកវាទេ ។ ពួកគេត្រូវតែទម្លាក់អាវុធចុះហើយត្រូវតែចូលខ្លួនជាមួយនឹងភូមិភាគបូព៌ា និងភូមិភាគឧត្តរនៃកងកម្លាំងរបស់យើង"។

[១៥:៤៤:០៩]

ឯកសារបន្ទាប់គឺឯកសារ E3/2694, ឯកសារ E3/2694។ នេះជាសារទូរលេខ 595 មកពីកុងស៊ុលបារាំង ហ្សង់ ឌីរ៉ាក់ ផ្ញើទៅប៉ារីស និយាយអំពីការសុំសិទ្ធិជ្រកកោនផ្នែកនយោបាយចុះថ្ងៃទី១៨ មេសា ៧៥ ដែលមានចែងដូចតទៅ៖ "តាមរយៈ ឱសានវាទពីគណៈកម្មាធិការក្រុង ខ្ញុំត្រូវបង្ខំចិត្តដើម្បីធានាដល់សន្តិសុខនៃជនរួមជាតិរបស់យើងដើម្បីដាក់បញ្ចូលនៅក្នុងបញ្ជីឈ្មោះមនុស្សដែលមានវត្តមាននៅក្នុងស្ថានទូតទី១ សម្តេចសិរិមតៈ និងមន្ត្រីរបស់គាត់។ ទី២ គឺសម្តេចស្ត្រី ម៉ុម មុនីវង្ស ជនជាតិដើម

ឡាវ និងជាប្រពន្ធទី៣ របស់សម្តេច សីហនុ និងព្រះរាជបុត្រីរបស់ព្រះអង្គនិងចៅប្រសាប្រុសស្រី។ លេខ៣ អ៊ុង ប៊ុនហ៊ី ប្រធានរដ្ឋសភាជាតិ។ ទី៤ លោក លឿង ណាល់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដែលត្រូវរារាំងមិនឲ្យចូលមកស្ថានទូត។ ខ្ញុំត្រូវបានគេបង្ខំឲ្យបញ្ជូនឈ្មោះនេះទៅឲ្យគេក្នុងរយៈពេល២៤ម៉ោង"។

[១៥:៤៥:៤៧]

ឯកសារបន្ទាប់ គឺឯកសារ E3/22 -- សូមម្តងទៀត E3/2700 ជាសារទូរលេខ លេខ៦០៥ មកពីកុងស៊ុលបារាំង ហ្សង់ ឌីរ៉ាក់ ផ្ញើជូនទីក្រុងប៉ារីសមានចំណងជើងថា "ការចេញដំណើររបស់ជនភៀសខ្លួន", ចុះថ្ងៃទី២០ មេសា ៧៥ ដែលមានការកត់ត្រាថាបានទទួលនៅវេលាម៉ោងដប់មួយ និងហាសិបប្រាំនាទី។ សារទូរលេខនេះ គឺបានសរសេរដូចតទៅ៖ សូមដកស្រង់ "តាមរយៈអន្តរាគមន៍របស់ខ្ញុំ ព្រឹកមិញនេះ គណៈកម្មាធិការក្រុងអនុញ្ញាតឲ្យប្រជាជនកម្ពុជាដែលបានជ្រកកោននៅក្នុងស្ថានទូតរបស់យើងចាកចេញដោយសេរី ជាមួយនឹងករណីលើកលែងដែលមានអតីតមន្ត្រីរបបចាស់ ដែលចូលរួមនៅជាមួយនឹងក្រុមរបស់យើងនេះ"។ បញ្ចប់ការដកស្រង់។

សារទូរលេខមួយទៀត ចុះថ្ងៃខែដដែលពី ហ្សង់ ឌីរ៉ាក់ នេះគឺឯកសារ E3/2702 ៗ ជាសារទូរលេខ លេខ៦០៨ នៅក្នុងសារទូរលេខ លោក ឌីរ៉ាក់ បានសរសេរដូចតទៅ សូមដកស្រង់ -- ខ្ញុំយោងទៅសារទូរលេខ លេខ៥៩៥ គឺឯកសារដែលខ្ញុំត្រូវបង្ហាញខាងលើអម្បាញ់មិញនេះ គឺឯកសារ E3/2694។ "យោងទៅលើសារទូរលេខ លេខ៥៩៥ សម្តេចសិរិមតៈ និងអ្នកដែលមានឈ្មោះដែលយោងនៅក្នុងសារទូរលេខ បានរាយការណ៍នៅរសៀលនេះ គឺត្រូវតែកំណត់គណៈកម្មាធិការ ហ្សុង ឬកងទ័ពរំដោះជាតិបានកំណត់ឈ្មោះដែលត្រូវមកយកពួកគេនៅក្នុងឡានហ្ស៊ីបមុន -- នៅមុខរបងស្ថានទូតនេះ ដែលចាត់ទុកថាអ្នកទាំងអស់នេះ គឺជាអ្នកទោស ហើយដែលត្រូវយកខ្លួននៅព្រឹកស្អែកនេះ"។

[១៥:៤៨:០៨]

ឯកសារ D365/1.1.39 ៗ, នេះជាអត្ថបទកាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី០១ ខែវិច្ឆិកា ១៩៧៥ មានចំណងជើងថា "ការកាប់សម្លាប់នៅក្នុងប្រទេសកម្ពុជា គឺត្រូវបានបញ្ជាក់ថាមានមែន"។ សូមដកស្រង់៖ "អៀង សារី ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេសបាននិយាយថា ឡុង បូរ៉េត អតីតនាយករដ្ឋមន្ត្រី លន់ ណុន ប្អូនប្រុសរបស់អតីតប្រធានាធិបតេយ្យ លន់ នល់ និង សិរិមតៈ ជាមន្ត្រីដ៏មានអំណាចម្នាក់នៅក្នុងរដ្ឋាភិបាល គឺត្រូវបានសម្លាប់ ប៉ុន្តែមិនបានផ្តល់នូវការលម្អិតនោះទេ"។

ហើយឯកសារ E3/604 ៗ នេះគឺជាអត្ថបទកាសែតបាងកកប៉ុស្តិ៍ គឺចុះថ្ងៃទី០២ ខែវិច្ឆិកា ១៩៧៥ ដាក់ចំណងជើងថា "ការកាប់សម្លាប់ គឺត្រូវបានគេទទួលស្គាល់ថាមានមែន"។ សូមដកស្រង់ "ឧបនាយករដ្ឋមន្ត្រីកម្ពុជា អៀង សារី បានអះអាងពីម្សិលមិញថា មេដឹកនាំជាន់ខ្ពស់ពីររូបនៃអតីតរបបភ្នំពេញ ត្រូវបានសម្លាប់ដោយក្រុមប្រឹក្សាប្រជាជន ក្រោយពីជ័យជម្នះរបស់ខ្មែរក្រហម។ ការអះអាងដោយ អៀង សារី ដែលថា ឡុង បូរ៉េត និង លន់ នល់ អតីតនាយករដ្ឋមន្ត្រី និងប្អូនប្រុសរបស់ -- និងលន់ នល់ ប្អូនប្រុសរបស់ប្រធានាធិបតី លន់ នល់ ត្រូវបានសម្លាប់ ប៉ុន្តែមិនមានរបាយការណ៍អះអាងលម្អិតនោះទេ"។

[១៥:៥០:០០]

ឯកសារបន្ទាប់គឺឯកសារ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ គឺឯកសារ E3/832ៗ។ ឯកសារនេះគឺជាសេចក្តីសម្រេចចុះថ្ងៃទី០៤ មិថុនា ១៩៧៥ ដែលឯកសារនេះរៀបរាប់មន្ត្រីទាហាន លន់ នល់ ១៧ នាក់ ជាពិសេសពីដែលជាពួកក្បត់ គឺចាប់ពីឋានៈវរសេនីយ៍ទោឡើងទៅ។ សូមដកស្រង់ "មនុស្សទាំង ១៧នាក់នេះត្រូវបានបក្សពិនិត្យពិច័យ ហើយបក្សបានសម្រេចថាត្រូវកម្ទេចពួកទាំងនេះចោល។ សមមិត្តរបស់នេះគឺថាស្នើសុំឲ្យសមមិត្តអនុវត្តនយោបាយរបស់បក្ស"។ បញ្ចប់ការដកស្រង់។

ជាមួយនឹងមន្ត្រី លន់ នល់ មួយចំនួនទៀតនៅក្នុងបញ្ជីនេះ ឧទាហរណ៍លេខ២ លេខ១១ និងលេខ១៧ នៅលើបញ្ជីនេះ។ ឯកសារបញ្ជាក់ថា សមាជិកក្រុមគ្រួសាររបស់ពួកគេទាំងអស់ក៏ជាៗគ្រួសារក្បត់ដែរ។ ហើយលេខ១៤នៅលើបញ្ជីនេះ គឺគាត់ជាអតីតគ្រូបង្រៀនដែលជាអ្នកក្បត់នៅពេលដែលគាត់ជាគ្រូបង្រៀន ហើយប្រវត្តិរូបរបស់គាត់ៗបានរិះគន់បដិវត្តន៍យើងយ៉ាងខ្លាំង។ ចម្លើយរបស់គាត់បញ្ជាក់ថាមានការគាំទ្រទៅដល់របបសាធារណរដ្ឋ និងធ្វើការជំទាស់ចំពោះបដិវត្តន៍យើង។

[១៥:៥២:១៦]

លោកប្រធាន ឯកសារបន្ទាប់ទៀតដែលខ្ញុំសូមយោងលឿនទេ គឺE3/276 ៗ ជាកាសែត អា.អេហ្វ.ប៉េ ចុះថ្ងៃទី២១ ឧសភា ១៩៧៦ ថាបញ្ជីឈ្មោះឧត្តមសេនីយ៍ដែលត្រូវគេរាយការណ៍ថាបានសម្លាប់ខ្លួន ជាសេចក្តីរាយការណ៍របស់កាសែត អា.អេហ្វ.ប៉េ គឺខ្មែរក្រហមបានចាប់ខ្លួនឧត្តមសេនីយ៍កម្ពុជា៥៤នាក់នៅពេលគេក្រោកកាន់កាប់ទីក្រុងភ្នំពេញនៅខែមេសា ៧៥ ហើយត្រូវបានរាយការណ៍ថាអ្នកទាំងនោះត្រូវបានគេសម្លាប់ចោលជាមួយនឹងគ្រួសាររបស់គេផងដែរ។ នេះជាការអះអាងរបស់ខាងចលនាតស៊ូកម្ពុជានៅថ្ងៃនេះឯង។ ហើយបញ្ជីរបស់ឧត្តមសេនីយ៍ទាំងនេះ គឺរបាយការណ៍នេះគឺរៀបរាប់

អំពីឈ្មោះនៅឧត្តមសេនីយ៍ លន់ នល់ ជាង៥០នាក់នេះ។ ខ្ញុំសូមមិនអានឈ្មោះឧត្តមសេនីយ៍ទាំងអស់នោះទេ។ គឺយើងបានទទួលសក្ខីកម្មនេះពី ថាច់ សារី ជាសាច់ញាតិរបស់អ្នកដែលត្រូវបានរស់រានមានជីវិតក្នុងបញ្ជីទាំងអស់នេះ។

[១៥:៥៣:៤៥]

ឯកសារមួយប្រភេទទៀតដែលយើងខ្ញុំសូមយោងផងដែរ គឺគោលនយោបាយបក្សទាក់ទងទៅនឹងមន្ត្រី និងទាហាននៃអតីតរបប លន់ នល់។ ប្រវត្តិរូបពីរដែលបានរៀបចំឡើងដោយកម្មាភិបាលក្រសួងការបរទេស។ ទី១ គឺ E3/3569 ។ នេះជាប្រវត្តិរូបរបស់ កោ ប៊ុនហេង *អេលៀស* ខុន ជាកម្មាភិបាលមួយពីក្រសួងការបរទេស ដែលនិយាយអំពីទំនាក់ទំនងកាលពីមុនជាមួយអ្នកដែលមានទំនាក់ទំនងជាមួយរបប លន់ នល់។ ឧទាហរណ៍នៅក្នុងផ្នែកទី១នៃប្រវត្តិរូបរបស់គាត់ ERN ជាភាសាខ្មែរ 00003745 ដល់ 46, អង់គ្លេស 00743406, បារាំង 00743081 ដល់ 82។ ខុន បានបង្ហាញនៅក្នុងប្រវត្តិរូបរបស់គាត់ដែលថាបងស្រីទី៣របស់គាត់ការជាមួយទាហានម្នាក់ឈ្មោះ ធម្ម រ៉េត ពាក់កាប៉ូរាល់សែហ្វ ជាទាហានហ្លួង ជាស្រទាប់វណ្ណៈពិសេស ដែលជាឧបករណ៍របស់វណ្ណៈកាន់អំណាច។ ខុន អ្នកសរសេរប្រវត្តិរូបនេះបន្តពន្យល់តទៅទៀតថា -- សូមដកស្រង់៖ “ចាប់ពីឆ្នាំ១៩៧០ មកខ្ញុំមិនដែលទាក់ទងជាមួយឪពុកម្តាយនិងបងប្អូនប្រុសរបស់ខ្ញុំតាមមធ្យោបាយណាទេ សូម្បីតែតាមលិខិតក៏អត់ដែរ ព្រោះខ្ញុំចូលរណសិរ្សមក ខ្ញុំដឹងថាគាត់មិនមែនជាអ្នកគាំទ្របដិវត្តន៍ទេ” បញ្ចប់ការដកស្រង់។

[១៥:៥៦:០៤]

ហើយនៅក្នុងផ្នែកទី៣ កថាខណ្ឌ៤ នៃប្រវត្តិរូបរបស់គាត់នេះគឺថាយើងឃើញ ERN ជាភាសាខ្មែរ 00003750, អង់គ្លេស 00743411, បារាំង 00743086។ ខុន ក៏គេតម្រូវឲ្យ ខុន ពន្យល់ជាសង្ខេបអំពីទំនាក់ទំនងរបស់គាត់ដែលគាត់មាននៅក្នុងពេលធ្វើការឃោសនានៅពេលគាត់ជាបារាំង -- និស្សិតនៅឯបារាំងក្នុងទសវត្សរ៍១៩៦០ នៅជុំវិញ៦៩។ នៅម្តុំ -- ប្រហែលជាឆ្នាំ១៩៦៩ ឡុង ខេង ដែលជាក្មួយប្រុសរបស់ លន់ នល់ ក៏បានចូលរួមនៅក្នុងយុទ្ធនាការពេលវិស្សមកាលរៀបចំឡើងដោយក្រុមវណ្ណៈកណ្តាល ដែល ឡុង ខេង គឺក្មួយប្រុសរបស់ លន់ នល់ គឺជាពួកក្បត់។ បាទ ជាក្មួយប្រុសអាក្បត់ លន់ នល់។

[១៥:៥៧:២៣]

ប្រវត្តិរូបទី២ ដែលខ្ញុំសូមយោងជាសង្ខេបទៀតគឺ E3/128 ជាប្រវត្តិរូបកម្ពុជាប្រជាធិបតេយ្យ

របស់ឈ្មោះ ឡុង នរិន្ទ ហៅថា រិត។ ឡុង នរិន្ទ គឺជាកម្មាភិបាលមកពីក្រសួងការបរទេសដែលមេរបស់គាត់ អៀង សារី បានបង្គាប់ឲ្យសរសេរប្រវត្តិរូប ហើយគាត់បានពន្យល់អំពីទំនាក់ទំនងកាលមពីមុនរបស់គាត់ជាមួយអនុរដ្ឋលេខាធិការរបបលន់ នល់ ឈ្មោះ ថាច់ ជា ។ ហើយនៅប្រវត្តិរូបរបស់គាត់នេះផងដែរ យើងឃើញមានការពន្យល់នៅត្រង់ផ្នែកទី១នៃប្រវត្តិរូបនេះ ដែល ឡុង នរិន្ទ បានរៀបរាប់អំពីការទំនាក់ទំនងរបស់គាត់ជាមួយ ថាច់ ជា នៅពេលដែលគាត់បានរៀនសូត្រជាមួយគ្នានៅសាលាគរុកោសល្យ។ ហើយឲ្យគាត់បង្គាប់ឲ្យរៀបរាប់ការទំនាក់ទំនងជាមួយនឹងអាក្បត់ ថាច់ ជា"។

ឯកសារបន្ទាប់មួយទៀតនោះគឺ E3/1539។ នេះជាបញ្ជីអ្នកទោសនៅស-២១ ដែលមានចំណងជើងថា "ឈ្មោះរបស់អ្នកទោសដែលស្លាប់នៅមន្ទីរសន្តិសុខស-២១(ក)"។ អតីតមន្ត្រីលន់ នល់ ទាហានលន់ នល់ និងសាច់ញាតិចំនួន១៦២ នាក់ស្លាប់នៅស-២១ រយៈពេលមួយក្នុងរយៈពេលតែមួយខែ គឺខែមីនា ១៩៧៦។ ១៥៣នាក់ក្នុងចំណោមអ្នកទាំងអស់នេះត្រូវបានសម្លាប់ឬក៏កម្ទេច ប្រាំបួននាក់ទៀតស្លាប់ដោយសារជំងឺ។ អ្នកដែលចូលចុងក្រោយនោះ គឺមានលេខរៀង១៥៩ បានកត់ត្រាអំពីការកាប់សម្លាប់នៅថ្ងៃទី៣០ មីនា ១៩៧៦ នៃកូនប្អូននាក់របស់ ថាច់ ជា អតីតមន្ត្រីមកពីក្រសួងអប់រំ ដែល ឡុង នរិន្ទ បានលើកឡើងនៅក្នុងប្រវត្តិរូបរបស់គាត់។

[១៥:៥៩:៤៦]

នៅក្នុងនេះផងដែរ បញ្ជីដែលគេសម្លាប់នៅស-២១ នោះយ៉ាងហោចណាស់ក៏មាន១៣នាក់ដែលជាសាច់ញាតិរបស់មហាក្បត់ ឡុង បូរ៉េត គឺ លេខរៀង៤៤ ដល់ ៥០ និងលេខរៀង១៣៥ ដល់៣៦, លេខរៀង១៤៩ និងលេខរៀង១៥៣ដល់១៥៥ ដែលថាជាសាច់ញាតិ និងជាសមាជិកគ្រួសាររបស់ ឡុង បូរ៉េត"។

ខ្ញុំត្រូវចូលទៅបង្ហាញឯកសារមួយទៀត លោកប្រធាន ប៉ុន្តែមើលទៅដូចដល់ម៉ោងហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ សវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២៦ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តការបង្ហាញឯកសារគន្លឹះរបស់ភាគីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សូមភាគីក្នុងរឿងក្តី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការ និង

សាធារណជនជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង អ.វ.ត.ក នាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*